# បទបញ្ជា ០១បប នៅខេត្តរតនគីរី ប្រទេសកម្ពុជា

## បញ្ហានិងផលប៉ះពាល់នៃការផ្តល់កម្មសិទ្ធិដីឯកជន
## នៅសហគមន៍ជនជាតិដើមភាគតិច

**ខែ មេសា ឆ្នាំ២០១៣**

**ដោយៈ អាលីសាន់ រ៉េបី**[1]

ក្រោមកិច្ចសហការជាមួយក្រុមការងារចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពខេត្តរតនគិរី

**SVC—NTFP—HA—CLEC—WHH**

**ការបកប្រែគាំទ្រថវិកាដោយៈ Welthungerhilfe**

[1] អាលីសាន់ រ៉េបី ជាអ្នកស្រាវជ្រាវឯករាជ្យ ដែលគាំទ្រថវិកាដោយ the Boren Fellowship។ របាយការណ៍នេះ ឆ្លុះបញ្ចាំងពីការវាយតម្លៃដ៏ទូលំទូលាយរបស់អ្នកនិពន្ធ ទាក់ទងនឹងការរកឃើញនៃការស្រាវជ្រាវពីជនជាតិដើមភាគតិចនៅខេត្តរតនៈគីរី។

# សេចក្តីថ្លែងអំណរគុណ

ក្រុមការងារដែលធ្វើការលើការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពខេត្តរតនគីរី សូមថ្លែងអំណរគុណ និងឧទ្ទិសរបាយការណ៍នេះ ចំពោះសហគមន៍ ចំនួន៧៩ ភូមិ គឺ៖ ភូមិ លោម ពែង ញ៉ាង កេត កាណាតធំ ការណាតតូច ទៀនបខាំ តាងជិ អ៊ិន ម៉ាលិក កាតែ តាឡាវ កានង យ៉ាសោម ស៊ើង ស៊ូ ជ្រុង សាលា តេន ប៉ាអរ សាគ្រៀង យ៉ែម កាចក់ តាអង តឺន តា ហើយ ខ្មែង តាបាក់ ចាងរ៉ា សាយ៉ស់ កាឡែង កឡែង កាទៀង កាទៀង កាចូន សមុទ្រលើ សមុទ្រក្រោម ថ្មី ប៉ាតត់ ប៉ាតាង តេងល់ ប៉ាដល ភិ ពាក់ ប្លង់ គងធំ គងយុ ប៉កតូច តាកុកច្រាយ ប្រលៃ កានសើង ក្រេះ កង គុយ តា ង៉ាច ក្រឡា ល្អក់ ភូមិ២ ក្រលង កាំ ល្មើនជង តងការម៉ាល់ ទុយធំ ស្វាយ ចាន់ ជួយ ទុន សៀងសាយ ផា យ៉ាង កិ ក្លង ទំពូនរឹងតូច កាឡៃតារ៉ង ទៀមក្រោម កាឡៃសាពូន ភ្នំកុកព្រៅ កោះពាក់ ឃុន ផាកណាម រ៉ក ឡាឡៃ ដាល់។

សូមអរគុណចំពោះអង្គការ **Welthungerhilfe** ដែលបានគាំទ្រថវិកាសម្រាប់បកប្រែរបាយការណ៍ពីភាសាអង់គ្លេសទៅភាសាខ្មែរ។

សហគមន៍ដែលមកពីភូមិខាងលើនេះ បានជួយយ៉ាងអស់ពីចិត្តក្នុងការផ្តល់ជាព័តមាន សម្រាប់ដាក់ក្នុងរបាយកាណ៍នេះ។ ក្រុមការងារដែលធ្វើការលើការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពខេត្តរតនគីរី សង្ឃឹមថា របាយការណ៍នេះ នឹងជួយឲ្យសហគមន៍ជនជាតិដើមភាគតិច ទទួលជោគជ័យក្នុងការខិតខំប្រឹងប្រែង តស៊ូ ដើម្បីការពារដីសហគមន៍ របស់ពួកគេ។

# មាតិកា

សេចក្តីថ្លែងអំណរគុណ ..... ២

ក្រុមការងារដែលធ្វើការលើការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពខេត្តរតនគីរី ..... ៦

I. សេចក្តីសង្ខេប ..... ៧

II. ជីវប្រវត្តិ ..... ១១

១–ជនជាតិដើមភាគតិចខេត្តរតនគីរី ..... ១១

ការគ្រប់គ្រងធនធានធម្មជាតិ ..... ១១

ស្ថានភាពសេដ្ឋកិច្ចនិងសង្គម ..... ១២

២–ការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពនិងបទបញ្ជា០១បប ..... ១៣

៣–ក្រុមការងារដែលធ្វើការលើចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពខេត្តរតនគីរី ..... ១៦

III. វិធីសាស្រ្ត ..... ១៧

IV. ការសង្ខេបលទ្ធផលនៃការស្រាវជ្រាវ ..... ១៨

១–ការបាត់បង់ដី ..... ២២

២–ដំណើរការក្នុងការបង្ខិតបង្ខំ ..... ២៤

៣–ការផ្តល់ពត៌មានមិនច្បាស់លាស់និងកង្វះតម្លាភាព ..... ២៥

៤–ការគំរាមកំហែង និងការបង្ខិតបង្ខំ ..... ២៨

V. ផលប៉ះពាល់នៃបទបញ្ជា០១បប ..... ២៩

១–ឯកជនភាវូបនីយកម្មនាំឲ្យបាត់បងដីនិងការចិញ្ចឹមជីវិត ........ ២៩
ក–ការលក់ដីដោយបង្ខិតបង្ខំ ........ ៣០
ខ–ការបាត់បង់របរចិញ្ចឹមជីវិត ........ ៣១
២–សហគមន៍ដែលបែកបាក់សាមគ្គី ........ ៣២
៣–បង្កើនភាពស្មុគស្មាញផ្នែកគតិយុត្តិ ........ ៣២
៤–ទំនាស់ដីធ្លីមានជាបន្តបន្ទាប់ ........ ៣៣
VI. អនុសាសន៍ ........ ៣៤
ឯកសារយោង ........ ៣៨
ឧបសម្ព័ន្ធទី១៖ បទបញ្ជា០១បប សេចក្តីណែនាំលេខ០១៥ សេចក្តីណែនាំលេខ០១៨ សេចក្តីណែនាំលេខ០២០ និងលិខិតលេខ៦៦៦ ........ ៤២
ឧបសម្ព័ន្ធទី២៖លិខិតផ្ញើឲ្យអង្គការ ........
ឧបសម្ព័ន្ធទី៣៖បញ្ជីក្រុមហ៊ុន ........

# អក្សរកាត់

| | |
|---|---|
| 01BB | ប្រើជាពាក្យយោងទៅនឹងគម្រោងដំណើរការផ្តល់កម្មសិទ្ធិដីឯកជន ដែលចេញមកពីបទបញ្ជា០១បប និងអមដោយសេចក្តីណែនាំផ្សេងៗទៀត |
| CLEC | មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ |
| CLT | កម្មសិទ្ធិដីសមូហភាព |
| CLT-WG | ក្រុមការងារដែលធ្វើការលើការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពខេត្តរតនគីរី |
| ELC | ដីសម្បទានសេដ្ឋកិច្ច |
| HA | អង្គការសហគមន៍ខ្មែរលើរតនគីរី |
| NTFP | អង្គការអនុផលព្រៃឈើ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| SVC | អង្គការសង្គ្រោះជនងាយរងគ្រោះកម្ពុជា |
| WHH | Welthungerhilfe |

## ក្រុមការងារដែលធ្វើការលើការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពខេត្តរតនគីរី

**(Ratanakiri Communal Land Titling Working Group)**

ខែកក្កដាឆ្នាំ២០១២ អង្គការក្រៅរដ្ឋាភិបាល ក្នុងខេត្តរតនគីរី ដែលកំពុងធ្វើការលើការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពបានទទួលលិខិតមួយដែលចេញដោយសាលាខេត្តរតនគីរី ដែលក្នុងលិខិតនេះបានលើក ឡើងពីឈ្មោះភូមិចំនួន៣១ដែលអាចស្ថិតក្នុងគោលនយោបាយនៃការចុះវាស់វែងដីរបស់ក្រុមនិស្សិតស្ម័គ្រចិត្ត។ លិខិតមួយនេះ មិនបានលើកឡើងពីសេចក្តីណែនាំពិសេសអ្វីទេ ប៉ុន្តែបានសូមឲ្យអង្គការក្រៅរដ្ឋាភិបាល ដែលធ្វើការលើការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាព ស្តាប់ការបង្គាប់របស់អាជ្ញាធរមូលដ្ឋាន ទាក់ទឹននឹងគោលនយោបាយនេះ។ ក្នុងការប្រជុំមួយ ដែលធ្វើឡើងមួយខែក្រោយ មន្ត្រីរដ្ឋាភិបាលបានបង្គាប់ឲ្យអង្គការក្រៅរដ្ឋាភិបាល បញ្ឈាសភូមិទាំង៣១ពីផែនការការងាររបស់ខ្លួន រហូតដល់ក្រោយពេលក្រុមនិស្សិតស្ម័គ្រចិត្តវាស់វែងដីចាកចេញទៅ ដើម្បីបញ្ជាសជម្លោះផលប្រយោជន៍ជាមួយក្រុមនិស្សិតស្ម័គ្រចិត្ត។ ដំណើរការនៃចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពត្រូវបានបញ្ឈប់ទាំងស្រុង ក្នុងពេលដែលក្រុមនិស្សិតស្ម័គ្រចិត្តចុះមកបំពេញបេសកកម្ម។

ក្នុងចំណោមភូមិទាំង៣១ដែលលើកឡើងក្នុងលិខិត ភូមិចំនួន១៩ ជាភូមិដែលអង្គការក្រៅរដ្ឋាភិបាលបានសហការជាមួយ លើការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាព។ ដូច្នេះ អង្គការក្រៅរដ្ឋាភិបាលដែលកំពុងធ្វើការលើការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាព ទទួលស្គាល់ថាបទបញ្ជាលេខ០១បប បានធ្វើឲ្យប៉ះពាលយ៉ាងខ្លាំងដល់ការខំប្រឹងប្រែង ក្នុងការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាព ហើយក៏ប្រហែលជាប៉ះពាល់ដល់ការខំប្រឹងប្រែងជាច្រើនឆ្នាំរបស់សហគមន៍ជនជាតិដើមភាគតិច ក្នុងការបញ្ជាក់ភាពជាម្ចាស់នៅលើដីព្រៃណីរបស់ខ្លួន។ ដើម្បីដោះស្រាយបញ្ហានេះ នៅខែកញ្ញា ឆ្នាំ២០១២ អង្គការក្រៅរដ្ឋាភិបាល ដែលធ្វើការលើការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពនៅខេត្តរតនគីរី បានបង្កើតជាក្រុមការងារមួយ ដែលមានឈ្មោះថា ក្រុមការងារដែលធ្វើការលើចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពខេត្តរតនគីរី (the CLT Working Group) ។

គំនិតផ្តួចផ្តើមទីមួយរបស់ក្រុមការងារដែលធ្វើការលើចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពខេត្តរតនគីរី គឺប្រមូលពត៌មានពីភូមិគោលដៅ ដើម្បីយល់ឲ្យកាន់តែច្បាស់ ពីផលប៉ះពាល់របស់បទបញ្ជាលេខ០១បប និងចងក្រងពត៌មានជារបាយការណ៍រួមនេះ ដើម្បីអាចចែករំលែកពត៌មាន ជាមួយរាជរដ្ឋាភិបាលកម្ពុជា សង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍នានា នៅថ្នាក់ជាតិនិងថ្នាក់អន្តរជាតិ។

## I. សេចក្តីសង្ខេប

ប្រទេសកម្ពុជា បានជួបប្រទះបញ្ហាដកហូតដីដែលមានទ្រង់ទ្រាយធំជាច្រើន ការការពារតិចតួច ចំពោះសិទ្ធិដីធ្លី និងឧប្បត្តិហេតុធ្ងន់ៗក្នុងទំនាស់ដីធ្លី។ ដោយរួមជាមួយការផ្លាស់ប្តូរគោលនយោបាយនាពេលថ្មីៗនេះផង ទំនាស់ដីធ្លីនៅកម្ពុជា បានឈានដល់ចំណុចវិបត្តិមួយ។ ខេត្តរតនគីរី ជាខេត្តដែលពោរពេញទៅដោយបញ្ហាទំនាស់ដីធ្លី ដោយសារខេត្តរតនគីរីមានដីមានដីជាតិល្អដែលគេដឹងគ្រប់ៗគ្នា ដែលធ្វើឲ្យខេត្តរតនគីរី មានលក្ខណៈទាក់ទាញ សម្រាប់គម្រោងអភិវឌ្ឍន៍ដីកសិឧស្សាហកម្ម ក្នុងទំរង់ជាសម្បទានដីសេដ្ឋកិច្ច។ ក្នុងពេលជាមួយគ្នានេះដែរ សហគមន៍ជនជាតិដើមភាគតិច ដែលពឹងផ្អែកទៅលើដីដើម្បីចិញ្ចឹមជីវិត មានចំនួនភាគច្រើន ក្នុងចំណោមប្រជាជនទាំងអស់នៅខេត្តរតនគីរី និងគេកាន់កាប់តំបន់ ដែលមានធនធានធម្មជាតិច្រើនជាងគេនៅក្នុងខេត្តរតនគីរី។ សម្បទានដីសេដ្ឋកិច្ច ជាទូទៅតែងតែគ្របដណ្តប់លើដីដាំដុះរបស់ជនជាតិដើមភាគតិច នៅខេត្តរតនគីរី។

ដើម្បីជួយទប់ទល់នឹងសម្ពាធទាំងនេះ ជនជាតិដើមភាគតិចអាចស្នើរសុំឲ្យមានការទទួលស្គាល់ភាពជាម្ចាស់លើដីប្រពៃណីរបស់ពួកគេ ស្របនឹងច្បាប់ភូមិបាលឆ្នាំ២០០១ តាមរយៈ កម្មសិទ្ធិដីសមូហភាព ដែលអាចឲ្យសហគមន៍ជនជាតិដើមភាគតិច ក្លាយជាម្ចាស់ពិតលើដីរបស់ពួកគេស្របច្បាប់ជាមួយនឹងកម្មសិទ្ធិតែមួយ។ មកដល់បច្ចុប្បន្ននេះ កម្មសិទ្ធិដីសមូហភាពចំនួនប្រាំ បានប្រគល់ឲ្យសហគមន៍ជនជាតិដើមភាគតិចហើយ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសថា កម្មសិទ្ធិសមូហភាពចំនួនបីទៀត នឹងត្រូវប្រគល់ឲ្យសហគមន៍ជនជាតិដើមភាគតិច នៅខែឧសភា។ ភូមិចំនួន៤៩ទៀត បានបញ្ចប់និតិវិធី នៃការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពនិង កំពុងរងចាំដំណាក់ចុងក្រោយ។

នាពេលថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជា បានបញ្ឈប់រាល់ដំណើរការនៃការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាព នៅពេលមានការប្រកាសឲ្យប្រើបទបញ្ជា០១បប ដើម្បីដោះស្រាយជម្លោះរវាងសហគមន៍ជនជាតិដើមភាគតិចនិងក្រុមហ៊ុន។ និស្សិតស្ម័គ្រចិត្តរាប់ពាន់នាក់ ត្រូវបានបញ្ជូនទៅពាសពេញផ្ទៃប្រទេសដើម្បីចុះវាស់វែងដីធ្លីដែលមានទំនាស់ និងកំណត់ព្រំប្រទល់ដី នៅលើដីដែលមានទំនាស់ទាំងនោះ។

ដើម្បីសិក្សាគោលនយោបាយថ្មីនេះ និងផលប៉ះពាល់ដល់ទំនាក់ទំនង រវាងកម្មសិទ្ធិដីសមូហភាព និងសម្បទានដីសេដ្ឋកិច្ច នៅខេត្តរតនគីរី ពត៌មានត្រូវបានប្រមូល ដោយអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការលើការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាព ចាប់ពីខែមករា ដល់ ខែកុម្ភៈ ឆ្នាំ២០១៣ ពីភូមិចំនួន ៧៩ ដែលក្នុងនោះ ភូមិចំនួន២៦ បានរងការប៉ះពាល់ដោយសារបទបញ្ជា០១បប។ ក្រុមការងារប្រមូលពត៌មាន បានសាកសួរ ប្រជាជនភូមិ ពីបញ្ហា ដែលទាក់ទងនឹងប្រជាជនភូមិ បញ្ហានានាដែលមានជាមួយក្រុមហ៊ុន និង ដំនាក់កាលនៃការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាព(បើមាន)។

ភូមិចំនួន៧១ ក្នុងចំណោមភូមិទាំង៧៩ បានធ្វើការលើដំណើរការនៃការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាព មុនការអនុវត្តបទបញ្ជា០១បប និងស្ថិតនៅដំនាក់កាលផ្សេងៗគ្នា។ ភូមិចំនួន១៨ បានចាប់ផ្តើ

មស្នើរសុំចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាព នៅឆ្នាំ២០១២ ភូមិចំនួន១៧ បានចាប់ផ្តើមនៅឆ្នាំ២០១១ ភូមិចំនួន៣ បានចាប់ផ្តើមនៅឆ្នាំ២០១០ ភូមិ៣ទៀត នៅឆ្នាំ២០០៨ ភូមិ២៩ទៀត នៅឆ្នាំ២០០៧ និង ភូមិចំនួនមួយ នៅឆ្នាំ១៩៩៨។ មកដល់ពេលបច្ចុប្បន្ន គ្មានភូមិណាមួយ បានទទួលកម្មសិទ្ធិសមូហភាពទេ។ ភូមិចំនួន៤០ មានបញ្ហាជាមួយក្រុមហ៊ុនចំនួន២៧ រួមមានសម្បទានដីសេដ្ឋកិច្ច សម្បទានខ្នាតតូច និងសម្បទានដីតំបន់រ៉ែ។

ភូមិចំនួន២៦ ដែលមានប្រជាជនសរុបប្រមាណ ៣០២៧គ្រួសារ បានទទួលរងផលប៉ះពាល់ ពីបទបញ្ជា០១បប។ ពត៌មានបន្ថែម ត្រូវបានប្រមូល ពីសហគមន៍នៅភូមិទាំង២៦ តាមរយៈកិច្ចប្រជុំពិគ្រោះយោបល់ និងកំរងសំណួរ។ មេភូមិ ចាស់ទំុក្នុងភូមិ និងប្រជាជនក្នុងសហគមន៍ត្រូវបានសួរ ពីផលប៉ះពាល់របស់បទបញ្ជាលេខ០១បប លើសហគមន៍របស់ពួកគេ ហើយតើប្រជាជនក្នុងសហគមន៍សប្បាយចិត្តនឹងគម្រោងថ្មីទេ។

បើយោងតាមពត៌មានដែលប្រមូលមកពីមេភូមិ និងចាស់ទំុក្នុងភូមិ គ្រួសារទាំងអស់ក្នុងភូមិចំនួន ១០ ត្រូវបានកំណត់ព្រំប្រទល់ដីសម្រាប់កម្មសិទ្ធិឯកជន។ ភូមិចំនួន១២ ត្រូវបានវាស់វែងដីសម្រាប់កម្មសិទ្ធិឯកជនដោយភាគ។ ភូមិចំនួនបួន បានបដិសេធអនុញ្ញាត ឲ្យក្រុមនិស្សិតស្ម័គ្រចិត្ត ចូលមកវាស់ដី លើកលែងតែក្រុមនិស្សិតស្ម័គ្រចិត្ត យល់ព្រមវាស់វែងដីជាកម្មសិទ្ធិសមូហភាព និងប្រគល់ទៅឲ្យសហគមន៍វិញ។ ជាសរុប ១៥៨៦ គ្រួសារក្នុងចំណោម ៣០២៧គ្រួសារ ដែលមកពី២៦ភូមិ (៥២%)បានជ្រើសរើសយកដីជាកម្មសិទ្ធិឯកជន ស្របតាមបទបញ្ជា០១បប។

នៅភូមិចំនួន២៥ ក្នុងចំណោមភូមិទាំង២៦ ដែលទទួលរងផលប៉ះពាល់ពីបទបញ្ជា០១បប ប្រជាជនភូមិដែលបានត្រូវបានសម្ភាស បានឆ្លើយថា ភូមិរបស់ពួកគេ មិនពេញចិត្តនឹងគម្រោងកម្មសិទ្ធិដីជាលក្ខណៈឯកជនទេ។ មូលហេតុចំបងមួយ ដែលបានលើកឡើង ក្នុងចំណោមមូលហេតុផ្សេងទៀត ចំពោះការមិនពេញចិត្តនេះ គឺដោយសារថា គោលនយោបាយនេះមិនបានធានាសុវត្ថិភាពដីរបស់សហគមន៍ទេ ដូច្នេះវាអាចនាំឲ្យពួកគេបាត់បង់ដីសហគមន៍។ ប្រជាជនភូមិ បានបញ្ជាក់ថា ពួកគេជ្រើសរើសកម្មសិទ្ធិសមូហភាពវិញ ប៉ុន្តែគេមានអារម្មណ៍ ត្រូវគាបសង្កត់ឲ្យទទួលយកការពឹត គឺកម្មសិទ្ធិដីឯកជន។ ភូមិគោលដៅរបស់គោលនយោបាយនេះ កំពុងរស់នៅជិតក្រុមហ៊ុនឯកជន និងបានទទួលរងនូវសម្ពាធខ្លាំង ក្នុងការទទួលយកជាផ្លូវការយ៉ាងលឿន នូវកម្មសិទ្ធិដីរបស់ពួកគាត់។ ពួកគេបានចូលរួមចំណែកធ្វើការ ដើម្បីស្នើរសុំកម្មសិទ្ធិសមូហភាព ប៉ុន្តែដំណើរការនៃចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាព មានរយៈពេលវែងនិង ចំណាយអស់ថវិកាច្រើន ដូចដែលបានបញ្ជាក់នៅក្នុងសេចក្តីណែនាំលេខ០២០។ កម្មសិទ្ធិដីឯកជន ជាលទ្ធផលរបស់បទបញ្ជា០១បប ប្រហែលជានឹងអាចបង្កឲ្យការបាត់បង់ដីធ្លីកាន់តែកើនឡើង ជាពិសេសនៅក្នុងភូមិដែលមានប្រជាជនភាគច្រើនបានចុះបញ្ជីដីជាកម្មសិទ្ធិឯកជន ក្នុងកំឡុងពេលអនុវត្តបទបញ្ជា០១បប ហើយ ក្រុមហ៊ុនបានកាត់យកដីសមូហភាពរបស់សហគមន៍កាន់តែច្រើន។

ម្យ៉ាងទៀត ប្រជាជនភូមិ ក៏បានទទួលបទពិសោធន៍រងនូវសម្ពាធពីក្រុមហ៊ុនហើយដែរ ដំណើរការនៃបទបញ្ជា០១បប បានបង្កើតជាសម្ពាធធំសម្រាប់អ្នកភូមិ។ គោលនយោបាយនេះ បានបង្ខំសហគមន៍ឲ្យធ្វើការសំរេចចិត្តយ៉ាងឆាប់រហ័ស ក្នុងការចុះបញ្ជីដីរបស់ពួកគាត់ និងដោះស្រាយជម្លោះដ៏ស្មុគស្មាញជាមួយក្រុមហ៊ុនដែលមានអំណាចជាង ដែលការធ្វើបែបនេះបានបង្កជាការខ្វែងគំនិតគ្នា នៅក្នុងសហគមន៍ជនជាតិដើមភាគតិច និងធ្វើឲ្យទំនាស់ដីធ្លីនៅតែបន្ត។ ក្រុមនិស្សិតស្ម័គ្រចិត្ត បានស្នាក់នៅក្នុងភូមិតែរយៈពេលមួយខែប៉ុណ្ណោះ ដែលរយៈពេលនេះ មិនគ្រប់គ្រាន់សម្រាប់អ្នកភូមិ ធ្វើការសំរេចចិត្តឲ្យឯកភាពចំពោះការចុះបញ្ជីដីរបស់ពួកគាត់ និងដោះស្រាយជម្លោះជាមួយក្រុមហ៊ុនទេ។

ការផ្តល់ពត៌មានមិនច្បាស់លាស់ និងកង្វះតម្លាភាព ទាក់ទងនឹងបទបញ្ជា០១បប កម្មសិទ្ធិដីឯកជន និងកម្មសិទ្ធិដីសមូហភាព ក្នុងកំឡុងពេលនៃដំណើរការចុះបញ្ជីដីធ្លី ក៏បានបង្កឲ្យប្រជាជនភូមិ មិនពេញចិត្តនឹងគោលនយោបាយនេះដែរ។ បទបញ្ជា០១បប មិនមានគោលបំណងច្បាស់លាស់ពីដំនាក់កាលដំបូង ក៏ដូចជាការផ្លាស់ប្តូរគោលនយោបាយច្រើនដង។ ការផ្លាស់ប្តូរគោលនយោបាយដែលស្មុគស្មាញ និងកង្វះតម្លាភាព បានធ្វើឲ្យប្រជាជនមិនបានដឹងថាតើ បទបញ្ជា០១បបនឹងប៉ះពាល់យ៉ាងដូចម្តេចទៅលើសុវត្ថិភាពដីរបស់ពួកគេ និងបញ្ហាទំនាស់ជាមួយក្រុមហ៊ុនឯកជន។

ក្រោយមក ពត៌មានមិនច្បាស់ ក៏បានផ្សព្វផ្សាយក្នុងពេលអនុវត្តបទបញ្ជា០១បប។ ប្រជាជនជនជាតិដើមភាគតិច មិនបានទទួល ពត៌មានឲ្យបានពេញលេញ ថាការកំណត់ព្រំប្រទល់ដីរបស់បទបញ្ជា០១បប នឹងមិនរួមបញ្ចូលដីសហគមន៍ទេ ដែលនេះបង្កឲ្យមានការភ្ញាក់ផ្អើលពេលដែលលទ្ធផលវាស់ដីត្រូវបានបិទផ្សាយ។ សហគមន៍ត្រូវបានគេប្រាប់ថា កម្មសិទ្ធិឯកជន អាចប្តូរជាកម្មសិទ្ធិសមូហភាពបាន យ៉ាងស្រួលនាពេលក្រោយ ទោះបីជាចំណុចនេះនៅមានលក្ខណៈមិនច្បាស់នៅឡើយ។ លទ្ធផលវាស់ដីត្រូវបានបិទផ្សាយសម្រាប់តែរយៈពេលមួយខែប៉ុណ្ណោះ ហើយអ្នកភូមិដែលមិនពេញចិត្ត មិនដឹងច្បាស់ថាត្រូវយល់ព្រម ឬបដិសេធនឹងកម្មសិទ្ធិដីឯកជន បើសិនជាពួកគាត់ចង់បន្ត ដើម្បីទទួលបានកម្មសិទ្ធិដីសមូហភាព។

សមាជិកសហគមន៍បាននិយាយថាមិនពេញចិត្ត ដោយសារថានិស្សិតស្ម័គ្រចិត្ត និងអជ្ញាធរមូលដ្ឋានបានគំរាមកំហែង និងបង្ខិតបង្ខំពួកគាត់ ក្នុងដំនាក់កាលអនុវត្តបទបញ្ជា០១បប។ អ្នកភូមិបានទទួលពត៌មានថា ដីធ្លីរបស់ពួកគាត់នឹងប្រគល់ឲ្យរដ្ឋាភិបាល ឬក្រុមហ៊ុនវិញ បើសិនជាពួកគាត់មិនយល់ព្រមទទួលយកកម្មសិទ្ធិឯកជន ហើយមន្ត្រីរដ្ឋាភិបាលបានបញ្ជាក់ថា ពួកគេមិនអាចដោះស្រាយទំនាស់របស់អ្នកភូមិនាពេលអនាគតទេ បើសិនអ្នកភូមិជ្រើសរើសមិនចូលរួមក្នុងការអនុវត្តបទបញ្ជា០១បប។

ដូចដែលលទ្ធផលនៃការស្រាវជ្រាវនេះបានបង្ហាញ បទបញ្ជា០១បបបានបង្កជាបញ្ហាជាច្រើនដែលប៉ះពាល់ដល់ជនជាតិដើមភាគតិច និងដីធ្លីរបស់គេ នៅខេត្តរតនគីរី។ ជនជាតិដើមភាគតិច អង្គការក្រៅរដ្ឋាភិបាល និងមន្ត្រីរដ្ឋាភិបាលថ្នាក់មូលដ្ឋាន រំពឹងថាការប៉ះពាល់នៃគោលនយោបាយ ដូចដែលបានអនុវត្តនាពេលបច្ចុប្បន្ននេះ នឹងបណ្តាលឲ្យបាត់បងដី ការចិញ្ចឹមជីវិត អត្តសញ្ញាណ និងវប្បធម៌របស់ជនជាតិដើម

ភាគតិច។ ឯកជនភាវូបនីយកម្មដីធ្លី គឺមិនសមស្របសម្រាប់ជនជាតិដើមភាគតិចទេ។ នាពេលបច្ចុប្បន្ននេះ ពេលដែលគ្រួសារជនជាតិដើមភាគតិច ទទួលបានកម្មសិទ្ធិដីឯកជន ក្រុមហ៊ុនអាចឈូសឆាយដីកម្មសិទ្ធិសមូហភាពរបស់សហគមន៍ បានយ៉ាងងាយស្រួល និងដាក់សម្ពាធដល់ ប្រជាជនភូមិឲ្យលក់ដីឯកជនឲ្យគេ។ ការបាត់បង់ដីសមូហភាព របស់ជនជាតិដើមភាគតិច នឹងបង្កឲ្យមានការបាត់បង់ការចិញ្ចឹមជិវិត ហើយដីច្រើនបំផុតត្រឹមប្រាំហិកតា មិនមែនជាដីគ្រប់គ្រាន់ ទោះជាសម្រាប់ វិធីធ្វើកសិកម្មរបស់ប្រជាជនធម្មតា មិនមែនជនជាតិដើមភាគតិចក៏ដោយ។ គ្រួសារជនជាតិដើមភាគតិចភាគច្រើន ទទួលបានដីតិចជាងប្រាំហិកតា។

បទបញ្ជានេះ ក៏បានបង្កើនភាគស្មុកស្មាញផ្នែកគតិយុត្តិ និងការច្របូកច្របល់ ចំពោះសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិចដែរ។ ចាប់ពីចេញបទបញ្ជា០១បបដំបូង ការផ្លាស់ប្តូរជាច្រើនដង ដោយគ្មានតម្លាភាព និងមានការប៉ះទង្គិចនានា បានបង្កឲ្យមានការយល់ខុស ពីសំណាក់ជនជាតិដើមភាគតិច និងភាគគីពាក់ព័ន្ធផ្សេងទៀត។ ការខ្វះភាពសម្របនៃបទបញ្ជា ទៅនឹងបទដ្ឋានគតិយុត្តិដែលមានហើយ ក៏ធ្វើឲ្យសិទ្ធិជនជាតិដើមភាគតិចស្ថិតនៅក្រោមច្បាប់ និងលើកដំកើនការទាមទាររបស់ក្រុមហ៊ុន ចំពោះដីដែលបានជួលដោយរំលោភសិទ្ធិក្នុងការរក្សាប្រពៃណីរបស់ជនជាតិដើមភាគតិចដែរ។

ក្រោយពេលក្រុមនិស្សិតស្ម័គ្រចិត្តបានចាកចេញទៅ ជម្លោះដីធ្លី រវាងក្រុមហ៊ុន និងជនជាតិដើមភាគតិចក៏បានបន្ត និងក្លាយជាធ្ងន់ឡើង។ សហគមន៍ជនជាតិដើមភាគជាច្រើន បានត្រូវគេចុះវាស់សម្រាប់កម្មសិទ្ធិឯកជន យោងទៅតាមផែនទីសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ទោះបីជាប្រជាជនភូមិ មិនទាន់បានសម្រេចការប្តឹងនឹងក្រុមហ៊ុនក៏ដោយ ចំពោះភាពត្រឹមត្រូវរបស់ព្រំប្រទល់ក្នុងផែនទីនោះ។ ជាមួយនឹងការបណ្តុះបណ្តាលមូលដ្ឋានដ៏តិចតួច និងផែនទីសម្បទានដីសេដ្ឋកិច្ច ក្រុមនិស្សិតស្ម័គ្រចិត្តខ្វះបទពិសោធន៍ និងធនធាន ដើម្បីដោះស្រាយទំនាស់ដ៏ស្មុគស្មាញនេះ។ ប្រជាជនដែលទទួលកម្មសិទ្ធិដីឯកជននិយាយថាពួកគេនឹងបន្តប្រើប្រាស់ដីសមូហភាព ក្នុងកំឡុងពេលដែលការប្តឹងតវ៉ារបស់គេនៅតុលាការប្រឆាំងនឹងក្រុមហ៊ុនមិនទាន់បានសម្រេច។ ជាមួយនឹងជម្លោះកាន់តែខ្លាំងឡើងៗ ក្រុមហ៊ុនបានឈូសឆាយយកដីសមូហភាពរបស់សហគមន៍កាន់តែច្រើនឡើង ពិសេសក្រោយពេលដំណើរការផ្តល់កម្មសិទ្ធិរបស់បទបញ្ជា០១បបបានបញ្ចប់។

ដូចដែលពត៌មានប្រមូលបានពីជនជាតិដើមភាគតិចនៅខេត្តរតនគីរីបានបង្ហាញ បទបញ្ជា០១បបបានបង្កជាបញ្ហានានា និងធ្វើឲ្យជនជាតិដើមភាគតិចទទួលរងការប៉ះពាល់រួចហើយ។ របាយការណ៍សិក្សាស្រាវជ្រាវនេះ នឹងត្រូវចែកចាយនិងបោះផ្សាយ ដើម្បីផ្សព្វផ្សាយពីការព្រួយបារម្ភ របស់ជនជាតិដើមភាគតិច ដែលរងការប៉ះពាល់ និងលើកទឹកចិត្តរដ្ឋាភិបាលឲ្យធ្វើការកែទំរង់គោលនយោយ ដើម្បីដោះស្រាយការព្រួយបារម្ភទាំងនោះ។

## II. ជីវប្រវត្តិ

### ១–ជនជាតិដើមភាគតិចខេត្តរតនគីរី[2]

ពីរភាគបីនៃជនជាតិដើមភាគតិចនៅប្រទេសកម្ពុជា រស់នៅភូមិភាគឥសានដូចជា ក្នុងខេត្តរតនគីរី និង ខេត្តមណ្ឌលគីរី។ ទោះបីជាគេស្គាល់ជាតិដើមជាភាគតិចច្បាស់ ប៉ុន្តែជនជាតិដើមភាគតិចមានចំនួនច្រើនជាងគេនៅខេត្តរតនគីរី។ ក្រុមជនជាតិដើមភាគតិចជាច្រើនក្រុម រស់នៅផ្តុំគ្នា នៅភាគឥសានប្រទេសកម្ពុជា។ ក្រុមជនជាតិដើមភាគតិចខេត្តរតនគីរី រួមមាន ព្រៅ ចារាយ កាចុក គ្រឿង ទំពុន លុន ការ៉េត និង ផ្សេងទៀត។ ក្នុងចំណោមភូមិប្រមាណ២៤០ភូមិ ជនជាតិដើមភាគតិចខេត្តរតនគីរី មានប្រជាជនប្រហែល ២០០ ឬ ៣០០ រយនាក់ក្នុងមួយភូមិ ដែលដឹកនាំដោយមេភូមិនិងក្រុមប្រឹក្សាមួយក្រុម។

### ការគ្រប់គ្រងធនធានធម្មជាតិ

ជនជាតិដើមភាគតិចស្ទើតែទាំងអស់ ពឹងផ្អែកលើដីធ្លីដើម្បីចិញ្ចឹមជីវិត បន្តវប្បធម៌ ប្រពៃណី ជំនឿ និង ទំនៀមទំលាប់ផ្សេងៗរបស់គេ។ ដីជាគ្រឹះនៃការចិញ្ចឹមជីវិត ការរៀបចំសង្គម និងអត្តសញ្ញាណជនជាតិដើមភាគតិច។ ទោះបីលក្ខខ័ណ្ឌថ្មីៗនានា កំពុងផ្លាស់ប្តូររបៀបរស់នៅ របស់ជនជាតិដើមភាគតិចខេត្តរតនគីរីក៏ដោយ ក៏ដីធ្លីបានត្រូវគេប្រើប្រាស់តាំងពីបុរាណមកជាប្រាំយ៉ាង÷ដីធ្លីសម្រាប់គ្រួសារ កសិកម្មតាមបែបពនាចរ(ផ្ទាល់ខ្លួនឬរួមគ្នា) ការប្រមូលអនុផលព្រៃឈើ ព្រៃអារក្ស ព្រៃបញ្ចុះសព ព្រមទាំងការប្រើប្រាស់ជាលក្ខណៈសង្គម ទំនៀមទំលាប់ ប្រពៃណី និងវប្បធម៌ផ្សេងទៀត។

ព្រៃអារក្ស ជាមូលដ្ឋានគ្រឹះនៃសាសនារបស់សហគមជនជាតិដើមភាគតិច។ ច្បាប់នៃការគ្រប់គ្រងដី និងការចូលប្រើប្រាស់ដីត្រូវបានកំណត់ដោយព្រៃអារក្ស ដែលគេហៅថា អ្នកតា ស្របនឹងចំណេះដឹងអ្នកស្រុកជនជាតិដើមភាគតិច។ អ្នកតាជាព្រលឹងនៃព្រៃអារក្ស និង តំបន់ផ្សេងៗទៀតក្នុងភូមិ ហើយនឹងដាក់ទោសដល់ជនណាដែលបំពានឬ ឈានជើងចូលព្រំដែនរបស់គេ ដោយគ្មានការអនុញ្ញាត។ការធ្លាក់ខ្លួនឈឺ ឬសំណាងអាក្រក់ ដែលកើតមានចំពោះសហគមន៍មួយ គឺចាត់ទុកថា មកពីអ្នកតា។ ពិធីបូជាយញ្ញ និងពិធីផ្សេងៗ ត្រូវបានប្រារព្ធឡើង សម្រាប់អ្នកតា នៅគ្រប់ដំណាក់កាលនៃការធ្វើកសិកម្ម មុនពេលបុកដី ពេលស្ទូង និងពេលប្រមូលផល។ ទីបញ្ចុះសពដ៏ស័ក្តិសិទ្ធិនៅក្នុងព្រៃ ត្រូវបានប្រើប្រាស់សម្រាប់បញ្ចុះសព។ ដីស័ក្តិសិទ្ធិទាំងនេះ ក៏ត្រូវបានប្រើប្រាស់ជាប្រវតិសាស្រ្តកំណត់ទីតាំង កន្លែងរបស់បុព្វបុរសសហគមន៍ និងការចិញ្ចឹមជីវិតតាមបែបបុរាណ។

[2] ទោះជាមានការបញ្ជាក់ក៏ដោយ ផ្នែកនេះត្រូវបានផ្អែកលើព័ត៌មានពីជនជាតិដើមភាគតិចនិងអង្គការក្រៅរដ្ឋាភិបាល។ សូមមើលផងដែរ គោលនយោបាយជាតិរបស់រាជរដ្ឋាភិបាលស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិចនៃឆ្នាំ 2009; របាយការណ៍ប្រជាជនជនជាតិដើមភាគតិចនិងសិទ្ធិមនុស្សឆ្នាំ 2006; Colm ឆ្នាំ 1997; OHCHR ឆ្នាំ 2012; OHCHR ឆ្នាំ 2004 ។

ដំណាក់កាលនៃការធ្វើកសិកម្ម របស់សហគមន៍ជនជាតិដើមភាគតិច ត្រូវបានធ្វើឡើងជុំវិញការប្រើប្រាស់ដីតាមបែបពនាចរ ឬ វិលជុំ និងមានការបុកដី។ នៅរដូវប្រាំង សហគមន៍ទាំងអស់កាប់ល្បះ និងឈូសឆាយដីពនាចរ ដោយដុតព្រៃ និងដើមឈើតូចៗ។ ចំការត្រូវបានដាំដុះ រួចទុកឲ្យទំនេរ រហូតដល់ដីមានជីជាតិម្តងទៀត ពេលដែលរឹះឈើចាក់ជ្រៅ និងដើមឈើមានផ្លែ នាំមកនូវជីជាតិដល់ផ្ទៃលើនៃដី។ ដីកសិកម្មពនាចរទាំងនេះ ជាកម្មសិទ្ធិរបស់គ្រួសារ ឬ ជាកម្មសិទ្ធិរួមរបស់សហគមន៍។ គ្រួសារនីមួយៗ មានដីប្រមាណបី ទៅប្រាំដុះ សម្រាប់វិលជុំគ្នា ដែលមានប្រហែល មួយទៅពីរហិចតា មួយជុំៗ។ ដូច្នេះដីវិលជុំអាចមានដល់ប្រាំមួយហិចតា។

អ្នកភូមិទំលាប់ប្រើប្រាស់ដីទាំងនេះ ដើម្បីធ្វើស្រែ ដាំដំឡូងឈើ ត្រាវ អំពៅ ពោត ដំឡូង ដំឡូងស្វា ត្រឡាច សណ្តែក ម្ទេសផ្លោក ល្ង ថ្នាំជក់ ម្នាស់ ត្រប់ ប៉េងប៉ោះ ល្ពៅ ត្រសក់ និងដើមឈើហូបផ្លែផ្សេងៗទៀត។ តំបន់ព្រៃឈើ ក៏បានត្រូវប្រើប្រាស់តាមបែបបុរាណ ដើម្បីប្រមូលអនុផលព្រៃឈើ ទោះបីជាការអនុវត្តបែបនេះ ត្រូវបានកាត់បន្ថយជាច្រើនក៏ដោយ ដោយទុកឲ្យព្រៃឈើស្តារឡើងវិញ។ អនុផលព្រៃឈើរួមមានថ្នាំបុរាណ ចំណីសត្វ ជីសម្រាប់ការដាំដុះ អាហារបន្ថែមដូចជា ផ្សិត ជ័រឈើ ទឹកឃ្មុំ អុស ផ្តៅ ឬស្សីរុក្ខជាតិស្មៅ ផ្លែឈើ និងរុក្ខជាតិផ្សេងៗទៀត។ ព្រៃឈើ ក៏ផ្តល់ជាប្រភពទឹក និងជាជំរក សម្រាប់ការនេសាទ និងការបរបាញ់ ក្នុងការបន្ថែមអាហារ និងបង្កើនចំណូលគ្រួសារ។

ការផ្លាស់ប្តូរជាច្រើន បានកើតឡើងនៅក្នុងសហគមន៍ជនជាតិដើមភាគតិច នាប៉ុន្មានឆ្នាំចុងក្រោយនេះ។ ការប្រើប្រាស់ដីទំនេរបានថយចុះ ស្របនឹងព្រៃឈើគម្រប ក៏ដូចជាប្រពៃណី ការធ្វើកសិកម្មជាប្រព័ន្ធស្របនឹងសិទ្ធិរបស់គ្រួសារក្នុងការលក់ដំណាំ ដូចជាស្វាយចន្ទី។

ជនជាតិដើមភាគតិច ដាំដំណាំសម្រាប់លក់នៅលើដីទំនេរ ដើម្បីបង្កើនចំណូលគ្រួសារ និងបោះបង្គោលចំណាំដី និង បញ្ចាសការយកដីពីអ្នកខាងក្រៅ។ យើងមិនអាចដឹងបាន ពីចំនួនដំណាំដែលដាំសម្រាប់លក់ដោយជនជាតិដើមភាគតិចទេ ប៉ុន្តែការកើនឡើងនៃការដាំដុះ បាននាំឲ្យខេត្តរតនគីរីក្លាយជាខេត្តនាំមុខគេប្រចាំប្រទេសខាងដំណាំស្វាយចន្ទី[3]។ ទោះបីជាដំណាំសម្រាប់លក់ បានកើនឡើង និងផ្តល់ចំណូលចំបងសម្រាប់គ្រួសារក៏ដោយ ក៏ជនជាតិដើមភាគតិច នៅតែបន្តអនុវត្តកសិកម្មពនាចរដូចមុន។

## ស្ថានភាពសេដ្ឋកិច្ចនិងសង្គម

ស្របនឹងការហូរចូលនៃការដាំដំណាំសម្រាប់លក់ ជនជាតិដើមភាគតិចបានទទួលរងនូវការខូចខាតដីកាន់តែកើនឡើង និងសម្ពាធនៃពាណិជ្ជកម្ម។ ការសន្និដ្ឋានបង្ហាញថា យ៉ាងហោយណាស់ ដីដាំដុះពាក់កណ្តាលនៅប្រទេសកម្ពុជា និង មួយភាគដប់នៃផ្ទៃដីសរុបទាំងអស់ ត្រូវបានប្រគល់ឲ្យក្រុមហ៊ុនបរទេស ក្នុងទំរង់ជាសម្បទានដីសេកិច្ច ដើម្បីបង្កើតគម្រោងកសិឧស្សាហកម្មដំណាំ ដូចជាកៅស៊ូ ដំឡូង

[3] សូមមើល Padwe 2011; Baird 2008.

ឈើ និងសណ្តែក ច្រើនជាងគេគឺ កៅស៊ូ[4]។ រាជរដ្ឋាភិបាលកម្ពុជា ក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ចដល់ក្រុមហ៊ុន នៅថ្នាក់ជាតិ និងក្រុមហ៊ុនតែងតែប្រមូលដី ដោយគ្មានធ្វើការវាយតំលៃផលប៉ះពាល់បរិដ្ឋាននិងសង្គមទេ[5]។ ក្រុមហ៊ុនភាគច្រើន បានរំលោភលើដីរបស់ជនជាតិដើមភាគតិច[6]។

អ្នកវិនិយោគ បានប្រមូលដីជនជាតិដើមភាគតិចបន្តិចម្តងៗ តាមរយៈទំរង់សម្បទានដីសេដ្ឋកិច្ចទ្រង់ទ្រាយធំ ក៏ដូចជាការលក់ដីទ្រង់ទ្រាយតូច។ លុយនិងអំណាយ ត្រូវបានប្រើដើម្បីទិញដីចំការ ក្នុងតំលៃទាប ឬ បញ្ឆោតនិងបង្ខំជនជាតិដើមភាគតិច ឲ្យចេញពីដីពួកគេ[7]។ សហគមន៍ភាគច្រើន បានបាត់បង់ដីពីដូនតាពួកគេស្ទើរតែទាំងអស់ ដែលនេះជាលទ្ធផលនៃសម្ពាធរួមផ្សំ[8]។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសថ្មីៗនេះថា ភូមិភាគឥសាន ជា“តំបន់សេដ្ឋកិច្ចទីបួន” ដោយយោងទៅលើសមត្ថភាពរបស់តំបន់ក្នុងការអភិវឌ្ឍកសិកម្ម ហើយខេត្តរតនគីរីត្រូវគេបានស្គាល់ជា “ព្រំដែនថ្មី” សម្រាប់ការដាំដំណាំកសិឧស្សាកម្ម ការសាងសង់ទំនប់វារីអគ្គិសនី និងការកាប់ឈើលើដីសម្បទាន ព្រមទាំងគេស្មើរថា ទំនោរនៃការបាត់បង់ខូចខាតដី របស់ជនជាតិដើមភាគតិចខេត្តរតនគីរី នឹងបន្តទៅមុខទៀត[9]។

ជនជាតិដើមភាគតិច ត្រូវបានគេទទួលស្គាល់ ជាក្រុមប្រជាជនក្រីក្រជាងគេបំផុតនៅក្នុងប្រទេស ដោយរាជរដ្ឋាភិបាលកម្ពុជា និង ក្រុមអន្តរជាតិនានា មួយផ្នែកមកពីការបាត់បង់ដីរបស់ពួកគេ ការរស់នៅដាច់ឆ្ងាយពីគេ និងមានភាសានិងវប្បធ៌មខុសពីគេ[10]។ ការទទួលបានសេវាអប់រំ សុខភាព និងហេដ្ឋារចនាសម្ព័ន គឺតែងតែទាបជាងក្រុមមិនមែនជនជាតិដើមភាគតិច។ ដោយឆ្លងកាត់ការលំបាកវេទនាជាច្រើនទសវត្សរ៍ សហគមន៍ជនជាតិដើមភាគតិចភាគច្រើន រក្សាបាននូវភាសាជាវប្បធម៌ និងមរតករបស់ពួកគេ។

## ២–ការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពនិងបទបញ្ញា០១បប

សម្បទានដីសេដ្ឋកិច្ច និងការដកហូតដីរបស់ជនជាតិដើមភាគតិច បានបង្កឲ្យមានជាទំនាស់ដីធ្លីដ៏ធំ និងការបាត់បង់ដីរបស់ជនជាតិដើមភាគតិចក្នុងខេត្តរតនគីរី។ ការអភិវឌ្ឍរបស់រាជរដ្ឋាភិបាលកម្ពុជាមានបំណងចង់ដោះស្រាយទំនាស់ទាំងនេះ ដូចជាតាមរយៈការបង្កើតការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពនៅឆ្នាំ២០០១ក្នុងច្បាប់ភូមិបាល។ ការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាព បានជួយជនជាតិដើមភាគតិច ក្នុង

---

[4] OHCHR 2012.

[5] មន្ត្រីថ្នាក់ក្រោមជាតិ រួមមានក្រុមប្រឹក្សាខេត្តរតនគីរី ទទួលស្គាល់ថាមានការខ្វះការវាយតំលៃផលប៉ះពាល់បរិដ្ឋាននិងសង្គមរបស់ក្រុមហ៊ុនជាបញ្ហាសំខាន់មួយ។

[6]សូមមើល Lewis.

[7]សូមមើល Baird.

[8]សូមមើល ឌ. Reaksmey; Oxfam; OHCHR 2007.

[9]សូមមើលPheaktra.

[10]សូមមើល OHCHR 2012; សូមមើលផែនការជាតិដើម្បីអភិវឌ្ឍជនជាតិដើមភាគតិចរបស់រាជរដ្ឋាភិបាលកម្ពុជា

កាបញ្ជាក់កម្មសិទ្ធិដីពីដូនតារបស់ពួកគេ តាមរយៈកម្មសិទ្ធិដីជាសមូហភាពតែមួយ។ ដំណើរការនៃការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាព តម្រូវឲ្យសហគមន៍កំណត់វិន័យក្នុងការគ្រប់គ្រងដីមូលដ្ឋាន ដែលវិធីនេះអាចជួយដោះស្រាយទំនាស់ជាមួយក្រុមហ៊ុន និងកាត់បន្ថយការលក់ដីដោយបង្ខំ។ ក្រោមច្បាប់នេះ រាជរដ្ឋាភិបាលកម្ពុជា ត្រូវធ្វើការជាមួយជនជាតិដើមភាគតិច ដែលចង់ចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាព តាមនិតិវិធីផ្សេងៗ រួមមានធ្វើផែនទីសម្គាល់ទីតាំងដី ការធ្វើស្វ័យអត្តសញ្ញាណ ការវាយតំលៃទទួលស្គាល់ស្វ័យអត្តសញ្ញាណដោយច្បាប់ និងការចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិចជានិតិបុគ្គល[11]។

ចាប់តាំងពីការអនុម័តច្បាប់ភូមិបាល នៅឆ្នាំ២០០១ សហគមន៍ចំនួនប្រាំ បានទទួលកម្មសិទ្ធិដីសមូហភាព ហើយរដ្ឋាភិបាលប្រកាសថា កម្មសិទ្ធិសមូហភាពចំនួនបីទៀត នឹងផ្តល់នៅខែឧសភា។ មានសហគមន៍ប្រមាណ ១២១ កំពុង ស្ថិតក្នុងដំណើរនៃការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាព។ ភូមិចំនួន ៧២បានធ្វើស្វ័យអត្តសញ្ញាណ ហើយនឹងទទួលស្គាល់ស្វ័យអត្តសញ្ញាណដោយក្រសួងអភិវឌ្ឍន៍ជនបទ ហើយភូមិចំនួន ៤៩ទៀត បានត្រូវទទួលស្គាល់ដោយក្រសួងមហាផ្ទៃ ជានិតិបុគ្គល និងកំពុងរងចាំដំណាក់កាលចុងក្រោយ[12]។

កម្មវិធីថ្មីបំផុតរបស់រាជរដ្ឋាភិបាល គឺបទបញ្ជាលេខ០១បប បានបញ្ឈប់រាល់ដំណើរការនៃការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាព និងប្រកាស់ប៉ន់ប៉ងដោះស្រាយទំនាស់ដីធ្លី[13]។ កម្មវិធីថ្មីនេះ អនុញ្ញាតឲ្យក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចទាំងអស់ដែលផ្តល់ហើយ(ក្នុងកន្លែងមានប្រេង)នៅបន្ត ប៉ុន្តែមានការបញ្ឈប់ការផ្តល់សម្បទានដីសេដ្ឋកិច្ចថ្មីទៀត។ បទបញ្ជានេះ ក៏ទាមទារឲ្យក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ញែកដីសហគមន៍ជនជាតិដើមភាគតិច ពីដីដែលប្រគល់ឲ្យក្រុមហ៊ុនកំណត់ក្នុងឯកសារសម្បទានដីសេដ្ឋកិច្ច។ គោលនយោបាយនេះ មិនបានលុបចោលការផ្តល់សម្បទានដីសេដ្ឋកិច្ចទេ ប៉ុន្តែផ្តល់កម្មសិទ្ធិឯកជនដស់គ្រួសារជនជាតិដើមភាគតិច និងបង្កើតជាតំបន់ផ្ទាល់ខ្លួនតូចៗក្នុងតំបន់សម្បទានដីសេដ្ឋកិច្ច។

នៅថ្ងៃទី ៩ ខែកក្កដា ឆ្នាំ ២០១២ រាជរដ្ឋាភិបាលកម្ពុជា បានប្រកាស់គម្រោងមួយ ក្នុងការប្រគល់ដីធ្លី ដល់គ្រួសារដែលរស់នៅក្នុង ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន។ រាជរដ្ឋាភិបាលកម្ពុជា បានជ្រើសរើសនិស្សិតស្ម័គ្រចិត្តរាប់ពាន់នាក់ ផ្តល់ការបណ្តុះបណ្តាលជាមូលដ្ឋានដល់ពួកគេ និងបញ្ជូនពួកគេទៅគ្រប់ខេត្តក្រុង ដើម្បីវាស់វែងដីចែកប្រជាជន។ និស្សិតស្ម័គ្រចិត្តទាំងអស់មានបេសកកម្មពីរៈ(១) វាស់វែងដីដែលមានទំនាស់រវាងសហគមន៍និងក្រុមហ៊ុនឯកជន និង (២) ផ្តល់កម្មសិទ្ធិដីធ្លី (ទោះបីជានៅជំនាក់កាលដំបូងក៏ដោយ ក៏គោលនយោបាយបញ្ជាក់ថាកម្មសិទ្ធិដីសមូហភាពនឹងផ្តល់ឲ្យសហគមន៍[14])។ គោលនយោបាយថ្មីនេះ មានគោលបំណងប្រគល់ចែកចាយយ៉ាងរហ័សនូវកម្មសិទ្ធិដី ប្រមាណ១២លានហិកតា

---

[11]សូមមើលច្បាប់ភូមិបាល២០០១និងអនុក្រិតលេខ៨៣របស់រាជរដ្ឋាភិបាលកម្ពុជា

[12]សូមមើល ILO.

[13]សូមមើល ឧបសម្ព័ន្ធទី១សម្រាប់បទបញ្ជា០១បប

[14]សូមមើល សេចក្តីណែនាំលេខ០១៥ របស់រាជរដ្ឋាភិបាលកម្ពុជា

ដល់ប្រជាជន ៣៥០ ០០០គ្រួសារ ដែលរស់នៅក្នុងតំបន់សម្បទានដីសេដ្ឋកិច្ច ព្រៃសម្បទានសេដ្ឋកិច្ច ឬដីកម្មសិទ្ធិរដ្ឋ។ ចាប់តាំងពីកម្មវិធីវាស់និងចែកដីចាប់ផ្ដើមនៅខែមិថុនា ឆ្នាំ២០១២ ដល់តឡូវ រាជរដ្ឋាភិបាលកម្ពុជា បានប្រគល់កម្មសិទ្ធិដីឯកជនប្រមាណ ១១០០០០ ហើយ[15]។

និស្សិតស្ម័គ្រចិត្តកំណត់ព្រំប្រទល់ដីដែលត្រូវវាស់វែង និងវាស់វែងក្បាលដីជាកម្មសិទ្ធិឯកជនសម្រាប់គ្រួសារ ស្របនឹងបទបញ្ជា និងវាស់តែដីមានទំនាស់ និងផ្ដល់កម្មសិទ្ធិបឋម។ គ្រួសារនីមួយៗ អាចទាមទារដី ច្រើនបំផុត៥ហិកតាសម្រាប់ជាលក្ខណៈឯកជន។ លទ្ធផលនៃការកម្រិតព្រំដី នឹងបិទផ្សាយរយៈពេលមួយខែ ហើយគ្រួសារអាចជ្រើសរើសព្រមទទួល ឬបដិសេធលទ្ធផលកម្រិតព្រំដីលើក្បាលដីមួយក្បាល យោងលើគោលការណ៍ក្បាលដី។ បើសិនជាគ្រួសារនីមួយៗព្រមទទួលលទ្ធផលកម្រិតព្រំដី កម្មសិទ្ធិដីឯកជនមួយ នឹងប្រគល់ជូនគ្រួសារ។ ទោះបីជាគ្រួសារនីមួយៗ ប្រើប្រាស់ដីលើសពីប្រាំហិកតាក៏ដោយ ក៏ពួកគេអាចចុះបញ្ជីបានតែដីដែលមានការដាំដុះ ចំនួនច្រើនបំផុតប្រាំហិកតាប៉ុណ្ណោះ។ ដីដែលនៅទំនេរ គ្មានដំណាំនឹងមិនត្រូវបានផ្ដល់កម្មសិទ្ធិឲ្យទេ។ បើសិនជាគ្រួសារនីមួយៗ ចង់បានកម្មសិទ្ធិដីលើសពីប្រាំហិកតា ពួកគេត្រូវព្យាយាម ចុះបញ្ជីជាដីសម្បទានសេកិច្ចទ្រង់ទ្រាយតូច សម្រាប់រយៈពេលមិនលើសពី ៩៩ឆ្នាំ ប៉ុន្តែពួកគេអាចប្រើប្រាស់ដីបាន ក្នុងគោលបំណងកសិកម្មនិងពាណិជ្ជកម្មប៉ុណ្ណោះ[16]។

បទបញ្ជា ០១បប បានផ្លាស់ប្ដូរក្នុងកំឡុងពេលដំនាក់កាលចុះវាស់ដី ដោយមានបន្ថែមសេចក្ដីណែនាំជាច្រើន ឬបទបញ្ជាផ្សេងៗទៀត។ គោលនយោបាយនេះ មានគោលបំណងដំបូង ក្នុងការប្រគល់ដីមានជម្លោះជាមួយក្រុមហ៊ុន ទៅឲ្យជនជាតិដើមភាគតិចវិញ[17] ប៉ុន្តែសេចក្ដីណែនាំលេខ០២០ បានបញ្ជាក់ថា ដីព្រៃដែលជនជាតិដើមភាគតិចប្រើប្រាស់សម្រាប់ប្រមូលអនុផលព្រៃឈើ កសិកម្មពនាចរ និងក្នុងបំណងប្រពៃណីនិងវប្បធម៌ មិនគួរដាក់ឲ្យមានកម្មសិទ្ធិទេ[18]។ បទបញ្ជា ០១បប បានអះអាងថាការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពក្នុងដំណើរការ នឹងត្រូវផ្ដល់តំលៃ ប៉ុន្តែសេចក្ដីណែនាំលេខ០២០បានបញ្ឈប់រាល់ដំណើរការនៃការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាព ដែលពេលនោះបទបញ្ជា ០១បប បាននឹងកំពុងអនុវត្ត[19]
។

សេចក្ដីណែនាំលេខ០១៥ បញ្ជាក់ថា ប្រជាជនអាចផ្លាស់ប្ដូរពីកម្មសិទ្ធិឯកជនទៅកម្មសិទ្ធិសមូហភាពបាន ប៉ុន្តែគោលនយោបាយ និងច្បាប់មានលក្ខណៈប្រឆាំងគ្នានិងមិនច្បាស់លាស់[20]។ ការផ្ដួចផ្ដើមមួយក្នុងចំណោមការផ្ដួចផ្ដើមផ្សេងៗ សម្រាប់ដំនាក់កាលការធ្វើស្វ័យអត្តសញ្ញាណ ក្នុងកំឡុងការពេលចុះ

---

[15]សូមមើល Woods &Bopha.

[16] សូមមើល សេចក្ដីណែនាំលេខ៦៦៦ របស់រាជរដ្ឋាភិបាលកម្ពុជា

[17] សូមមើល សេចក្ដីណែនាំលេខ០១៥ របស់រាជរដ្ឋាភិបាលកម្ពុជា

[18] សូមមើល សេចក្ដីណែនាំលេខ០២០ របស់រាជរដ្ឋាភិបាលកម្ពុជា

[19] សូមមើល សេចក្ដីណែនាំលេខ០២០ របស់រាជរដ្ឋាភិបាលកម្ពុជា

[20]សូមមើល សេចក្ដីណែនាំលេខ០១៥ របស់រាជរដ្ឋាភិបាលកម្ពុជា

បញ្ជីដីជាកម្មសិទ្ធិសមូហភាព តម្រូវឲ្យសហគមជនជាតិដើមភាគតិចប្រើប្រាស់ដីតាមបែបបុរាណ ដែលគ្រួសារនីមួយៗមិនអាចធ្វើបែបនេះបានជាមួយក្បាលដីឯកជនទេ[21]។ ក្នុងពេលជាមួយគ្នា មន្ត្រីរដ្ឋាភិបាលបាននិយាយថា អាចមានលទ្ធភាពសម្រាប់ជនជាតិដើមភាគតិច ក្នុងការផ្លាស់ប្តូរពីកម្មសិទ្ធិឯកជនទៅកម្មសិទ្ធិសមូហភាព ទោះជាដំណើរការនេះមិនត្រូវបានលើកឡើងក្នុងសេចក្តីណែនាំក៏ដោយ។

## ៣–ក្រុមការងារដែលធ្វើការលើចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពខេត្តរតនគីរី

(Ratanakiri CLT Working Group)

នៅខែកក្កដាឆ្នាំ២០១២ អង្គការក្រៅរដ្ឋាភិបាលនៅក្នុងខេត្តរតនគីរីដែលធ្វើការលើការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាព បានទទួលលិខិតដែលចេញដោយសាលាខេត្ត ក្នុងលិខិតនេះបានលើកឡើងពីឈ្មោះភូមិចំនួន៣១ដែលអាចស្ថិតក្នុងគោលនយោបាយការចុះវាស់ដីរបស់ក្រុមនិស្សិតស្ម័គ្រចិត្ត។ លិខិតមួយនេះ មិនបានលើកឡើងពីសេចក្តីណែនាំពិសេសអ្វីទេ ប៉ុន្តែបានសូមអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការលើការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាព ឲ្យស្តាប់ការបង្គាប់របស់អាជ្ញាធរមូលដ្ឋាន ទាក់ទឹងគោលនយោបាយ។ ក្នុងការប្រជុំមួយដែលធ្វើឡើងក្រោយមួយខែ មន្ត្រីរដ្ឋាភិបាលបានបង្គាប់ឲ្យអង្គការក្រៅរដ្ឋាភិបាលបញ្ឈប់ភូមិទាំង៣១ពីផែនការរបស់ខ្លួន រហូតដល់ក្រោយពេលក្រុមនិស្សិតស្ម័គ្រចិត្តចុះវាស់វែងដីចាកចេញទៅដើម្បីបញ្ជាសជម្លោះផលប្រយោជន៍ជាមួយក្រុមនិស្សិតស្ម័គ្រចិត្ត។ ដំណើរការនៃការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពត្រូវបានបញ្ឈប់ទាំងស្រុង ក្នុងពេលដែលក្រុមនិស្សិតស្ម័គ្រចិត្តចុះមក បំពេញបេសកកម្ម។

ក្រៅពីភូមិទាំង៣១ដែលលើកឡើងក្នុងលិខិត ភូមិចំនួន១៦ជាភូមិដែលអង្គការក្រៅរដ្ឋាភិបាលបានសហការជាមួយ លើការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាព។ ដូច្នេះអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការលើការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាព ទទួលស្គាល់ថាបទបញ្ជាលេខ០១បប បានធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងចំពោះការខំប្រឹងប្រែងក្នុងការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាព ប្រហែលជាប៉ះពាល់ដល់ការខំប្រឹងប្រែងជាច្រើនឆ្នាំរបស់ភូមិទៀត។ ដើម្បីដោះស្រាយបញ្ហានេះ នៅខែកញ្ញាឆ្នាំ២០១២ អង្គការក្រៅរដ្ឋាភិបាលដែលធ្វើការលើការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាព នៅខេត្តរតនគីរី ដែលធ្វើការលើការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាព បានបង្កើតជា**ក្រុមការងារដែលធ្វើការលើចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពខេត្តរតនគីរី** ។

គំនិតផ្តួចផ្តើមទីមួយរបស់ក្រុមការងារ ដែលធ្វើការលើចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពខេត្តរតនគីរី គឺប្រមូលពត៌មាន ពីភូមិគោលដៅ ដើម្បីយល់ឲ្យកាន់តែច្បាស់ពីផលប៉ះពាល់របស់បទបញ្ជាលេខ០១បប និងចងក្រងពត៌មានជារបាយការណ៍រួមនេះ ដើម្បីអាចចែករំលែក ពត៌មានជាមួយរាជរដ្ឋាភិបាលកម្ពុជា សង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ថ្នាក់ជាតិនិងថ្នាក់អន្តរជាតិនានា។

---

[21]ពត៌មានពី ILO និង CLEC.

## III. វិធីសាស្រ្ត

ការសិក្សាស្រាវជ្រាវ បានធ្វើឡើងពីខែមករាដល់ខែកុម្ភៈ ឆ្នាំ២០១៣ ក្នុងលក្ខណៈតម្លាភាពនិងមានការចូលរួម។ ការសិក្សាស្រាវជ្រាវ បានធ្វើឡើង ចំពោះសហគមន៍ជនជាតិដើមភាគតិចចំនួន៧៩ ៖ ២៦ ក្នុងចំណោមនោះ បានទទួលរងផលប៉ះពាល់ពីបទបញ្ជាលេខ០១បប។ អង្គការក្រៅរដ្ឋាភិបាលបានប្រមូលពីសហគមន៍ទាំង៧៩ នូវពត៌មានដែលទាក់ទងនឹងប្រជាជនភូមិ បញ្ហានានាដែលមានជាមួយក្រុមហ៊ុន ដំនាក់កាលនៃការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាព(បើមាន) និង សួរថាតើភូមិបានទទួលរងការប៉ះពាល់ពីបទបញ្ជាលេខ០១បបរឺទេ។

អង្គការក្រៅរដ្ឋាភិបាល បានប្រមូលពត៌មានបន្ថែម តាមរយៈការប្រជុំពិគ្រោះយោបល់ផ្សេងៗ និងមានកំរងសំណួរ មកពី ភូមិទាំង២៦ ដែលបានទទួលរងការប៉ះពាល់ពីបទបញ្ជាលេខ០១បប។ កំរងសំណួរត្រូវបានបំពេញ ដោយមេភូមិនិងចាស់ទុំ ក្នុងភូមិចំនួនចំនួន១២ ក្នុងចំណោមភូមិទាំង២៦ ដែលបានទទួលរងការប៉ះពាល់ពីបទបញ្ជាលេខ០១បប។

អង្គការក្រៅរដ្ឋាភិបាល បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ នៅក្នុងភូមិដែលទទួលរងការប៉ះពាល់ពីបទបញ្ជាលេខ០១បប នៅបាន់លុង ឬតាមរយៈទូរសព្ទ។ អង្គការបានពិគ្រោះជាមួយបុរស ស្រ្តី រួមទាំងចាស់ព្រឹទ្ធាចារ្យ មេ ភូមិ និងសមាជិកភូមិផ្សេងទៀត។ ការប្រជុំពិគ្រោះយោបល់ខ្លះ មានបញ្ចូលប្រជាជនភូមិដែលមកពីគ្រួសារ ដែលជ្រើសរើសកម្មសិទ្ធិដីឯកជន ព្រមទាំងប្រជាជនភូមិ ដែលមកពីគ្រួសារដែលមិនបានទទួលកម្មសិទ្ធិឯកជន។ ការប្រជុំពិគ្រោះយោបល់និងកំរងសំណួរ ផ្តោតលើបញ្ហាចំបងចំនួនបី៖

១–តើមានគ្រួសារចំនួនប៉ុន្មានដែលបានព្រមទទួលការវាស់វែងដីសម្រាប់កម្មសិទ្ធិឯកជន ក្នុងពេលអនុវត្តបទបញ្ជាលេខ០១បប?

២–ហេតុអ្វីបានជាគ្រួសារទាំងនេះជ្រើសរើសកម្មសិទ្ធិឯកជន?

៣–តើភូមិអ្នកពេញចិត្តនឹងគម្រោងវាស់វែងដីរបស់ក្រុមនិស្សិតស្ម័គ្រចិត្តទេ។

ពត៌មានដែលប្រមូលបានដោយអង្គការក្រៅរដ្ឋាភិបាលទាំងអស់ ត្រូវបានចងក្រង ក្នុងឯកសារតែមួយ។ របាយការណ៍នេះ ជាសេចក្តីសង្ខេប និងជាការវិភាគពត៌មាន របស់សហគមន៍ដែលបានផ្តល់ឲ្យអង្គការក្រៅរដ្ឋាភិបាល នឹងផ្តោតលើពត៌មានដែលបានមកពីអ្នកភូមិ ក្នុងភូមិទាំង២៦ដែលបានសម្ភាសនិងទទួលរងការប៉ះពាល់ពីបទបញ្ជាលេខ០១បប។

អង្គការក្រៅរដ្ឋាភិបាលទាំងអស់ ក៏បានជួបថ្នាក់ឃុំ ស្រុក និងខេត្ត ព្រមទាំងអង្គការអន្តរជាតិនានា ក្នុងពេលធ្វើការស្រាវជ្រាវ ដើម្បីធានាឲ្យបានដំណើរការស្រាវជ្រាវមួយ ដែលមានតម្លាភាព និងការទទួលព

ត៌មានគ្រប់គ្រាន់។ របាយការណ៍ស្រាវជ្រាវនេះ បានបញ្ចូលការបារម្ភចំបងៗ របស់មន្ត្រីរដ្ឋាភិបាល អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល ដែលយើងបានជួបពិគ្រោះយោបល់ជាមួយ។

ក្រុមការងារ ដែលធ្វើការលើចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពខេត្តរតនគីរី បានព្យាយាមធ្វើការដើម្បីផ្តល់ពត៌មានយ៉ាងសុក្រិតបំផុត ក្នុងរបាយការណ៍ ប៉ុន្តែដើម្បីធានាតម្លាភាព យើងក៏ទទួលស្គាល់ ការខ្វះចន្លោះខ្លះៗ ក្នុងការសិក្សាស្រាវជ្រាវដែរ។ ទីមួយ តាមរយៈសហគមន៍ភូមិគោលដៅរបស់ក្រុមការងារដែលធ្វើការលើការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពខេត្តរតនគីរី បញ្ហាទំនាក់ទំនងបានកើតមានឡើង ដែលជាលទ្ធផលរបស់បទបញ្ញាលេខ០១បប ហើយមានការលំបាកក្នុងការប្រមូលពត៌មាន។ ពេលដែលរាជរដ្ឋាភិបាលកម្ពុជា ប្រគល់លិខិតដល់អង្គការក្រៅរដ្ឋាភិបាល ជាសមាជិករបស់ក្រុមការងារដែលធ្វើការលើការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពខេត្តរតនគីរី ដើម្បីផ្តល់ឈ្មោះភូមិទាំងអស់ ដែលក្រុមនិស្សិតស្ម័គ្រចិត្តនឹងចុះទៅ អង្គការក្រៅរដ្ឋាភិបាលទាំងនេះ ត្រូវបានបង្គាប់ឲ្យនៅឆ្ងាយ ពីភូមិក្រុមនិស្សិតស្ម័គ្រចិត្តចុះ ដើម្បីបញ្ជាសជម្លោះផលប្រយោជន៍ ជាមួយក្រុមនិស្សិតស្ម័គ្រចិត្ត។ ថ្វីបើការចុះមូលដ្ឋាន អាចជាវិធីល្អ ក្នុងការទទួលបានពត៌មានដ៏សុក្រិតនិងហ្មត់ចត់ ពត៌មានខ្លះក៏ ត្រូវបានប្រមូលពីការប្រជុំ នៅក្រុងបាន់លុង ឬតាមទូរស័ព្ទ។

គួរកត់សម្គាល់ថា អ្នកភូមិដែលយើងបានសម្ភាសភាគច្រើន គឺជាប្រជាជនដែលចូលរួមក្នុងការដឹកនាំនិងគ្រប់គ្រងសហគមន៍ ដូចជាមេភូមិ ចាស់ព្រឹទ្ធាចារ្យក្នុងភូមិ មិត្តភ័ក្តិ និងអ្នកជិតខាងពួកគេ។ អ្នកដឹកនាំសហគមន៍ បានទទួលស្គាល់ថា ជនជាតិដើមភាគតិចខ្លះនៅក្នុងភូមិ មិនចង់បានកម្មសិទ្ធិដីសមូហភាព ដោយសារពួកគាត់ចង់លក់ដីរបស់ខ្លួន។ ប្រជាជនភាគច្រើនក្នុងភូមិទាំង៧១ ដែលបានទទួលការសម្ភាស បានបោះឆ្នោតយកកម្មសិទ្ធិដីសមូហភាព មុនការអនុវត្តបទបញ្ញា០១បប ទោះជាភាគរយនេះនឹងប្រហែលជាបានផ្លាស់ប្តូរ ក្រោយការមកដល់របស់ក្រុមនិស្សិតស្ម័គ្រចិត្ត។

## IV. ការសង្ខេបលទ្ធផលនៃការស្រាវជ្រាវ

អ្នកស្រាវជ្រាវ បានសម្ភាសជនជាតិដើមភាគតិច មកពី៧៩ភូមិ នៅខេត្តរតនគីរី។ ភូមិនេះស្ថិតនៅក្នុងស្រុកទាំងប្រាំបី នៃខេត្តរតនគីរី៖ ស្រុកអណ្តូងមាស (១៣ភូមិ) បរកែវ (១០ភូមិ) កូនមុំ(៥ភូមិ) លំផាត់(១ភូមិ) អូរយ៉ាដាវ(១១ភូមិ) អូរជុំ(១៣ភូមិ) តាវែង(៦ភូមិ) និងស្រុកវើនសៃ(៩ភូមិ) ។ ជាតិពន្ធុក្នុងស្រុកនីមួយៗ ផ្លាស់ប្តូរពីមួយទៅមួយ រួមមានប្រាំពីរក្រុមជនជាតិភាគតិចផ្សេងគ្នា ក្រុមព្រៅ(៩ភូមិ) ចារាយ(២១ភូមិ) កាចក់(៥ភូមិ) គ្រឹង(២៣ភូមិ) ទំពួន(១៧ភូមិ) លន់(១ភូមិ) ការវេត(២ភូមិ) និងមួយភូមិទៀតជាល្បាយនៃក្រុមជនជាតិដើមភាគតិចជាច្រើនក្រុម ។

**រូបទីមួយៈ ជនជាតិដើមភាគតិច និងទីតាំង (តាមស្រុក) នៃភូមិដែលបានសម្ភាសក្នុងខេត្តរតនៈគីរី**




ភូមិចំនួន៧១ ក្នុងចំណោមភូមិទាំង៧៩ ដែលក្រុមការងារស្រាវជ្រាវបានសម្ភាស បាននឹងកំពុងធ្វើការ ដើម្បីទទួលកម្មសិទ្ធិដីសមូហភាព និងស្ថិតនៅក្នុងដំនាក់កាលផ្សេងៗគ្នា។ ភូមិចំនួន១៨ បានចាប់ផ្តើមដំណើរការនៃការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាព នៅឆ្នាំ២០១២ ភូមិចំនួន១៧ បានចាប់ផ្តើមនៅឆ្នាំ២០១១ ភូមិចំនួន៣ បានចាប់ផ្តើមនៅឆ្នាំ២០១០ ភូមិ៣ទៀត នៅឆ្នាំ២០០៨ ភូមិ២៩ទៀតនៅឆ្នាំ២០០៧ និងភូមិចំនួនមួយ នៅឆ្នាំ១៩៩៨។ មកដល់បច្ចុប្បន្ននេះ គ្មានភូមិណាមួយ បានទទួលកម្មសិទ្ធិដីសមូហភាពទេ។ ភូមិចំនួន៤០ មានបញ្ហាជាមួយក្រុមហ៊ុនចំនួន២៧ រួមមានសម្បទានដីសេដ្ឋកិច្ច សម្បទានទ្រង់ទ្រាយតូច និងសម្បទាននៅតំបន់មានរ៉ែ។

នៅខែកក្កដាឆ្នាំ២០១២ អង្គការក្រៅរដ្ឋាភិបាលដែលធ្វើការលើការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាព បានទទួលលិខិតពី គណៈអភិបាលខេត្តរតនគីរី ក្នុងលិខិតនោះបានលើកឡើងពីឈ្មោះភូមិចំនួន៣១ ដែលនឹងត្រូវទទួលការវាស់វែងដី ក្នុងកំឡុងការអនុវត្តបទបញ្ជា០១បប។ អង្គការក្រៅរដ្ឋាភិបាល បាននឹងកំពុងធ្វើការលើការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាព។ ក្រុមនិស្សិតស្ម័គ្រចិត្ត បានអនុវត្តបទបញ្ជា០១ប នៅក្នុងភូមិចំនួន១៩ ចំណោមភូមិទាំងអស់ និងបន្ថែមទៅលើប្រាំពីរភូមិ ដែលមិនបានបញ្ជាក់ក្នុងលិខិត[22]។

[22] សូមមើលឯកសារយោងទីពីរ សម្រាប់លិខិតដែលផ្ញើរមកអង្គការ

ក្នុងចំណោមភូមិទាំង៧៩ដែលក្រុមការងារស្រាវជ្រាវបានសម្ភាស ភូមិចំនួន៤០ មានបញ្ហាជាមួយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច សម្បទានទ្រង់ទ្រាយតូច និងសម្បទាននៅតំបន់រ៉ែ[23] ។ ភូមិចំនួន២៥ ក្នុងចំណោមភូមិទាំង៤០ ដែលបានទទួលរងការប៉ះទង្គិចពីក្រុមហ៊ុន និងត្រូវបានវាស់វែងដោយបទបញ្ជា០១បប។ ភូមិចំនួន១៥ទៀត ដែលមានជម្លោះជាមួយក្រុមហ៊ុន មិនបានត្រូវវាស់វែងដោយបទបញ្ជា០១បបទេ។ ភូមិចំនួន៣៨ មិនមានជម្លោះជាមួយក្រុមហ៊ុន និង មិនបានត្រូវវាស់វែងដោយបទបញ្ជា០១បបទេ។ ភូមិចំនួនមួយ គឺភូមិកុកព្រៅ បានអះអាងថា គ្មានដីជាន់ជាមួយក្រុមហ៊ុនទេ ប៉ុន្តែ គ្រួសារចំនួន៨៤ក្នុងចំណោម៩១គ្រួសារ ត្រូវបានគេវាស់ដីសម្រាប់កម្មសិទ្ធិឯកជន។

### រូបទី២ ៖ ការចាត់ថ្នាក់ភូមិចំនួន២៦ដែលទទួលរងការប៉ះពាល់ដោយបទបញ្ជា០១បប




ភូមិចំនួន២៦ ដែលទទួលរងការប៉ះពាល់ពីបទបញ្ជា០១បប មានប្រជាជនសរុបចំនួន៣០៥៣គ្រួសារ។ ក្នុងចំណោមគ្រួសារទាំងនេះ ១៥៨២គ្រួសារ(៥២%) បានត្រូវវាស់វែងដីសម្រាប់កម្មសិទ្ធិឯកជន។

### តារាងទី១៖ ការចាត់ថ្នាក់ភូមិដែលបានត្រូវសម្ភាសពីអង្គការ

| អង្គការក្រៅរដ្ឋាភិបាល | #ភូមិគោលដៅរបស់ក្រុមការងា CLT | ពត៌មានដែលប្រមូលបានពី# ភូមិ | # ភូមិ ជាន់ជាមួយក្រុមហ៊ុន | #ភូមិ ដែលរងការប៉ះពាល់ដោយ ០១បប | # គ្រួសារដែលទទួលព្រមយកកម្មសិទ្ធិដោយ០១បប/ ចំនួនគ្រួសារសរុប |
|---|---|---|---|---|---|
| សរុប | ៧១ | 79 | ៤០ | ២៦ | ១៥៨៦/៣០៥៣(៥២%) |

[23] នេះរួមមានក្រុមហ៊ុនចំនួន២៦។ សម្រាប់បញ្ជីឈ្មោះភូមិដែលទទួងរងការប៉ះពាល់ដោយក្រុមហ៊ុន និងឈ្មោះក្រុមហ៊ុន សូមមើលឧបសម្ព័ន្ធទី៣

រូបទីពីរ បង្ហាញពីការចាត់ថ្នាក់ភូមិទាំង២៦ ដែលបានទទួលការសម្ភាស និងរងការប៉ះពាល់ពីបទបញ្ជា០១បប ព្រមទាំងចំនួនគ្រួសារ ដែលត្រូវបានវាស់វែងដីសម្រាប់កម្មសិទ្ធិឯកជន។ ក្នុងសហគមន៍ចំនួន ១០ គ្រួសារប្រហែល១០០% ត្រូវបានគេវាស់វែងដីសម្រាប់កម្មសិទ្ធិឯកជន។ ក្នុង១១ភូមិទៀត ក្រុមនិស្សិតស្ម័គ្រចិត្ត បានចុះមកវាស់វែងតែព្រំប្រទល់ដីឯកជនរបស់គ្រួសារខ្លះប៉ុណ្ណោះ។ ក្នុងភូមិទាំងនេះ មានតែគ្រួសារ ដែលរស់នៅក្នុងដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ដីដែលមានទំនាស់ទេ ដែលត្រូវបានគេវាស់វែងដីសម្រាប់កម្មសិទ្ធិឯកជន។

ភូមិចំនួន៤ មិនអនុញ្ញាតឲ្យក្រុមនិស្សិតស្ម័គ្រចិត្តចុះមកអនុវត្តការងារទេ៖ ភូមិកាតែ កាណុង ប៉ាដាល់ និងភូមិសមុទ្រក្រោម។ ពួកគេបដិសេដសហការ លើកលែងតែក្រុមនិស្សិតស្ម័គ្រចិត្តយល់ព្រមវាស់វែងដីសមូហភាពរបស់គេ។ ដូចបានលើកឡើងខាងលើ ក្នុងមួយភូមិ ភូមិកុកព្រៅ គ្រួសារភាគច្រើនបានត្រូវគេវាស់ដី សម្រាប់កម្មសិទ្ធិឯកជន ទោះបីជាគេអះអាងថា មិនមានដីដែលជាន់នឹងដីក្រុមហ៊ុនក៏ដោយ។

**រូបទី៣៖ការចាត់ថ្នាក់គ្រួសារដែលបានត្រូវគេវាស់ដីសម្រាប់កម្មសិទ្ធិឯកជននៅក្នុង២៦ភូមិ**




នៅក្នុងភូមិនីមួយៗ នៃភូមិទាំង២៦ ដែលទទួលរងការប៉ះពាល់ពីបទបញ្ជា០១បប នៅពេលដែលសមាជិកសហគមន៍រួមមានបុរស និងស្ត្រី ត្រូវបានសម្ភាសថា តើពួកគេមានការពេញចិត្តឬទេ ជាមួយដំណើរការផ្តល់ដីកម្មសិទ្ធិ របស់និស្សិតស្ម័គ្រចិត្ត ក្នុងនោះភូមិចំនួន២៥ មកពីសហគមន៍ជនជាតិដើមភាគតិចចំនួន២៦ បានឆ្លើយថា"ទេ"។

មូលហេតុទូទៅដែលប្រជាជនមិនពេញចិត្ត គឺ៖

១–ប្រជាជនបាត់បង់ដី ដែលនេះជាលទ្ធផលនៃដំណើរការ។

២–គោលនយោបាយបានដាក់សម្ពាធលើសហគមន៍ ដើម្បីធ្វើឲ្យដីរបស់គេមានលក្ខណៈឯកជន និង ដោះស្រាយទំនាស់ដ៏ស្មុគស្មាញយ៉ាងឆាប់រហ័ស។

៣–ក្រុមដែលផ្តល់កម្មសិទ្ធិដីឯកជន ឬ អ្នកដែលសហការណ៍ជាមួយគេ បានផ្តល់ពត៌មានមិនច្បាស់លាស់ដល់សហគមន៍ និងខ្វះតម្លាភាព។

៤–ក្រុមនិសិត្ស និង អជ្ញាធរមូលដ្ឋាន បានគំរាមកំហែង និងបង្ខិតបង្ខំអ្នកភូមិ។

បញ្ហាទាំងអស់នេះនឹងត្រូវបកស្រាយយ៉ាងលិអិតនៅខាងក្រោមនេះ។

**១–ការបាត់បង់ដី**

ហេតុផលសំខាន់ថាហេតុអ្វីបានជា អ្នកភូមិរាយការណ៍ថា ពួកគេមិនពេញចិត្តនឹងបទបញ្ជា០១បប គឺដោយសារតែ គោលនយោបាយនេះមិនបានការពារ នូវដីសហគមន៍របស់ពួកគេ។ ជំហានទីមួយ របស់ក្រុមនិសិត្សស្ម័គ្រចិត្ត គឺធ្វើការបង្ហាញនូវផែនទីក្រុមហ៊ុន ដែលពួកគេបានមកពីថ្នាក់ជាតិ បន្ទាប់មកធ្វើការវាស់វែង និងកំណត់ព្រំប្រទល់ដីរបស់គ្រួសារនីមួយៗ។ ជាក់ស្តែងគ្រួសារមួយចំនួនបានទទួលប្លង់ដីកម្មសិទ្ធ នៅក្នុងក្បាល់ដីរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច។ នៅក្នុងភូមិខ្លះ ក្រុមនិសិត្សស្ម័គ្រចិត្តវាស់វែងព្រំប្រទល់ដី សម្រាប់គ្រួសារ នៅខាងក្រៅព្រំប្រទល់ដីសម្បទានដីសេដ្ឋកិច្ច។ សមាជកិសហគមន៍ភាគច្រើនមិនសូវពេញចិត្ត ជាមួយនឹងបទបញ្ជានេះទេ គឺដោយសារតែ មានការវាស់វែងតែដីផ្ទាល់ខ្លួន ដែលកំពុងប្រើប្រាស់តែប៉ុណ្ណោះ ហើយមិនបានវាស់វែដីសមូហភាពបន្ថែមរបស់ពួកគេនោះទេ។

សហគមន៍គោលដៅសម្រាប់ការអនុវត្តបទបញ្ជា០១បប កំពុងរស់នៅជិតក្រុមហ៊ុន និងកត់សម្គាល់ថា ពួកគេទទួលរងនូវសម្ពាធកាន់តែខ្លាំងឡើង ដើម្បីព្យាយាមថែរក្សានូវវប្បធម៌ ប្រពៃណី និងភាពជាម្ចាស់លើដីរបស់ពួកគេ។ ពួកគេចង់ធានានូវសុវត្ថិភាពដីសមូហភាពរបស់ពួកគេ ប៉ុន្តែដំណើការនៃការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពប្រើពេលយូរពេក។ សមាជិកសហគមន៍ចំនួន២៥នាក់ ក្នុងចំណោមភូមិទាំង២៦ បានសំដែងនូវភាពភ័យខ្លាចថា ក្រុមហ៊ុន នឹងចូលមកធ្វើការឈូសដីដែលនៅសល់របស់ពួកគេ បើសិនជាពួកគេ មិនព្រមទទួលនូវកម្មសិទ្ធិដីឯកជន។ រាជរដ្ឋាភិបាល បានទទួលស្គាល់ អំពីពេលវេលា ការចំណាយច្រើន នៅក្នុងដំណើការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាព តាមរយៈបទបញ្ជា០២០ និងបានបញ្ឈប់នូវការវាស់វែងដីជាកម្មសិទ្ធិសមូហភាព ដោយបន្តអនុវត្តវាស់វែងតែដីកម្មសិទ្ធិឯកជន ដល់សហគមន៍។ ក្នុងពេលដំណាលគ្នា ក្រុមហ៊ុន ក៏កំពុងចូលជិតអ្នកភូមិដែរ។ ចាស់ទំម្នាក់ នៅក្នុងភូមិកាណាត បានធ្វើការពន្យល់៖ ″

បើយើងរង់ចាំការចុះបញ្ជីដីជាសមូហភាព ពួកយើងប្រាកដជាគ្មានដីដែលនៅសល់ សម្រាប់ចុះបញ្ជីនោះទេ។

សហគមន៍ មិនសូវពេញចិត្ត ជាមួយបទបញ្ជា០១បបនោះទេ ដោយសារបទបញ្ជានេះ មិនផ្ដល់ត្រលប់មកវិញនូវដីសមូសភាព របស់សហគមន៍ ដែលបានបាត់បង់ ដោយសារក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចទេ។ សម្រាប់សហគមន៍មួយចំនួន ដែលបានទទួលការវាស់វែង សម្រាប់កម្មសិទ្ធិឯកជន ជាទូទៅ ភាគច្រើន ទទួលការគំរាមកំហែងពីក្រុមហ៊ុន។ នៅក្នុងសហគមន៍ទាំងអស់ ដែល១០០ភាគរយនៃគ្រួសារទាំងនោះបានទទួលបានកម្មសិទ្ធិដីឯកជន គឺសុទ្ធសឹង ជាគ្រួសារ ដែលក្រុមហ៊ុនបានឈូសដីសមូហភាពរបស់ពួកគេ ស្ទើរតែទាំងអស់រួចទៅហើយ ហើយក្នុងចំណោមទាំងនោះ មានគ្រួសារជាច្រើន ដែលមានដីស្ថិតនៅក្នុងព្រំប្រទល់របស់ផែនទីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច។ ដូច្នេះបទបញ្ជា០១បប មិនបានផ្ដល់នូវដីដែលបាត់បង់នោះត្រឡប់មកអោយសហគមន៍វិញទេ។

ការពិត អ្នកភូមិបានបញ្ជាក់ថាកម្មសិទ្ធិឯកជនបានធ្វើឲ្យដីសមូហភាពរបស់សហគមន៍ពួកគាត់កាន់តែងាយរងគ្រោះទៅនឹងក្រុមហ៊ុន។ សមាជិកសហគមន៍នៅក្នុងភូមិខ្លះដែលបានទទួលដីកម្មសិទ្ធិឯកជនពីបទបញ្ជា០១បប បាននិយាយថា ក្រុមហ៊ុនទាំងនោះបានឈូសឆាយដីសហគមន៍របស់ពួកគាត់រួចបន្ថែមទៀតហើយ ពីព្រោះក្រុមនិសិត្សបានវាសវែងតែចំពោះក្បាលដី ដែលស្ថិតនៅក្នុងតំបន់ក្រុមហ៊ុនដោយយោងតាមផែនទីដីសម្បទានដីសេដ្ឋកិច្ច។ សហគមន៍ទទួលស្គាល់ថា ក្រុមហ៊ុនមានការងាយស្រួលជាងមុនក្នុងការឈូសឆាយដីសមូហភាពរបស់សហគមន៍ដែលនៅសល់ និងគ្មានបន្សល់ទុកនូវដីទំនេរសម្រាប់ពួកគេទេ។ នេះជាសំដីរបស់ចាស់ទុំនៅក្នុងភូមិថ្មី៖ ״បើសិនជាពួកយើងខិតខំព្យាយាមចុះបញ្ជីដីជាសមូហភាព ពួកយើងនឹងបាត់បង់ដីរបស់យើងទេ ដោយសារដំណើរការនៃការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពមានការយឺតយ៉ាវខ្លាំងណាស់ ប៉ុន្តែបើសិនជាយើងយល់ព្រមយកដីកម្មសិទ្ធិឯកជន យើងក៏នឹងបាត់បង់ដីរបស់យើងដូចគ្នា״។

ភូមិយ៉ាសាំ ជាភូមិមួយ ដែលបានចុះបញ្ជីជានីតិបុគ្គល និងបានការទទួលស្គាល់ពីក្រសួងមហាផ្ទៃរួចហើយ នៅពេលដែលក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចបានចូលទៅយកដីមួយផ្នែករបស់ពួកគេ។ គ្រួសារចំនួន ៤០ ក្នុងចំណោម១២០គ្រួសារ នៅក្នុងសហគមន៍ ត្រូវបានគេបង្ខំឲ្យលក់ដីក្នុងតំលៃ ១០០ ទៅ ២០០ដុល្លាអាមេរិកក្នុងមួយហិតា តាមរយៈការគំរាមកំហែងថា ក្រុមហ៊ុននឹងធ្វើការឈូសឆាយដីរបស់ពួកគេ បើសិនជាពួកគេមិនព្រមលក់ដី។ នៅពេលដែលនិសិត្សបានមកដល់ ក្រុមហ៊ុន បានឈូសឆាយដីមួយផ្នែកធំ របស់សហគមន៍រួចបាត់ទៅហើយ ដោយរួមបញ្ចូលទាំងព្រៃអារក្ស និងព្រៃបញ្ចុះសព។ គ្រួសារដែលនៅសល់ចំនួន៨០គ្រួសារ បានជ្រើសរើសយកដីកម្មសិទ្ធិឯកជន ជាមួយក្រុមនិស្សិតស្ម័គ្រចិត្ត ក្រោមការភ័យខ្លាច និង ការគំរាមកំហែងពីក្រុមហ៊ុនថា យកដីរបស់ពួកគេផងដែរ។ យ៉ាងណាងក៏ដោយ ចាស់ទុំម្នាក់ ក្នុងភូមិ បាននិយាយថា វាហាក់ដូចជាគ្រួសារដែលនៅសល់ ពីការយកកម្មសិទ្ធិដីឯកជន នឹងត្រូវទទួលរងសម្ពាធឲ្យលក់ដីរបស់ពួកគេ។

កាណាត ជាភូមិមួយ ដែលរំព័ទ្ធដោយក្រុមហ៊ុនចំការកៅស៊ូចំនួន៤។ ដូចគ្នាទៅនឹងភូមិយ៉ាសាំដែរ គឺក្រុមហ៊ុនបានកាត់យកដីមួយចំនួនធំរបស់សហគមន៍ ព្រមទាំងបានបង្ខំគ្រួសារជាច្រើនអោយលក់ដីផ្ទាល់ខ្លួនរបស់ពួកគេក្នុងតំលៃ ១០០ ទៅ ២០០ដុល្លាអាមេរិកក្នុងមួយហិកតា។ ទោះបីជាមានការទទួលរងនូសម្ពាធយ៉ាងណាក៏ដោយ ក៏នៅមានគ្រួសារមួយចំនួន យលព្រមចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពដែរ ដើម្បី "បញ្ឈប់ការឈូសឆាយរបស់ក្រុមហ៊ុនមកលើដីរបស់យើងបន្តទៀត"។ នៅពេលក្រុមនិស្សិតស្ម័គ្រចិត្ត បានចុះមកវាស់វែងដី អង្គការក្រៅរដ្ឋាភិបាល បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ ជាមួយចាស់ទុំក្នុងភូមិ អំពីដំណើការនៃការចុះវាស់ដីនេះ ក្រុមចាស់ទុំក្នុងភូមិបានផ្តល់ពត៌មានថា សមាជិកសហគមន៍ភាគច្រើននៅចង់បានការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាព និងមិនចង់បានកម្មសិទ្ធិឯកជននោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ក្រោយពីក្រុមនិសិត្សបានចាកចេញប្រហែលជាមួយខែ គ្រួសារទាំងអស់ត្រូវបានវាស់វែងសម្រាប់កម្មសិទ្ធិឯកជន ដែលបានកំណត់នៅក្នុងផែនទីរបស់ក្រុមហ៊ុនទាំង៤ នេះបើតាមការអះអាងរបស់ចាស់ទុំនៅក្នុងភូមិ។ ចាស់ទុំម្នាក់នៅក្នុងភូមិបានប្រាប់អោយដឹងៈ "យើងនៅតែចង់បានដីជាកម្មសិទ្ធិសមូហភាព ប៉ុន្តែយើងមិនមានគ្រប់ជ្រុងទាំង៤សម្រាប់ដីរបស់យើងទេ បើសិនជាយើងមានគ្រប់ទាំង៤ជ្រុងក្នុងការវាស់វែង យើងប្រាកដជាបានទទួលផែនទីរួចហើយ។ នៅពេលដែលក្រុមហ៊ុនទាំងនោះ បានឈូសដីស្ទើរតែទាំងអស់របស់សហគមន៍រួចហើយ ពួកគេមានអារម្មណ៍ថា ពួកគេគ្មានជំរើសអ្វីផ្សេងទៀត សម្រាប់ដីសមូហភាពទេ"។

សម្រាប់សហគមន៍មួយចំនួន ដែលមានបទពិសោធន៍មិនសូវទទួលរងសម្ពាធ ពីក្រុមហ៊ុនដែលនៅក្បែរភូមិពួកគេ គេហាក់បីដូចជាមិនសូវទទួលយកនូវកម្មសិទ្ធិដីឯកជននោះទេ។ ភូមិចំនួន៤ ក្នុងចំនោមភូមិទាំង២៦ដែលក្រុមនិសិត្សព្យាយាមចូលទៅវាស់វែងដីរួមមានៈ កាក់ តាណង បាដល និងភូមិសមុទ្រក្រោម សហគមន៍មិនបានអនុញ្ញាត អោយក្រុមនិសិត្សចូលទៅកំណត់ព្រំប្រទរបស់ពួកគេនោះទេ។ ក្រុមហ៊ុនដែលមានទំនាស់ជាមួយសហគមន៍ទាំងនោះ គ្រាន់តែចុះទៅវាសវែងដីមួយផ្នែកតូច ដែលមានជម្លោះ ដូច្នោះសហគមន៍ពួកគេមិនបានមានអារម្មណ៍ថា ត្រូវបានបង្ខំអោយទទួលយកកម្មសិទ្ធិឯកជននោះទេ។ ភូមិនីមួយៗ នឹងបន្តបដិសេធមិនព្រមចូលរួមនៅក្នុងដំណើរការអនុវត្តបទបញ្ជា០១បបនោះទេ លុះត្រាតែក្រុមនិសិត្សកំណត់ព្រំប្រទល់ដីសហគមន៍របស់ពួកគេសិន។ ពួកគេ មានជំនឿថា ការទទួលយកនូវកម្មសិទ្ធិឯកជន ជាមូលហេតុដែលបង្កឲ្យពួកគេបាត់បង់ដីបន្ថែមទៀត។

### ២–ដំណើរការក្នុងការបង្ខិតបង្ខំ

សហគមន៍បានបង្ហាញថា ការអនុវត្តបទបញ្ជា ០១បប បានធ្វើអោយពួកគេ ទទួលរងសម្ពាធកាន់តែខ្លាំងឡើង បន្ថែមទៅលើអ្វីដែលពួកគេធ្លាប់បានទទួលពីខាងក្រុមហ៊ុន។ បទបញ្ជា ០១បប បានបង្ខិតបង្ខំអោយសហគមន៍ ធ្វើការសម្រេចចិត្តយ៉ាងឆាប់រហ័ស ដែលនេះធ្វើអោយពួកគេពិបាកក្នុងការសម្រេចចិត្តទាក់ទងទៅនឹងការចុះបញ្ជីដីរបស់ពួកគេ និងដោះស្រាយជម្លោះដែលមានភាពស្មុគស្មាញជាមួយក្រុមហ៊ុន

មានអំណាច។ ការធ្វើបែបនេះបង្កឲ្យមានការបែកបាក់នូវសាមគ្គីភាពនៅក្នុងសហគមន៍ និងធ្វើឲ្យមានជម្លោះដីធ្លីបន្តបន្ទាប់ទៀត។

ទោះបីជាសហគមន៍ជាច្រើន ដែលធ្លាប់បានឯកភាពរួមគ្នា ក្នុងការស្នើរសុំចុះបញ្ជីដីរបស់គេជាកម្មសិទ្ធិសមូហភាពក៏ដោយ ក៏ពួកគេបានកត់សំគាល់ថា ការមកដល់របស់ក្រុមនិសិត្សស្ម័គ្រចិត្ត បានកាន់តែធ្វើឲ្យសហគមន៍មានការខ្វែងគំនិតគ្នាអំពីថា តើសហគមន៍គួរតែទទួលយកនូវកម្មសិទ្ធិដីឯកជន ឬក៏ រងចាំកម្មសិទ្ធិសមូហភាព។ ក្រុមនិស្សិតស្ម័គ្រចិត្ត ស្នាក់នៅក្នុងភូមិប្រហែលជាមួយខែ ដែលនេះបង្ខំឲ្យសហគមន៍ធ្វើការសម្រេចចិត្តអំពីរឿងសំខាន់និងពិបាក ចំពោះការចុះបញ្ជីដីរបស់គេនៅក្នុងរយៈពេលយ៉ាងខ្លី។ សហគមន៍បាននិយាយថា ដំណើរការយ៉ាងឆាប់រហ័សរបស់ក្រុមនិស្សិតស្ម័គ្រចិត្ត បានបង្កឲ្យមានការបែកបាកសាមគ្គីភាពផ្ទៃក្នុង នៅសហគមន៍របស់ពួកគេកាន់តែខ្លាំងឡើងៗ។

គោលនយោបាយនេះ បានដាក់សម្ពាធដល់សហគមន៍ក្នុងការដោះស្រាយនូវជម្លោះដែលមានភាពស្មុគស្មាញ ជាមួយនឹងក្រុមហ៊ុនដែលមានអំណាច ព្រមទាំងផ្តល់នូវធនធានបន្តិចបន្តួចក្នុងការដោះស្រាយនូវជម្លោះទាំងនោះ។ ឧទាហរណ៍នៅក្នុងភូមិកាឡៃតាវ៉ង និងភូមិកាឡៃសាពូន ក្រុមនិស្សិតស្ម័គ្រចិត្តបានធ្វើការវាស់វែងដីរបស់គ្រួសារមួយចំនួន ដែលជាន់គ្នាជាមួយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច បន្ទាប់មកក្រុមនិសិត្សបានសុំឲ្យសហគមន៍ពិភាក្សាដោះស្រាយបញ្ហាជាមួយក្រុមហ៊ុនដោយខ្លួនឯង ដោយសន្យាថានឹងត្រឡប់មកធ្វើការវាសវែងដីកម្មសិទ្ធិឯកជនដល់សហគមន៍ម្តងទៀត បន្ទាប់ពីដោះស្រាយជម្លោះរួច។ មេភូមិទាំងពីរបាននិយាយថា ពួកគេមិនដឹងជាដោះស្រាយដោយវិធីណាទេ និងក៏មិនដឹងថាពេលណាក្រុមនិសិត្សនឹងត្រឡប់មកទៀតដែរ។ មេភូមិបានអះអាង៖ " ក្រុមហ៊ុនមិនមានការគោរពចំពោះពួកយើងទេ ហើយពួកគេមិនស្តាប់ពួកយើងនោះទេ"។ បទបញ្ជា ០១បប បានដាក់សម្ពាធដល់សហគមន៍ក្នុងការដោះស្រាយជម្លោះជាមួយនឹងការផ្តល់នូវធនធានបន្តិចបន្តួច ហើយជម្លោះនៅតែបន្ត ក្រោយពីក្រុមនិសិត្សបានចាកចេញទៅ។

### ៣–ការផ្តល់ព័ត៌មានមិនច្បាស់លាស់និងកង្វះតម្លាភាព

ចាប់ពីពេលផ្តើមបទបញ្ជា០១បប ការខ្វះតម្លាភាពនៅក្នុងការផ្តល់ពត៌មាន ជាហេតុផលដែលធ្វើអោយសហគមន៍ ធ្វើការសម្រេចចិត្តខុសចំពោះដីធ្លីរបស់ពួកគេ។ ជនជាតិដើមភាគតិច បានទទួលពត៌មានមិនពិតអំពីបទបញ្ជា ០១បប និងការអនុវត្តរបស់បទបញ្ជានេះ។ មុនពេលក្រុមនិស្សិតស្ម័គ្រចិត្តមកដល់ អាជ្ញាធរមូលដ្ឋាន បានប្រាប់ទៅអ្នកភូមិថាបទបញ្ជានេះ គឺជាគោលនយោបាយរបស់រដ្ឋាភិបាលដែលបានអនុវត្តក្នុងការដោះស្រាយជម្លោះដីធ្លី និងផ្តល់ឱកាសដល់សហគមន៍ក្នុងការទាមទាយកដីពីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចត្រលប់មកវិញ ។ សហគមន៍ជាច្រើន បានសម្រេចចិត្តផ្អាកនូវដំណើការចុះបញ្ជីដីជាកម្មសិទ្ធិ

សមូហភាព និងឈប់តវ៉ាប្រឆាំងជាមួយក្រុមហ៊ុន ដែលនៅជិតភូមិ ដើម្បីរង់ចាំមើលគោលនយោបាយនេះ។ សហគមន៍ខ្លះបានលើកឡើងថា ពួកគេបានឈូសឆាយតំបន់ព្រៃធំ ដើម្បីត្រៀមចាំទទួលគោលនយោបាយនេះ ដោយសារមានពាក្យចាមអារ៉ាមថា គេនឹងអនុញ្ញាតឲ្យចុះបញ្ជីក្បាលដីកាន់តែច្រើន។ ការផ្តល់ព័ត៌មានខុសពីដំបូង ក្នុងគោលនយោបាយ បានបង្កឲ្យអ្នកភូមិ ធ្វើការសម្រេចចិត្តប្រញាប់ប្រញាល់ចំពោះដីពួកគេ។

ដោយសារគោលនយោបាយ និងច្បាប់នានា ត្រូវបានតាក់តែង ដោយមិនមានតម្លាភាព សហគមន៍ព្យាយាមក្នុងការបត់បែនតាម និងព្យាយាមក្នុងការស្វែងរកយុទ្ធសាស្ត្រដែលប្រសើរ ថាតើធ្វើយ៉ាងណាល្អដើម្បីថែរក្សាដីរបស់ពួកគេ។ ទោះបីជាសហគមន៍ដែលមានការយល់ដឹងខ្លះៗ អំពីសិទ្ធិជាមូលដ្ឋានរបស់ពួកគេ ក៏បាននិយាយថា ពួកគេតែងតែមិនបានទទួលដំណឹងស្តីពីបទបញ្ជា០១បប ដោយសារមានការកែប្រែបទបញ្ជានេះជាច្រើនលើក។ ជាមួយការផ្លាស់ប្តូរជាញឹកញាប់ ក្រុមនិស្សិតស្ម័គ្រចិត្តផ្សព្វផ្សាយនូវព័ត៌មានមិនត្រឹមត្រូវ និងមិនច្បាស់លាស់នៅក្នុងដំណើរការនៃការអនុវត្តបទបញ្ជា០១បប ដែលទាំងនេះបានធ្វើឲ្យសហគមន៍មានការលំបាកក្នុងការសម្រេចចិត្ត។

អ្នកភូមិដែលព្យាយាមចង់ដឹងអំពីព័ត៌មាន បាននៅដាច់ឆ្ងាយពីប្រភពព័ត៌មានសំខាន់ៗ ដូចជាអង្គការក្រៅរដ្ឋាភិបាលជាដើម។ ក្រុមនិសិត្សបានរស់ក្នុងភូមិនីមួយៗប្រមាណជាជាងមួយខែ អង្គការក្រៅរដ្ឋាភិបាលបាន ត្រូវគេប្រាប់ឲ្យធ្វើសកម្មភាពរបស់អង្គការ នៅក្រៅភូមិ ដែលមានក្រុមនិស្សិតស្ម័គ្រចិត្តកំពុងបំពេញបេសកកម្មរបស់ពួកគេ ដើម្បីជៀសវាងជម្លោះផលប្រយោជន៍ជាមួយក្រុមនិសិត្ស។ អ្នកភូមិដែលបានស្វែងរកការជួយពីអង្គការក្រៅរដ្ឋាភិបាល បានប្រាប់អោយដឹងថា រដ្ឋាភិបាលគ្រាន់តែដោះស្រាយជម្លោះដីធ្លីនៅក្នុងសហគមន៍ ដែលមិនមានការគាំទ្រពីអ្នកខាងក្រៅតែប៉ុណ្ណោះ។

អង្គការក្រៅរដ្ឋាភិបាល ក៏ខ្វះនូវព័ត៌មានដែលមានតម្លាភាពដែរ។ បុគ្គលិកអង្គការក្រៅរដ្ឋាភិបាលធ្វើការកត់សំគាល់ថា អាជ្ញាធរមូលដ្ឋាន និងសារព័ត៌មាន បានអោយដឹងថាគោលនយោបាយនេះអាចដោះស្រាយនូវជម្លោះដីធ្លីបាន តាមរយៈការវាស់វែងដីសហគមន៍ ពីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច និងប្រគល់ត្រលប់ទៅឲ្យសហគមន៍វិញ ប៉ុន្តែការអនុវត្តជាក់ស្តែងគឺផ្ទុយពីការពិត។ អង្គការក្រៅរដ្ឋាភិបាលបានទទួលលិខិតពីសាលាខេត្ត នៅក្នុងខែកក្កដាឆ្នាំ២០១២ ដែលក្នុងនោះមានភូមិចំនួន៣១ នៅក្នុងខេត្តរតនគីរីដែលនឹងត្រូវទទួលការវាស់វែង។ ភូមិចំនួន១៩ក្នុងចំណោមភូមិទាំង៣១ ស្ថិតក្នុងភូមិគោលដៅរបស់អង្គការដែលធ្វើការលើការចុះបញ្ជីដីជាកម្មសិទ្ធសមូហភាព ។ ទោះបីជាយ៉ាងណាក៏ដោយ អង្គការក្រៅរដ្ឋាភិបាលមានការភ្ញាក់ផ្អើលជាមួយនឹងការរកឃើញថា ក្រុមនិសិត្សស្ម័គ្រចិត្ត បានធ្វើការវាស់វែងភូមិចំនួន៧ផ្សេងទៀត ដែលមិនមានឈ្មោះនៅក្នុងលិខិតរបស់សាលាខេត្ត។ អាជ្ញាធរឃុំ ស្រុក ខេត្តបាននិយាយថា ពួកគេមិនបានដឹង អំពីលិខិតនោះទេ ដោយសារការជ្រើសរើសភូមិទាំងនោះ គឺធ្វើឡើងដោយមានការបង្គាប់បញ្ជា

ពីថ្នាក់លើ។ អង្គការក្រៅរដ្ឋាភិបាល មិនបានទទួលដំណឹងអំពីសកម្មភាពរបស់ក្រុមនិសិត្សស្ម័គ្រចិត្តនោះទេ នេះជាមូលហេតុដែលធ្វើអោយពួកគេមានពត៌មានមិនច្បាស់ពីអ្នកភូមិ នៅក្នុងករណីមួយចំនួន។

ក្នុងការអនុវត្តបទបញ្ជា០១បប គ្រួសារជនជាតិដើមភាគតិចភាគច្រើន បាននិយាយថា ពួកគេទទួលយកដីកម្មសិទ្ធិឯកជន ដោយមិនមានការយល់ដឹងច្បាស់ អំពីភាពខុសគ្នារវាងកម្មសិទ្ធិដីឯកជនរបស់ក្រុមនិសិត្សស្ម័គ្រចិត្ត និងកម្មសិទ្ធិសមូហភាព។ ក្រុមនិសិត្សស្ម័គ្រចិត្ត មិនបានធ្វើការពន្យល់ឲ្យបានក្បោះក្បាយនោះទេថា មូលហេតុអ្វីបានជាពួកគេធ្វើការវាស់វែងតែប្លង់ដីឯកជនជូនអ្នកភូមិ ឬក៏តើដីប្រភេទណាដែល បទបញ្ជា០១បប រាប់បញ្ចូលក្នុងការវាស់វែង។ នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយអ្នកភូមិ ពួកគេបានប្រាប់អោយដឹងថា ពួកគេមិនពេញចិត្តជាមួយ០១បបទេ ពីព្រោះថាក្រុមនិសិត្សស្ម័គ្រចិត្ត មិនបានវាស់វែងដីរបស់ពួកគេទាំងអស់ទេ។ ដូច្នេះគេ ដូចជាមិនច្បាស់សោះថា ការវាស់វែងនេះគួរតែបានផាត់ដីសមូហភាពរបស់ពួកគេចេញពីក្នុងកម្មសិទ្ធិដីឯកជនរបស់បទបញ្ជា០១បប។ ដំណើការការកំណត់ព្រំប្រទល់ដីមិនបានទទួលជោគជ័យក្នុងការផ្តល់ពត៌មាន ដ៏ពេញលេញដល់សហគមន៍ទេ តើបទបញ្ជា០១បបរួមមានកម្មសិទ្ធិអ្វី បើប្រៀបធៀបនឹងកម្មសិទ្ធិសមូសភាព។

សហគមន៍ភាគច្រើនដែលមិនបានទទួលដំណឹង គឺសហគមន៍ដែលនៅជំហានដំបូងនៃដំណើការចុះបញ្ជីដីជាសមូហភាព។ ឧទាហរណ៍ដូចជាភូមិភ្នំកុកព្រៅ ជាភូមិដែលទើបតែនឹងចាប់ផ្តើមដំណើរការចុះបញ្ជីដីសមូហភាព ក្រុមនិសិត្សស្ម័គ្រចិត្តក៏បានចូលមកដល់។ សហគមន៍ និងអង្គការក្រៅរដ្ឋាភិបាលបានចូលរួមក្នុងការជួយសម្របសម្រួលការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាព ក្រោយពីអនុវត្តការបង្គាប់របស់រាជរដ្ឋាភិបាល ឲ្យផ្អាកដំណើការចុះបញ្ជីដីសមូហភាពមួយរយៈ រហូតដល់ក្រុមនិសិត្សស្ម័គ្រចិត្ត បានបញ្ចប់ការកំណត់ព្រំប្រទល់ដី។ នៅពេលដែលអង្គការក្រៅរដ្ឋាភិបាល បានជួបជាមួយមេភូមិភ្នំកុកព្រៅ និងចាស់ទុំនៅក្នុងភូមិ បន្ទាប់ពីក្រុមនិសិត្សស្ម័គ្រចិត្តបានចាកចេញទៅ គ្រួសារចំនួន៨៤ ក្នុងចំណោម៩១គ្រួសារ បានទទួលការវាស់វែងដីកម្មសិទ្ធិឯកជន។ លោកមេភូមិ បាននិយាយថា សហគមន៍របស់ពួកគេ មិនមានទំនាស់ជាមួយក្រុមហ៊ុនទេ ប៉ុន្តែក្រុមនិសិត្សស្ម័គ្រចិត្ត មិនបានសួរគាត់ថាតើនៅក្នុងសហគមន៍របស់គាត់មានជម្លោះជាមួយក្រុមហ៊ុនរឺទេ។ មេភូមិបាននិយាយថាអ្នកភូមិរបស់ពួកគាត់ បានចូលរួមជាមួយនឹងគម្រោងរបស់ក្រុមនិសិត្សស្ម័គ្រចិត្ត ពីព្រោះ "មានក្រុមហ៊ុនមួយចំនួន បានចុះមកសិក្សាមើល នៅតាមព្រំប្រទល់ដីរបស់ពួកយើង ហើយយើងចង់បានឯកសារផ្លូវការ ដើម្បីការពារដីរបស់ពួកយើងសម្រាប់កូនចៅជំនាន់ក្រោយរបស់យើង និងបន្តការប្រើប្រាស់ដីសហគមន៍របស់យើងជាលក្ខណៈសមូហភាព"។ លោកមេភូមិបានគិតថា ការវាស់វែងដីរបស់បទបញ្ជា ០១បប មានរួមបញ្ចូលដីសហគមន៍ផងដែរ។

ទោះបីជាសហគមន៍មួយចំនួន ដែលបានទទួលការពន្យល់អំពីភាពខុសគ្នារវាងកម្មសិទ្ធិឯកជន និងកម្មសិទ្ធិសមូហភាព ដើម្បីធ្វើការសម្រេចចិត្តសម្រាប់ដីរបស់ពួកគេ ប៉ុន្តែពត៌មានទាំងនោះ ក៏មិនមានតម្លាភាពដែរ។ សហគមន៍ជាច្រើន បានទទួលយកកម្មសិទ្ធិឯកជន ដោយពួកគេស្មានថា អាចផ្លាស់ប្តូរទៅជាកម្មសិទ្ធិសមូហភាពវិញបាន។ ក្រុមនិសិត្សស្ម័គ្រចិត្ត បានប្រាប់ទៅសហគមន៍ថា ពួកគេអាចធ្វើការផ្លាស់ប្តូរ "យ៉ាងងាយស្រួល" ពីកម្មសិទ្ធិឯកជនទៅកម្មសិទ្ធិសមូហភាពទេ ប៉ុន្តែនាពេលថ្មីៗនេះ រដ្ឋមន្រ្តីក្រសួងដែនដី

នគររូបនីយកម្មនិងសំណង់ មានប្រសាសន៍ថាមិនអាចផ្លាស់ប្តូរបានទេ។ ទោះបីជាយ៉ាងណាក៏ដោយ កិច្ចសន្យាដែលសហគមន៍ត្រូវចុះហត្ថលេខា ដោយយោងតាមសេចក្តីណែនាំរបស់បទបញ្ជា ០២០ តម្រូវឲ្យសហគមន៍ បោះបង់ចោលនូវសិទ្ធិក្នុងការប្រើប្រាស់កម្មសិទ្ធិសមូហភាពលើដីរបស់ពួកគេ។ សហគមន៍ជាច្រើនមិនអាចអាន ឬយល់នូវភាសាខ្មែរ និងអត្ថន័យរបស់កិច្ចសន្យាទាំងស្រុងទេ។ សហគមន៍ទាំងអស់ដែលបានទទួលការសម្ភាសបាននិយាយថា ពួកគេចង់បានសុវត្ថិភាពសម្រាប់ដីរបស់ពួកគេ ជាមួយកម្មសិទ្ធិសមូហភាព ហើយពួកគេហាក់បីដូចជាមិនច្បាស់សោះថាតើពួកគេគួរតែបដិសេធ ឬក៏ទទួលយកនូវដំណោះស្រាយរបស់ក្រុមនិសិត្សស្ម័គ្រចិត្ត ដើម្បីបន្តដំណើរនៃការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាព រហូតដល់បានទទួលជោគជ័យ។ កង្វះព័ត៌មានអំពីការផ្លាស់ប្តូរពីកម្មសិទ្ធិឯកជនទៅជាកម្មសិទ្ធិសមូភាពបានធ្វើអោយអ្នកភូមិមិនដឹងច្បាស់ថា ពួកគេត្រូវធ្វើអ្វីតទៅទៀតដើម្បីការពារដីសហគមន៍របស់ពួកគេ។

ការបិទប្រកាស អំពីលទ្ធផលនៃការកំណត់ព្រំប្រទល់ ក៏មិនមានតម្លាភាពដែរ។ អ្នកភូមិមិនដឹងច្បាស់ថា លទ្ធផលនេះនឹងបិទនៅពេលណា នៅកន្លែងណា ហើយអ្នកភូមិភាគច្រើនមិនចេះអានអក្សរនោះទេ ទោះបីជាភាសារខ្មែរក៏ដោយ។ លទ្ធផលនៃការវាស់វែងដីរបស់ ០១បប នឹងត្រូវបិទផ្សាយសម្រាប់រយៈពេលមួយខែ ហើយបើសិនជា សហគមន៍មិនបានបដិសេធនូវលទ្ធផលនោះទេ ការនៅស្ងៀមគឺមានន័យថាព្រមទទួលយកនូវលទ្ធផលទាំងនោះ។ នៅក្នុងពេលដែលកំពុងសរសេររបាយការណ៍នេះ ការបិទផ្សាយលទ្ធផល បានផុតកំណត់ហើយសម្រាប់អ្នកភូមិជាច្រើនដែលនៅតែចង់បានកម្មសិទ្ធិដីសមូហភាព។

## ៤–ការគំរាមកំហែង និងការបង្ខិតបង្ខំ

អ្នកភូមិដែលទទួលរងផលប៉ះពាល់ពីបទបញ្ជា ០១បប បាននិយាយថា សហគមន៍របស់ពួកគេមិនពេញចិត្តជាមួយ ០១បប នោះទេ ពីព្រោះថានិសិត្សស្ម័គ្រចិត្ត ឬអាជ្ញាធរមូលដ្ឋាន បានគំរាមកំហែង ឬបង្ខិតបង្ខំពួកគេ នៅក្នុងដំណើរការអនុវត្តបទបញ្ជា ០១បបនេះ។ គោលនយោបាយនេះ បានធ្វើអោយសហគមន៍ មានអារម្មណ៍ថា បើសិនជាពួកគេមិនជ្រើសរើសយកកម្មសិទ្ធិឯកជន ពួកគេនឹងបាត់បង់ដីរបស់ពួកគេទៅឲ្យក្រុមហ៊ុន ឬក៏រដ្ឋាភិបាលហើយ។

អ្នកភូមិបាននិយាយដដែលៗនូវពាក្យសំដីដែលចេញមកពីក្រុមនិសិត្សស្ម័គ្រចិត្ត "ភូមិរបស់លោកអ្នកស្ថិតនៅក្នុងដីរបស់រដ្ឋ ហើយបើសិនជាលោកអ្នកមិនព្រមទទួលយកដីកម្មសិទ្ធិឯកជន ដីនេះនឹងត្រូវប្រគល់ទៅអោយរដ្ឋវិញ"។ និសិត្សស្ម័គ្រចិត្ត បានប្រាប់ទៅអ្នកភូមិថា ពួកគេអត់មានសិទ្ធិស្របច្បាប់លើដីរបស់គេនោះទេ។ ចាស់ទុំម្នាក់នៅភូមិទៀមក្រោម បាននិយាយថា ក្រុមនិសិត្សបានធ្វើការប្រៀបធៀបសហគមន៍របស់ពួកគាត់ទៅនឹងរបបប៉ុលពត ដោយធ្វើការប្រៀបធៀបដីសហគមន៍ទៅនឹងដីសមូហភាពសម្រាប់ធ្វើកសិកម្ម។ ក្រុមនិសិត្សបានប្រាប់ទៅសហគមន៍៖ "ដីសមូហភាពនេះ ដូចកាលពីសម័យប៉ុលពតអញ្ចឹង

ហើយបើសិនជាលោកអ្នក ចង់រក្សាទុកការប្រើប្រាស់ដីរបស់លោកអ្នករបៀបនេះ លោកអ្នកចង់ឲ្យប្រទេសរបស់យើងត្រលប់ទៅសម័យប៉ុលពតវិញហើយ"។

ការគំរាមកំហែង មិនមែនមកតែពីក្រុមនិសិត្យស្ម័គ្រចិត្តនោះទេ ប៉ុន្តែមកពីខាងអាជ្ញាធរមូលដ្ឋានផងដែរ។ អ្នកភូមិបាននិយាយជាច្រើនលើក អំពីពាក្យសំដីរបស់ ក្រុមប្រឹក្សាឃុំ គណអភិបាលស្រុក និងខេត្ត ដែលបានប្រាប់ទៅអ្នកភូមិះ "បើសិនជាបងប្អូនមិនរើសយកកម្មសិទ្ធិដីឯកជន ហើយមានទំនាស់ជាមួយក្រុមហ៊ុន ទៅថ្ងៃអនាគត យើងនឹងមិនទទួលខុសត្រូវក្នុងការដោះស្រាយបញ្ហានេះទេ" ។ ពាក្យសំដីនេះ បានធ្វើឲ្យសហគមន៍ជឿថា យន្តការក្នុងការដោះស្រាយជម្លោះមិនមានសម្រាប់ពួកគេនោះទេ ហើយមានតែ ០១បបតែប៉ុណ្ណោះដែលជាដំណោះស្រាយក្នុងការ ការពារដីរបស់ពួកគេប្រឆាំងទៅនឹងក្រុមហ៊ុន។

មិនមែនមានតែសមាជិកសហគមន៍តែប៉ុណ្ណោះទេ ដែលទទួលការគំរាមកំហែងនៅក្នុងពេលអនុវត្តបទបញ្ជា០១បប អាជ្ញាធរមូលដ្ឋាន បានប្រាប់ទៅថ្នាក់ដឹកនាំអង្គការក្រៅរដ្ឋាភិបាល សូមឲ្យផ្អាកសកម្មភាពចុះបញ្ជីនៅក្នុងភូមិគោលដៅណា ដែលមានការប្រកាសអនុវត្តបទបញ្ជា ០១បប ដើម្បី "ជៀសវាង ការមានបញ្ហាជាមួយក្រុមនិសិត្យស្ម័គ្រចិត្ត "។ អង្គការក្រៅរដ្ឋាភិបាលមួយ បានចូលទៅក្នុងភូមិគោលដៅរបស់ខ្លួន ដើម្បីបន្តការសម្របសម្រួលការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាព ហើយអង្គការនេះ ត្រូវបានកោះហៅដោយគណអភិបាលខេត្ត ដើម្បីឆ្លើយសំណួរមួយចំនួន។ រឿងនេះ កើតមានឡើងតែនៅក្នុងខេត្តរតនគិរីតែប៉ុណ្ណោះ នៅពេលដែលអង្គការក្រៅរដ្ឋាភិបាលចូលទៅក្នុងភូមិគោលដៅ ក្នុងពេលជាមួយគ្នានៃដំណើរការអនុវត្តបទបញ្ជា ០១បប ក្រៅពីនោះអង្គការផ្សេង ក៏អនុវត្តតាមបទបញ្ជារបស់រដ្ឋាភិបាលដើម្បីអោយមានកិច្ចសហការល្អ ជាមួយរដ្ឋាភិបាលទៅអនាគត។

## V. ផលប៉ះពាល់នៃបទបញ្ជា០១បប

ដូចដែលលទ្ធផលនៃការស្រាវជ្រាវបានបង្ហាញ បទបញ្ជា០១បប បានបង្កជាបញ្ហាជាច្រើនដែលបានប៉ះពាល់ដល់ជនជាតិដើមភាគតិច និងដីធ្លីរបស់ពួកគេនៅខេត្តរតនគីរី។ ជនជាតិដើមភាគតិច អង្គការក្រៅរដ្ឋាភិបាល និងមន្ត្រីរដ្ឋាភិបាលថ្នាក់មូលដ្ឋាន រំពឹងថា ការប៉ះពាល់នៃគោលនយោបាយដូចដែលបានអនុវត្តនេះ នាពេលបច្ចុប្បន្ននឹង(១)បណ្តាលឲ្យបាត់បងដីរបស់ជនជាតិដើមភាគតិច ការចិញ្ចឹមជីវិត អត្តសញ្ញាណ និងវប្បធម៌ (២)ធ្វើឲ្យសហគមន៍បែកបាក់គ្នា (៣) បង្កើនភាពស្មុគស្មាញ កង្វះការចុះសម្រុងគ្នា និងនាំឲ្យច្របូកច្របល់ ក្នុងក្របខណ្ឌច្បាប់ភូមិបាល និង(៤)បង្កជាទំនាស់ដីធ្លីឥតឈប់ឈរ។

### ១–ឯកជនភាវូបនីយកម្មនាំឲ្យបាត់បងដីនិងការចិញ្ចឹមជីវិត

គោលបំណងដំបូងរបស់បទបញ្ញា០១បប គឺដើម្បីវាស់វែងដីធ្លីមានទំនាស់ និងប្រគល់ដីនោះ ឲ្យស ហគមន៍វិញ ដែលនេះអាចជួយដោះស្រាយទំនាស់ដែលកំពុងកើតមានឡើង និងជួយទ្រទ្រង់ការចិញ្ចឹមជិវិត របស់ជនជាតិដើមភាគតិច ប៉ុន្តែនេះមិនមែនជាអ្វីដែលគោលនយោបាយបានអនុវត្តទេ។ ផ្ទុយទៅវិញ បទ បញ្ញា០១បប បានបង្កើនឯកជនភាវូបនីយកម្មដីធ្លី នៅក្នុងសហគមន៍ជនជាតិដើមភាគតិច និងបង្កឲ្យមាន ការបាត់បង់ដី។ ភូមិទាំង៣១ ដែលមានឈ្មោះក្នុងលិខិត និងជាគោលដៅរបស់បទបញ្ញា០១បប នៅខេត្ត រតនគីរី ជាជនជាតិដើមភាគតិចដំបូង ហើយទោះបីជាពត៌មានមិនបានប្រមូលមកពីភូមិទាំងអស់ដែល ទទួលរងការប៉ះពាល់ពីគោលនយោបាយនេះក៏ដោយ ក៏ក្នុងភូមិចំនួន២៦ដែលយើងបានសម្ភាស គ្រួសារ លើសពីពាក់កណ្តាល(៥២%)បានត្រូវគេវាស់វែងដីសម្រាប់កម្មសិទ្ធិឯកជនដែលសរុបមាន១៥៨៦គ្រួសារ។

ជនជាតិដើមភាគតិច អង្គការក្រៅរដ្ឋាភិបាលដែលធ្វើការលើការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាព និងមន្ត្រីរដ្ឋាភិបាលថ្នាក់មូលដ្ឋាន បានទទួលស្គាល់ថា ឯកជនភាវូបនីយកម្មដីធ្លី ដែលកំពុងកើតឡើង និង ជាលទ្ធផលនៃបទបញ្ញា០១បប គឺមិនសមស្របទៅនឹងបរិបទរបស់ជនជាតិដើមភាគតិចទេ។ បងប្អូនជន ជាតិដើមភាគតិចភាគច្រើន មានបំណងចង់ថែរក្សាដីសមូហភាពរបស់សហគមន៍ និងធានាកុំឲ្យមានការ បាត់បង់ដី ជាមួយកម្មសិទ្ធិសមូហភាព។ បងប្អូនជនជាតិដើមភាគតិចបញ្ជាក់ថា ឥឡូវនេះ សហគមន៍ពួក គេត្រូវ ″បែកបាក់‟គ្នា ដោយសារឯកជនភាវូបនីយកម្ម ហើយបើយោងតាមរដ្ឋមន្ត្រីនៃក្រសួងដែនដី នគររូប នីយកម្មនិងសំណង់ នាពេលឥឡូវពួកគេនឹងមិនអាចទទួលបានកម្មសិទ្ធិសមូហភាពទេ។ របៀបរស់នៅ តាមបែបបុរាណរបស់បងប្អូនជនជាតិដើមភាគតិច មិនត្រូវបានក្រុមនិស្សិតស្ម័គ្រចិត្តស្គាល់ទេ ដោយសារ និស្សិតស្ម័គ្រចិត្តមិនបានទទួលការបណ្តុះបណ្តាលលើជនជាតិដើមភាគតិច នេះបើយោងតាម មន្ត្រីរដ្ឋាភិបា លមកពីស្រុកលំផាត់។

ពេលចុះសិក្សាស្រាវជ្រាវ ភាគីពាក់ព័ន្ធទាំងអស់ទទួលស្គាល់ថា សហគមន៍ដែលបានយល់ព្រមកម្ម សិទ្ធិឯកជន កំពុងស្ថិតក្នុងគ្រោះថ្នាក់ក្នុងការបាត់បង់ដីសហគមន៍របស់គេទៅឲ្យក្រុមហ៊ុន។ ក្រុមប្រឹក្សាខេត្ត រតនគីរីបានហៅគោលនយោបាយនេះថា “មិនសមស្របនឹងស្ថានភាពជនជាតិដើមភាគតិច” ពីព្រោះឯកជ នភាវូបនីយកម្មគឺបន្តស្ថានភាពពីមុនក្នុងការប្រគល់ដីសហគមន៍ដល់ក្រុមហ៊ុន។

#### ក–ការលក់ដីដោយបង្ខិតបង្ខំ

ឯកជនភាវូបនីយកម្មដីធ្លី តែងតែបង្កឲ្យមានការបាត់បង់ដីរបស់ជនជាតិដើមភាគតិច ដោយសារ ការលក់ដីដោយបង្ខិតបង្ខំ។ ពេលដែលគ្រួសារខ្លះ នៅក្នុងសហគមន៍ជនជាតិដើមភាគតិច សំរេចចិត្តទទួល យកដីជាលក្ខណៈឯកជន ការលក់ដីទំនងជាបានធ្វើហើយ។ បងប្អូនជនជាតិដើមភាគតិចភាគច្រើនដែល

រស់នៅក្នុងតំបន់សម្បទានដីសេដ្ឋកិច្ច បានលើកឡើងថា ពួកគេទីទ័លក្រ ជំពាក់បំណុល និងស្ថិតក្នុងការគាបសង្កត់ផ្នែកសេដ្ឋកិច្ចដ៏ខ្លាំងបំផុត។ ក្រុមហ៊ុន អាចប្រើប្រាស់លុយនិងអំណាច ដើម្បីបង្ខំពួកគេឲ្យលក់ដីក្នុងតំលៃមួយដែលមិនសមស្រប។ ចាស់ទុំក្នុងភូមិទទួលស្គាល់ថា នេះទំនងជាមានគ្រួសារជាច្រើនដែលមានកម្មសិទ្ធិឯកជន នឹងលក់ដីពួកគេក្រោមតំលៃទីផ្សារ ដោយគ្មានដំណោះស្រាយផ្សេង ឬលទ្ធភាពដើម្បីតាំងលំនៅថ្មី។

បងប្អូនជនជាតិដើមភាគតិចភាគច្រើន បន្តចង់បានដីជាកម្មសិទ្ធិសមូហភាព ដូច្នេះពួកគេអាចបង្កើតវិន័យផ្ទៃក្នុងលើការលក់ដី និងបញ្ហាសការលក់ដីដោយបង្ខិតបង្ខំ។ ពួកគេទទួលស្គាល់ថា ការលក់ដីអាចប៉ះពាល់ដល់សហគមន៍ទាំងមូល។ ដោយសារដីធ្លីរបស់គ្រួសារនីមួយៗ ក្នុងភូមិជនជាតិដើមភាគតិចបានចែកជាភាគតូចៗ និងលក់ឲ្យក្រុមហ៊ុនបន្តិចម្តងៗ រចនាសម្ពន័របស់សហគមន៍ខ្សោយ និងនេះធ្វើឲ្យក្រុមហ៊ុនអាចរំលោភលើដីប្រជាជនផ្សេងទៀត។ ការធ្វើបែបនេះនាំឲ្យប្រជាជនផ្សេងទៀតប្រឈមនឹងការពឹតដែលពួកគេគ្មានជំរើស ប៉ុន្តែត្រូវតែលក់ដី។

ទោះបីជាទំនងថា ជនជាតិដើមភាគតិចខ្លះប្រហែលជាបានជ្រើសរើសកម្មសិទ្ធិឯកជន ពីព្រោះពួកគេចង់បានសេរីភាពក្នុងការលក់ដីរបស់គេ រឿងនេះ មិនមែនជាលទ្ធផលនៃការសិក្សាស្រាវជ្រាវយើងទេ។ ឯកជនភាវូបនីយកម្ម ប្រហែលជាបណ្តាលមកពី ការគាបសង្កត់ខាងក្រៅយ៉ាងលើសលប់ ពីក្រុមហ៊ុន លើដីជនជាតិដើមភាគតិច ការផ្តល់ពត៌មានខុស ការគំរាមកំហែង និងការបង្ខិតបង្ខំ។ ពេលដែលយើងសួរប្រជាជននៅភូមិថា តើពួកគេជ្រើសរើសកម្មសិទ្ធិឯកជន ដោយសារថាពួកគេប្រហែលជាចង់លក់ដីរបស់គេ អ្នកភូមិដែលបានសម្ភាសទាំងអស់ឆ្លើយ៖ “អត់ទេ” ។ អ្នកភូមិម្នាក់ មកពីភូមិទាមក្រោមនិយាយ៖ “អត់ទេ ហេតុអ្វីខ្ញុំចង់លក់ដីខ្ញុំ? បើសិនជាខ្ញុំលក់ដីខ្ញុំ ខ្ញុំគ្មានកន្លែងណាដែលត្រូវទៅទេ”។ គាត់បានពន្យល់៖ “ខ្ញុំអាចលក់ម៉ូតូមួយ ឬបោះចោលដីមួយដុំជាមួយលុយ ប៉ុន្តែពេលក្រោយខ្ញុំមិនអាចមានលុយគ្រប់គ្រាន់ ដើម្បីទិញដីថ្មីទេ”។ លោកយាយម្នាក់ មកពីភូមិទាមក្រោម បានទទួលស្គាល់ថា បើសិនជាគាត់ចង់បានលុយសម្រាប់អ្វីមួយ គាត់នឹងលក់ក្របីមួយវិញ “ពីព្រោះយើងមានក្របីច្រើនក្បាល ប៉ុន្តែ យើងមានដីតែមួយទេ” ។ ពួកគេទទួលស្គាល់ថាប្រជាជនខ្លះគ្មានជំរើស ដូច្នេះត្រូវលក់ដីគេឲ្យក្រុមហ៊ុនដែលមានអំណាចជាង។

## ខ–ការបាត់បង់របរចិញ្ចឹមជីវិត

កម្មសិទ្ធិដីឯកជន មិនសមស្របសម្រាប់សហគមន៍ជនជាតិដើមភាគតិចទេដែលប្រាថ្នាចង់រក្សាដីសហគមន៍របស់គេ និងវិធីសាស្រ្តធ្វើកសិកម្មតាមបែបបុរាណ ប៉ុន្តែដីតិចតួចដែលបានផ្តល់ឲ្យដោយគោលនយោបាយថ្មី នឹងប្រហែលជាមិនសមរម្យសម្រាប់គ្រួសារណាដើម្បីធ្វើកសិកម្មចិញ្ចឹមជីវិតទេ។ ជនជាតិដើមភាគតិច ទទួលស្គាល់ថាចំនួនអតិប្បរមាប្រាំហិកតា គឺតិចតួចណាស់សម្រាប់គ្រួសារគេ និងមិនគ្រប់គ្រាន់សម្រាប់គេក្នុងការចិញ្ចឹមជីវិតទេ។ គ្រួសារជាច្រើន ទទួលបានដីតិចជាងប្រាំហិកតា។ ឧទាហរណ៍ នៅភូមិសមុទ្រលើ គ្រួសារខ្លះទទួលបានតិចតួចដូចជា០.៤ហិកតា។ គ្រួសារជនជាតិដើមភាគ

តិចបានបញ្ជាក់ថា បើសិនជានេះជាមានតែដីតិចតួចប៉ុន្នេះដើម្បីដាំដុះ ពួកគេប្រហែលគ្មានជំរើសទេ ត្រូវតែលក់ដីទៅក្រុមហ៊ុនដែលនៅជិតនោះ ដើម្បីព្យាយាមរកលំនៅថ្មី។

## ២–សហគមន៍ដែលបែកបាក់សាមគ្គី

ដំណើរការនៃបទបញ្ជា០១បប និងលទ្ធផលនៃឯកជនភាវូបនីយកម្ម បានបង្កើតជាការបែកបាក់សាមគ្គីនៅក្នុងសហគមន៍ដែលមានការរួបរួមគ្នាពីមុន។ ទោះជាភូមិដែលទទួលរងដោយបទបញ្ជា០១បប បានរួបរួមគ្នា ខំប្រឹងប្រែងដើម្បីស្នើរសុំកម្មសិទ្ធិដីសមូហភាពក៏ដោយ ក៏ដំណើរការនៃបទបញ្ជា០១បបបានបង្កជាការខ្វែងគំនិតគ្នាថា តើត្រូវរងចាំកម្មសិទ្ធិដីសមូហភាព ឬទទួលយកកម្មសិទ្ធិដីឯកជនឥឡូវនេះ។

ឯកជនភាវូបនីយកម្មដែលបានកើតឡើង ជាលទ្ធផលនៃបទបញ្ជា០១បប ក៏បានបង្កនូវការខ្វែងគំនិតគ្នាក្នុងសហគមន៍។ ក្នុងភូមិខ្លះដែលមានតែគ្រួសារតិចភាគរយប៉ុណ្ណោះដែលបានជ្រើសរើសការវាស់វែងដីដោយបទបញ្ជា០១បប ប្រជាជនដែលជ្រើសរើសកម្មសិទ្ធិសមូហភាពនិយាយថា ពួកគេនឹងមិនអនុញ្ញាតឲ្យ ប្រជាជនក្នុងភូមិដែលជ្រើសរើសកម្មសិទ្ធិឯកជន ចូលរួមក្នុងដំណើរការសុំកម្មសិទ្ធិសមូហភាពនាពេលក្រោយទេ។ ចាស់ព្រឹទ្ធាចារ្យម្នាក់និយាយថា បើសិនគ្រួសារណាដែលបានជ្រើសរើសកម្មសិទ្ធិឯកជនប្តូរចិត្ត និងចង់បានកម្មសិទ្ធិសមូហភាពវិញ ក៏គេមិនអនុញ្ញាតឲ្យចូលរួមដែរ ដោយសារថាគ្រួសារទាំងនោះ អាចបំផ្លាញសំណាងសហគមន៍ក្នុងការទទួលបានកម្មសិទ្ធិដីសមូហភាព។

## ៣–បង្កើនភាពស្មុគស្មាញផ្នែកគតិយុត្តិ

ការផ្លាស់ប្តូរគោលនយោបាយជាញឹកញាប់ដែលបានធ្វើឡើងក្រោយបទបញ្ជា០១បប និងការប្រាប់ពត៌មានខុស ក្នុងពេលអនុវត្តន៍បទបញ្ជា បានបង្កឲ្យមានភាពស្មុគស្មាញផ្នែកគតិយុត្ត និងចុងក្រោយបង្កើតជាភាពច្របូកច្របល់ ក្នុងភូមិរបស់ជនជាតិដើមភាគតិច។ បទបញ្ជានេះ មិនបានទទួលស្គាល់សិទ្ធិរបស់ជនជាតិដើមភាគតិចទៅលើដីសមូហភាពទេ ហើយក្នុងការអនុវត្តជាក់ស្តែង ធ្វើឲ្យអន្តរាយនិងបញ្ជាសការប្រើសិទ្ធិពេញលេញរបស់ជនជាតិដើមភាគតិច។ ទោះបីជាច្បាប់ភូមិបាលឆ្នាំ២០០១ និងច្បាប់អន្តរជាតិ បានចែងពីសិទ្ធិប្រពៃណីរបស់ជនជាតិដើមភាគតិចក្នុងការថែរក្សាដីសមូហភាពក៏ដោយ[24] ក៏ដំណើរការនៃការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពត្រូវបានបញ្ឈប់ ពេលដែលឯកជនភាវូបនីយកម្មបន្សល់ដែលកាន់ទុកនៅដីសហគមន៍ដែលដុនដាបទៅឲ្យក្រុមហ៊ុន។ ការខ្វះតម្លាភាពចំពោះការផ្លាស់ប្តូរផ្នែកគតិយុត្ត ចាប់ពីពេល

[24] សូមមើលច្បាប់ភូមិបាលឆ្នាំ២០០១ និង សេចក្តីសំរេចរបស់រាជរដ្ឋាភិបាលកម្ពុជា លេខ ០៩២/០០៣/២០០៧

ចាប់ផ្ដើមបទបញ្ញា០១បប និងក្រោយមកប្រទាស់នឹងក្របខ័ណ្ឌច្បាប់ភូមិបាល និងបង្កឲ្យជនជាតិដើមភាគតិចទទួលពត៌មានបានតិចតួចចំពោះសិទ្ធិរបស់ពួកគេ។

### ៤–ទំនាស់ដីធ្លីមានជាបន្តបន្ទាប់

ទោះបីជាសេចក្ដីណែនាំលេខ០១៨ចែងថា មានតែ"ដីដែលកាន់កាប់ពឹតប្រាកដដោយប្រជាជន និងមិនមែនជាដីក្នុងទំនាស់ ដែលអាចធ្វើការស្ទង់មតិបាន"។ ភូមិចំនួន២៥ ក្នុងចំណោមភូមិទាំង២៦ដែលបានវាស់វែងដោយបទបញ្ញា០១បប នៅក្នុងការសិក្សានេះមានជម្លោះដីធ្លីជាមួយក្រុមហ៊ុន។ ការអនុវត្តបទបញ្ញា០១បប មិនបានដោះស្រាយទំនាស់ជនជាតិដើមភាគតិចជាមួយនឹងក្រុមហ៊ុនទេ ប៉ុន្តែបានបង្អាក់យន្តការនានា ក្នុងការដោះស្រាយទំនាស់ដែលមានស្រាប់ហើយ។ ក្រុមនិស្សិតស្ម័គ្រចិត្ត ខ្វះពត៌មាន ខ្វះការបណ្ដុះបណ្ដាល និងធនធាន ដើម្បីដោះស្រាយទំនាស់ដ៏ស្មុកស្មាញទាំងនេះ។ មន្ត្រីរដ្ឋាភិបាលថ្នាក់មូលដ្ឋានមកពីស្រុកលំផាត់បាននិយាយថា ឧបករណ៍របស់ក្រុមនិស្សិតស្ម័គ្រចិត្តចុះមកដោះស្រាយទំនាស់ មានតែផែនទីសម្បទានដីសេដ្ឋកិច្ចផ្ដល់ដោយថ្នាក់ជាតិ និងក្បាលដីជាបុគ្គលរបស់អ្នកភូមិដែលបានដាំដុះដំណាំ និងត្រួសត្រាយដីហើយ។ សមាជិកក្រុមប្រឹក្សាឃុំបានលើកឡើង៖ "យើងបានទទួលការណែនាំពីថ្នាក់លើកុំឲ្យសួរអ្នកភូមិ ពីជម្លោះពួកគេជាមួយក្រុមហ៊ុន ក្នុងពេលដែលក្រុមនិស្សិតស្ម័គ្រចិត្តធ្វើការវាស់ដី"។

អ្នកភូមិបាននិយាយថា បទបញ្ញា០១បប មិនបានសម្រេចក្នុងការដោះស្រាយជម្លោះដីធ្លីជាមួយក្រុមហ៊ុនទេ។ ភូមិជាច្រើន ដែលបានធ្វើការប្ដឹងតវ៉ានឹងក្រុមហ៊ុននៅតុលាការខេត្តរតនគីរី បានត្រូវកំណត់ក្បាលដីដោយបទបញ្ញា០១បប ពេលដែលក្រុមនិស្សិតស្ម័គ្រចិត្តបានបង្ខិតបង្ខំភូមិនានាឲ្យដោះស្រាយទំនាស់ ប៉ុន្តែការប្ដឹងតវ៉ានៅតែមិនទាន់ដោះស្រាយនៅឡើយ។ អ្នកតំនាងមកពីភូមិកាឡៃតាវែង និងភូមិកាឡៃសពុន បានទទួលស្គាល់៖ "យើងមិនបានដឹងថាត្រូវដោះស្រាយជម្លោះខ្លួនឯងយ៉ាងដូចម្ដេចទេហើយ ក្រុមហ៊ុនមិនស្ដាប់អ្វីដែលយើងនិយាយទេ" ។

អ្នកភូមិខ្លះបានកត់សម្គាល់ថា ក្រុមហ៊ុនបានប្រមូលយកដីសមូហភាពកាន់តែច្រើន ចាប់ពីពេលគេផ្ដល់កម្មសិទ្ធិឯកជន នឹងបង្កឲ្យទំនាស់កាន់តែធ្ងន់ឡើង។ អ្នកភូមិដែលបានទទួលការវាស់វែងដីកម្មសិទ្ធិឯកជនថ្លែងថា ពួកគេនឹងបន្តប្រើដីសមូហភាពរបស់ពួកគេ ទោះបីជាត្រូវប្រឈមនឹងការប្រឆាំងពីថ្នាក់លើក៏ដោយ។ មេភូមិម្នាក់បាននិយាយ៖ "ភូមិខ្ញុំចង់បានកម្មសិទ្ធិសមូហភាព ប៉ុន្តែប្រហែលជាខ្ញុំគួរតែរកអ្នកណាម្នាក់នៅក្នុងភូមិ ជាអ្នកនាំមុខផ្តួចផ្តើម ដោយសារខ្លាចមានបញ្ហាដល់ជីវិតខ្ញុំ."។ ក្រោយពេលដែលក្រុមនិស្សិតស្ម័គ្រចិត្តចុះវាស់វែងក្បាលដីសម្រាប់កម្មសិទ្ធឯកជន ទំនាស់ដីធ្លីជាមួយនឹងក្រុមហ៊ុនឯកជនមិនបានចាកចេញឆ្ងាយទេ។

## VI. អនុសាសន៍

អ្នកភូមិដែលទទួលរងការប៉ះពាល់ដោយសារបទបញ្ជា០១បប និងក្រុមការងារការដែលធ្វើការលើចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពខេត្តរតនគីរី(CLT-WG) សូមផ្តល់នូវអនុសាសន៍ជាច្រើនសម្រាប់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីដោះស្រាយបញ្ហាដ៏ចំបង និងការប៉ះពាល់ខូចខាតរបស់បទបញ្ជា០១បប។

- *ទទួលស្គាល់ថាការផ្តល់កម្មសិទ្ធិដីឯកជន គឺមិនសមស្របសម្រាប់សហគមន៍ជនជាតិដើមភាគតិចនៅក្នុងខេត្តរតនៈគីរី។* ភាគីពាក់ព័ន្ធដទៃទៀត គួរតែធ្វើតាមសំណើររបស់ជនជាតិដើមភាគតិចនិងការទទួលស្គាល់ថាការផ្តល់កម្មសិទ្ធិដីឯកជន គឺសមស្របសម្រាប់សហគមន៍ជនជាតិដើមភាគតិចទេ។

- *ការអប់រំយ៉ាងពេញលេញប្រកបដោយតម្លាភាពដល់សហគមន៍៖* រាជរដ្ឋាភិបាលកម្ពុជា គួរតែធានាថាក្រុមនិស្សិតស្ម័គ្រចិត្តផ្សព្វផ្សាយពត៌មានឲ្យបានគ្រប់គ្រាន់ ទៅដល់ភូមិដែលទទួលរងការប៉ះពាល់ រួមមានការអប់រំលើបទបញ្ជា០១បប ដីជាកម្មសិទ្ធិសមូហភាព និងដីកម្មសិទ្ធិឯកជន ព្រមទាំងធានាថាអ្នកភូមិដឹងពី ចំណុចល្អនិងចំណុចមិនល្អរបស់ប្រភេទកម្មសិទ្ធិនីមួយៗ។ អង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិល ក៏គួរតែចូលរួមចំណែក ដើម្បីធានាការផ្សព្វផ្សាយពត៌មានប្រកបដោយតម្លាភាព និងការអប់រំដល់អ្នកភូមិលើបទបញ្ជា០១បប និងលក្ខណៈខុសគ្នារវាងកម្មសិទ្ធិដីសមូហភាពនិងកម្មសិទ្ធិដីឯកជន។

- *ការអប់រំយ៉ាងពេញលេញដល់និស្សិតស្ម័គ្រចិត្ត៖* និស្សិតស្ម័គ្រចិត្តដែលបញ្ជូនដោយបទបញ្ជា០១បបទៅខេត្តរតនគីរី មិនបានទទួលការបណ្តុះបណ្តាល ពីការចិញ្ចឹមជីវិត និងវប្បធម៌របស់ជនជាតិដើមភាគតិចទេ។ ដោយសារថានិស្សិតស្ម័គ្រចិត្តមកពីភ្នំពេញ និងមិនដែលបានដឹងពីជនជាតិដើមភាគតិចទេ ឬ ភាពខុសគ្នារវាងកម្មសិទ្ធិសមូហភាពនិងកម្មសិទ្ធិឯកជន និងថាតើអ្វីទាំងនេះនឹងប៉ះពាល់យ៉ាងដូចម្តេចដល់ការចិញ្ចឹមជីវិតរបស់ជនជាតិដើមភាគតិច រាជរដ្ឋាភិបាលកម្ពុជាគួរតែធ្វើការនៅថ្នាក់ជាតិនិងថ្នាក់មូលដ្ឋាន ដើម្បីធានាថានិស្សិតស្ម័គ្រចិត្ត ទទួលបានការបណ្តុះបណ្តាលយ៉ាងពេញលេញទាក់ទងនឹងជនជាតិដើមភាគតិច។ អង្គការក្រៅរដ្ឋាភិបាល គួរតែចូលរួមចំណែកក្នុងដំណើរការនៃការបណ្តុះបណ្តាលនិស្សិតស្ម័គ្រចិត្ត ដើម្បីធានាឲ្យបានការអប់រំយ៉ាងពេលលេញនិងឥតលំអៀង។

- *ការបិទផ្សាយប្រកបដោយតម្លាភាពនូវកម្មសិទ្ធិដីឯកជន៖* អាជ្ញាធរមូលដ្ឋាន គួរតែធ្វើការធានាថាអ្នកភូមិដឹងពី ពេលវេលានិងទីកន្លែង ជាពិសេស ថ្ងៃខែពីតប្រាកដ និងទីកន្លែងជាក់លាក់ ដែលគេបិទផ្សាយកម្មសិទ្ធិដីឯកជន និងផ្តល់ឲ្យអ្នកភូមិនូវកាលានុវត្តភាពល្អជាងមុន ក្នុងការទទួលយល់

ព្រម ឬបដិសេធកម្មសិទ្ធិ។ ការពិតមួយទៀត គឺអ្នកភូមិខ្លះ មិនអាចអានភាសាខ្មែរបាន ហើយតម្រូវឲ្យរកដំណោះស្រាយសម្រាប់ចំណុចនេះ។

– *ធានាឲ្យបានការអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវបទបញ្ជា០១បបៈ* រាជរដ្ឋាភិបាលកម្ពុជា និងមន្ត្រីរដ្ឋាភិបាលថាថ្នាក់មូលដ្ឋាន គួរតែធ្វើការដើម្បីធានាឲ្យបានការអនុវត្តយ៉ាងខ្ជាប់ខ្ជួននិងត្រឹមត្រូវជាងមុន នូវបទបញ្ជា០១បប ស្របទៅតាមច្បាប់ ដូចដែលបទបញ្ជាបានបង្កើតឡើងនាពេលដំបូង និងដើម្បីសម្រេចគោលបំណងនៃការធានាសុវត្ថិភាពដីធ្លីរបស់ជនជាតិដើមភាគតិច។

– *វាស់វែងដីធ្លីទាំងអស់រួមទាំងដីសមូហភាពៈ* នៅបទបញ្ជា០១បបដំបូង រាជរដ្ឋាភិបាលកម្ពុជាបានលើកឡើងថា បទបញ្ជាមានគោលបំណងលើកកំពស់សុវត្ថិភាពដីធ្លី សម្រាប់ជនជាតិដើមភាគតិច និងប្រគល់ដីសមូហភាពដល់អ្នកភូមិវិញ។ រាជរដ្ឋាភិបាលកម្ពុជា គួរតែប្រើប្រាស់បទបញ្ជា០១បប ដើម្បីវាស់វែងដីសមូហភាព រួមទាំងព្រៃអារក្សដែលគេគោរពបូជា ព្រៃឈើជាទីកន្លែងបូជាសពក្បាលដីពនាចរដែលមានទំនាស់ជាមួយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ហើយប្រគល់ដីទាំងអស់ទៅដល់សហគមន៍ជនជាតិដើមភាគតិចវិញ។

– *និតិវិធីធ្វើការមានការសហការណ៍ជាងមុនៈ* មន្ត្រីរដ្ឋាភិបាលថ្នាក់មូលដ្ឋាន គួរតែធ្វើការដើម្បីធានាឲ្យបានថាទំនាក់ទំនង រវាងនិស្សិតស្ម័គ្រចិត្ត ភូមិដែលទទួលរងការប៉ះពាល់ និងអង្គការក្រៅរដ្ឋាភិបាល មានលក្ខណៈសហការណ៍និងផ្តល់ពត៌មាន មានសម្ពាធតិចតួចជាងមុន និងស្របទៅនឹងនិតិវិធីនៃការសម្រេចចិត្ត ដែលមានការព្រមព្រៀងគ្នាជាមូលដ្ឋាន ដែលបានប្រើដោយសហគមន៍ជនជាតិដើមភាគតិចរួចហើយ។ អង្គការក្រៅរដ្ឋាភិបាល ក៏គួរតែត្រូវបានអនុញ្ញាតឲ្យបន្តគម្រោងរបស់ខ្លួន នៅក្នុងភូមិគោលដៅទាំងអស់ដែរ។

– *ការផ្លាស់ប្តូរគោលនយោបាយដោយតម្លាភាពៈ* អង្គការក្រៅរដ្ឋាភិបាលនានា និងអ្នកភូមិ នៅតែមិនបានទទួលពត៌មាន ពីស្ថានភាពថ្មីៗនៃបទបញ្ជា០១បប។ អង្គការក្រៅរដ្ឋាភិបាលមិនដឹងច្បាស់ថា តើភូមិណានិស្សិតស្ម័គ្រចិត្តមានគម្រោងផ្តល់កម្មសិទ្ធិ ហើយអ្នកភូមិក៏មិនដឹងច្បាស់ថា តើកម្មសិទ្ធិឯកជន អាចប្តូរទៅជាកម្មសិទ្ធិសមូហភាពបានរឺទេ ឬ តើជាការល្អ រឺមិនល្អក្នុងការយល់ស្របតាម ឬបដិសេធលទ្ធផលវាស់វែង។ អជ្ញាធរថ្នាក់ជាតិ មន្ត្រីមូលដ្ឋាន និងនិស្សិតស្ម័គ្រចិត្ត គួរតែធ្វើការដើម្បីធ្វើឲ្យនយោបាយទាំងនេះងាយយល់បានជាងមុន មានតម្លាភាព និងអាចឲ្យជនជាតិដើមភាគតិចទទួលពត៌មានបានឆាប់រហ័ស។

– *អនុញ្ញាតឲ្យអ្នកភូមិអាចប្តូរពីកម្មសិទ្ធិដីឯកជនទៅកម្មសិទ្ធិដីសមូហភាពៈ* សហគមន៍ដែលបានសម្ភាសទាំងអស់ នៅតែចង់បានកម្មសិទ្ធិដីសមូហភាពជាង ដូច្នេះរាជរដ្ឋាភិបាលកម្ពុជាគួរតែធ្វើ

យ៉ាងណាផ្តល់ឱកាសអាចទទួលបាន សម្រាប់ជនជាតិដើមភាគតិចដែលទទួលរងការប៉ះពាល់ពីបទបញ្ជា០១បប ដែលនៅតែប្រាថ្នាចង់បានកម្មសិទ្ធិដីសមូហភាព។

– *សម្របសម្រួលក្របខ័ណ្ឌគតិយុត្តិ៖* រាជរដ្ឋាភិបាលកម្ពុជា គួរតែធ្វើការដើម្បីធានាឲ្យបានថា បទបញ្ជា០១បប សមស្របនឹងក្របខណ្ឌគតិយុត្តិ ដែលគោរពសិទ្ធិដីធ្លីសមូហភាពជាប្រពៃណីរបស់ជនជាតិដើមភាគតិច និងទទួលស្គាល់សិទ្ធិរបស់ជនជាតិដើមភាគតិច ក្នុងការប្រកបរបរកសិកម្មតាមបែបប្រពៃណីលើដីរបស់គេ។

– *គោរពយន្តការនៃការដោះស្រាយជម្លោះដែលមានស្រាប់* ៖ ដោយមានការគោរព ចំពោះក្របខ័ណ្ឌគតិយុត្តិដែលមានស្រាប់ និស្សិតស្ម័គ្រចិត្តគួរតែត្រូវបានដឹកនាំឲ្យវាស់វែងដី ឬដោះស្រាយជម្លោះនៅក្នុងភូមិ ដែលអ្នកភូមិបានដាក់ពាក្យប្តឹងតវ៉ាក្រុមហ៊ុននៅនឹងតុលាការរួយហើយ ឬតាមរយៈយន្តការនៃការដោះស្រាយជម្លោះផ្សេងទៀត។ បញ្ជូនគណៈកម្មាធិការទៅស៊ើបអង្កេតផលប៉ះពាល់នៃបទបញ្ជា០១បប ទៅលើជនជាតិដើមភាគតិច ការចិញ្ចឹមជីវិតរបស់ពួកគេ និងអង្កេតថាតើគោលនយោបាយនេះ បានបំពេញបេសកកម្មរបស់ខ្លួន ក្នុងការដោះស្រាយជម្លោះដីធ្លី និងវាស់ដីធ្លីដែលស្ថិតក្នុងទំនាស់រឺទេ។

– *បង្កើតក្រុមការងារពហុភាគីមួយដើម្បីស៊ើបអង្កេតលើបទបញ្ជា០១បប* ៖ ដំណើរការមានការពិចារណាជាងនេះ និងការស៊ើបអង្កេតលើបទបញ្ជា០១បប គឺចាំបាច់ណាស់ ក៏ដូចជាមានការគាំទ្រជាងមុន ពីថ្នាក់ជាតិសម្រាប់ជនជាតិដើមភាគតិច។ រាជរដ្ឋាភិបាលកម្ពុជា គួរតែបង្កើតក្រុមការងារមួយដែលគាំទ្រដល់ជនជាតិដើមភាគតិច និង ពិនិត្យមើលផលប៉ះពាល់របស់បទបញ្ជា០១បប ដែលរួមមាន រដ្ឋាភិបាល សង្គមស៊ីវិល និងជាពិសេស ជនជាតិដើមភាគតិចគ្រប់ក្រុមជាតិពន្ធទាំងអស់។

– *អញ្ជើញអ្នកជំនាញអន្តរជាតិរបស់អង្គការសហប្រជាជាតិដែលធ្វើការលើជនជាតិដើមភាគតិចនិងជនជាតិភាគតិច មកឆ្លើយតបនឹងបទបញ្ជា០១បប៖* រាជរដ្ឋាភិបាលកម្ពុជា និងសង្គមស៊ីវិលគួរតែអញ្ជើញ អ្នកតំណាងពិសេសរបស់អង្គការសហប្រជាជាតិ មកស៊ើបអង្កេតពីផលប៉ះពាល់របស់បទបញ្ជា០១បប លើជនជាតិដើមភាគតិច។

– *បន្តដំណើការនៃការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាព៖* ដោយសារថា ដីជាកម្មសិទ្ធិសមូហភាពអាចជួយថែរក្សាដីធ្លី ការចិញ្ចឹមជីវិត វប្បធម៌ និងប្រពៃណីរបស់ជនជាតិដើមភាគតិច ហើយជនជាតិដើមភាគតិចត្រូវទទួលបានសិទ្ធិនេះ ស្របតាមច្បាប់ជាតិ រាជរដ្ឋាភិបាលកម្ពុជាគួរតែផ្តល់អទិភាពទៅដល់ការចែកចាយជកម្មសិទ្ធិដីសមូហភាព ទៅឲ្យជនជាតិដើមភាគតិច។ ជំហ៊ានទីមួយដ៏ល្អ គួរតែ

ចេញប្រកាសជាផ្លូវការ បង្អាក់សិននូវដំណើរការដីជាកម្មសិទ្ធិសមូហភាព ពេលដែលកំពុងអនុវត្ត បទបញ្ជា០១បប។

– *ផ្តល់អទិភាពក្នុងការបង្កើនល្បឿននៃដំណើរការនៃការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាព៖* រាជរដ្ឋាភិបាលកម្ពុជានៅថ្នាក់ជាតិ គួរតែចាត់វិធានការឲ្យបានច្បាស់លាស់ ដើម្បីបង្កើនល្បឿនក្នុងដំណើរកាការនៃចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាព ជាពិសេសសម្រាប់ភូមិចំនួន៩៩នៅប្រទេសកម្ពុជា ដែលទទួលបានការទទួលស្គាល់ ជានិតិបុគ្គលដោយក្រសួងមហាផ្ទៃ និងកំពុងរងចាំកម្មសិទ្ធិដីជាសមូហភាពរបស់គេ។

– *ផ្តល់អទិភាពដល់ការកំណត់ផែនទីរបស់ជនជាតិដើមភាគតិច៖* ដើម្បីចំណេញថវិកា និងពេលវេលា រាជរដ្ឋាភិបាលកម្ពុជា គួរតែធ្វើការលើការកំណត់ផែនទីព្រំដែនខាងក្រៅរបស់ភូមិជនជាតិដើមភាគតិច ដែលអាចនឹងត្រូវប្រើប្រាស់ជាធនធាន ក្នុងទំនាស់របស់ជនជាតិដើមភាគតិច ជាមួយក្រុមហ៊ុន និងក្នុងដំណើរការនៃការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាព។

– *ធានាដំណើរការសម្បទានដីសេដ្ឋកិច្ចឲ្យត្រឹមត្រូវតាមច្បាប់៖* រាជរដ្ឋាភិបាលកម្ពុជា គួរតែចាត់វិធានការ ដើម្បីធានាឲ្យបានថា ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចធ្វើការវាយតំលៃផលប៉ះពាល់សង្គម និងបរិដ្ឋាន មុនពេលប្រមូលយកដី សហការជាមួយអ្នកភូមិតាមរយៈយន្តការដ៏ត្រឹមត្រូវ បើសិនជាមានជម្លោះកើតឡើង ហើយសូមឲ្យក្រុមហ៊ុនទទួលខុសត្រូវ ដោយយោងទៅលើគោលបំណងរបស់បទបញ្ជា០១បប។

## ឯកសារយោង


គណៈកម្មាធិការនៃការលុបបំបាត់ការប្រកាន់ពូជសាសន៍ –ការសង្កេតសរុបៈកម្ពុជា CERD/C/KHM/CO/8-13, Apr. 1, 2010, at 16.

ILO—ពត៌មានដែលផ្តល់ឲ្យដោយអង្គការ ILOកម្ពុជា ខែមិនា ឆ្នាំ២០១៣។

*ជនជាតិដើមភាគតិចនិងសិទ្ធិមនុស្សៈ កម្ពុជា*–ក្នុងរបាយការណ៍ស្តីពីជនជាតិដើមភាគតិចនិងសិទ្ធិមនុស្ស នៅអាស៊ីៈ កម្ពុជា ថៃនិងនេប៉ាល់ (២០០៦)។

រាជរដ្ឋាភិបាលកម្ពុជា–ក្រុមប្រឹក្សាជាតិគោលនយោបាយដីធ្លី– *"សេចក្តីណែនាំលេខ២០ ស្តីពីការអនុវត្តបទបញ្ជា០១បបរបស់រាជរដ្ឋាភិបាលកម្ពុជា"* ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២ ទាក់ទងការពង្រឹងនិងបង្កើនប្រសិទ្ធិភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច នៅក្នុងតំបន់សហគមន៍ជនជាតិដើមភាគតិចភាគតិច ចុះថ្ងៃទី២៦កក្កដា ឆ្នាំ២០១២។

រាជរដ្ឋាភិបាលកម្ពុជា–ក្រុមប្រឹក្សាជាតិនៃគោលនយោបាយដីធ្លី–សេចក្តីណែនាំលេខ០១៥ ចុះថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១២ *"សេចក្តីណែនាំស្តីពីការអនុវត្តបទបញ្ជា០១បប របស់រាជរដ្ឋាភិបាលកម្ពុជា"* ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២ ទាក់ទងការពង្រឹងនិងបង្កើនប្រសិទ្ធិភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច នៅក្នុងតំបន់សហគមន៍ជនជាតិដើមភាគតិច ព្រៃស្រោង ពាក់កណ្តាលព្រៃស្រោង ព្រៃឡង់ និងមូលដ្ឋានការពារប្រទេស តំបន់បេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ។

រាជរដ្ឋាភិបាលកម្ពុជា–សេចក្តីសំរេចលេខ០៩២/០០៣/២០០៧ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧។ សេចក្តីសំរេចនេះបញ្ជាក់ពីការអនុវត្តរាល់សន្ធិសញ្ញាសិទ្ធមនុស្សទាំងអស់របស់កម្ពុជា រួមមានការប្រកាសសិទ្ធិមនុស្សជាសកល(UDHR) កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ចនិងវប្បធម៌( ICESCR) កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ(ICCPR) និងពិធីសាមិនបង្ខំរបស់កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ចនិងវប្បធម៌ អនុសញ្ញាអន្តរជាតិស្តីការប្រកាន់គ្រប់ទំរង់ទាំងអស់ចំពោះស្ត្រី(CEDAW) និងអនុសញ្ញាស្តីពីចំរុះភាពនៃរុក្ខជីវសាស្ត្រ(CBD)។

រាជរដ្ឋាភិបាលកម្ពុជា–បទបញ្ជា០១បប ស្តីពីវិធានការពង្រឹងនិងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២។

រាជរដ្ឋាភិបាលកម្ពុជា–សេចក្តីសំរេចលេខ០១៨ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១២ ស្តីពីការធ្វើអត្តសញ្ញាណកម្មដីធ្លី អត្តសញ្ញាណកម្មប្រជាពលរដ្ឋ និងការចេញប័ណ្ណកម្មសិទ្ធបឋម អនុវត្តតាមបទបញ្ជា០១បបរបស់រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២។

រាជរដ្ឋាភិបាលកម្ពុជា–ច្បាប់ភូមិបាល លេខ នស/រកម/០៨ត១ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០១។ អាច អាចរកមើលបាននៅ៖ https://docs.google.com/gview?url=www.opendevelopmentcambodia.net/law/en/Law-on-Land-2001-E.pdf.

រាជរដ្ឋាភិបាលកម្ពុជា–ច្បាប់ស្តីពីការវិនិយោគ–ព្រះរាជក្រម០៣នស ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៩៤។ រកមើលបាននៅ៖https://docs.google.com/gview?url=www.opendevelopmentcambodia.net/law/en/Law-on-investment-E.pdf.

រាជរដ្ឋាភិបាលកម្ពុជា–លិខិតទីស្តីការគណៈរដ្ឋមន្ត្រី លេខ៦៦៦សចន ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១២។ (ជំរាបជូនរដ្ឋមន្ត្រីក្រសួងដែនដី នគររូបនីយកម្ម និងសំណង់ ពីសេចក្តីសំរេចរបស់រដ្ឋាភិបាលក្នុងដំណើរនៃការចុះបញ្ជីដីធ្លីឲ្យរហស័ នៅក្នុងតំបន់គោលដៅដែលត្រូវអនុវត្តបទបញ្ជា០១បប របស់នាយកមន្ត្រី)។

រាជរដ្ឋាភិបាលកម្ពុជា–ក្រសួងមហាផ្ទៃ និងក្រសួងដែនដីនិងនគររូបនីយកម្ម–*សារាចរអន្តរក្រសួងស្តីពីវិធានការការពារជាបណ្តោះអាសន្ន នូវដីដែលសហគមន៍ជនជាតិដើមភាគតិចស្នើសុំចុះបញ្ជីដី និងក្នុងពេលរងចាំការចុះបញ្ជីដីនោះជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ ត្រូវបានបញ្ចប់ទៅតាមនិតិវិធី* ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១។

រាជរដ្ឋាភិបាលកម្ពុជា–*គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច*–ក្រសួងអភិវឌ្ឍន៍ជនបទ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៨។ ចរាចររបស់ក្រសួងអភិវឌ្ឍន៍ជនបទ ស្តីពីនិតិវិធី និងវិធីសាស្រ្តក្នុងការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍ និងផ្តល់អត្តសញ្ញាណដល់សហគមន៍ជនជាតិដើមភាគតិចចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩។

រាជរដ្ឋាភិបាលកម្ពុជា–*ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ២០០៦-២០១០* សម្រាប់ការរីកចម្រើនសមធម៌ និងប្រសិទ្ធភាព ដើម្បីសំរេចបានគោលបំណងនៃការអភិវឌ្ឍសហស្សវត្សរបស់កម្ពុជា–ថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦។ រកមើលបាននៅ៖http://www.cdc-crdb.gov.kh/cdc/aid_management/nsdp.pdf.

រាជរដ្ឋាភិបាលកម្ពុជា–*ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ២០០៩-២០១៣* សម្រាប់ការរីកចម្រើន សមធម៌ និងប្រសិទ្ធភាព ដើម្បីសំរេចបានគោលបំណងនៃការអភិវឌ្ឍសហស្សវត្សរបស់កម្ពុជា–ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០១០ (យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី២ ដើម្បីការរីកចម្រើនសមធម៌ និងប្រសិទ្ធភាព)។

រាជរដ្ឋាភិបាលកម្ពុជា–អនុក្រិត្យលេខ១១៨អនក.បក ស្តីពីការគ្រប់គ្រងដីរដ្ឋ ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៥។

រាជរដ្ឋាភិបាលកម្ពុជា–អនុក្រិត្យលេខ៨៣អនក.បក ស្តីពីនិតិវិធីនៃការចុះបញ្ជីដីរបស់សហគមន៍ជនជាតិដើមភាគតិច ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៩។

រាជរដ្ឋាភិបាលកម្ពុជា–អនុក្រិត្យស្តីពីសម្បទានដីសេដ្ឋកិច្ច លេខ១៤៦អនក.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ ២០០៥ នៅមាត្រាទី៥។ អាចមើលបាននៅ https://docs.google.com/gview?url=www.opendevelopmentcambodia.net/law/en/ANK-146-05-Concession-Land-E.pdf.

RGC, Sub-Decree No.129 ANK/BK on the Rules and Procedures on Reclassification of State Public Properties and Public Entities, Nov. 27, 2006.

RGC, Royal Decree NS/RKT/0806/339 on Provisional Guidelines and Principles Regarding the Re-classification of State Public Properties and of Public Entities (2006).

RGC, Sub-Decree 114 on The Mortgage and Transfer of the Rights Over a Long-Term Lease or an Economic Land Concession, Aug. 29, 2007, available at http://www.cambodiainvestment.gov.kh/sub-decree-114-rgc-on-the-mortgage-and-transfer-of-the-rights-over-a-long-term-lease-or-an-economic-land-concession_070829.html.

Colm, Sara, *សិទ្ធិដីធ្លី: ជម្លោះរបស់ជនជាតិដើមភាគតិចខេត្តរតនគីរី* 3(1) Watershed People's Forum on Ecology (1997).

Lewis, Simon & Khuon Narim, *ក្រុមហ៊ុនតិចតួចណាស់ដែលធ្វើការវាយតំលៃផលប៉ះពាល់បរិដ្ឋាន* The Cambodia Daily, Nov. 25, 2012.

OHCHR, *សម្បទានដីសេដ្ឋកិច្ចនៅកម្ពុជា: ទស្សនវស័យមួយនៃសិទ្ធិមនុស្ស* មិថុនា ឆ្នាំ២០០៧ អាចមើលបាននៅ http://cambodia.ohchr.org/WebDOCs/DocReports/2-Thematic-Reports/Thematic_CMB12062007E.pdf.

OHCHR, *សម្បទានដីសេដ្ឋកិច្ចនៅកម្ពុជា: ទស្សនវិស័យមួយនៃសិទ្ធិមនុស្ស* វិច្ឆិកា ឆ្នាំ២០០៤ អាចមើលបាននៅ http://cambodia.ohchr.org/WebDOCs/DocReports/2-Thematic-Reports/Thematic_CMB14112004E.pdf.

OHCHR, *របាយការណ៍របស់អ្នកអង្កេតការពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា*: Addendum, ២៤ កញ្ញា ឆ្នាំ២០១២, UN Doc. A/HRC/21/63/Add.1, អាចមើលបាននៅ: *http*://www.ohchr.org/Documents/HRBodies/HRCouncil/RegularSession/Session21/A-HRC-21-63-Add1_en.pdf

OHCHR, *របាយការណ៍របស់អ្នកអង្កេតការពិសេស ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា*, ១៦កក្កដា ឆ្នាំ ២០១២UN Doc. A/HRC/21/63, អាចមើលបាននៅ: http://cambodia.ohchr.org/WebDOCs/DocReports/3-SG-RA-Reports/A-HRC-21-63_en.pdf

OHCHR, *របាយការណ៍របស់អ្នកអង្កេតការពិសេស ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា និងសេរីភាពជាមូលដ្ឋានរបស់ជនជាតិដើមភាគតិច* , A/HRC/9/9, 2008.

Baird, Ian, *ពិចារណាពីការប្រែប្រួលនៅខេត្តរតនគិរី ភូមិភាគឥសាននៃប្រទេសកម្ពុជា* 12(3) Watershed People's Forum on Ecology (Nov. 2008), at 65-73.

Oxfam, *តើដីទាំងអស់ទៅណាហើយ? សិទ្ធិនិងការទទួលបានដីធ្លីនៃកម្ពុជា* UN Doc. E/CN.4/1996/93, Feb. 26, 1996.

*នេត្រ ភក្ត្រា–នាយករដ្ឋមន្ត្រី៖ភាគឥសាននឹងក្លាយជាតំបន់សេដ្ឋកិច្ចទីបួន* The Mekong Times, Apr. 30, 2008.

ហ៊ុល រស្មី–សម្បទានដីសេដ្ឋកិច្ច ឥឡូវដល់១.២លានហិកតាហើយ បើតាមមន្ត្រីពាក់ព័ន្ធ Cambodia Daily, Feb. 29, 2012, at 20.

Titthara, May, *ការបញ្ឈប់សម្បទានដីសេដ្ឋកិច្ចត្រូវបានពន្យា បើតាមសំដីនាយករដ្ឋមន្ត្រី*, Phnom Penh Post, Oct. 1 2012.

Tran, Mark, *UN urges Cambodia to hold companies to account over land disputes*, The Guardian, May 14, 2012, *available at* http://www.guardian.co.uk/global-development/2012/may/14/un-cambodia-companies-land-disputes.

Woods, Ben & Kuch Naren, *Minorities Choosing Private Over Communal*, Cambodia Daily, Nov. 30, 2012, at 1-2.

Woods, Ben & Phorn Bopha, *Ethnic Minorities Risk More Than Just Land: Choosing private land titles threatens indigenous communities*, Cambodia Daily, Dec. 6, 2012.

# ឧបសម្ព័ន្ធទី១

## បទបញ្ជា០១បប

## សេចក្តីណែនាំលេខ០១៥

## សេចក្តីណែនាំលេខ០១៨

## សេចក្តីណែនាំលេខ០២០

## និងលិខិតលេខ៦៦៦

ក្រសួង ខ.ជ.ន.ស.

ចូល

លេខ 2072

ចុះថ្ងៃ 10/05/12 ម៉ោង 15 30

បញ្ជូន ឧទ្ទកាលេខា

ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និង សំណង់

ខុទ្ទកាល័យ

ចូល

លេខ 1341

ថ្ងៃទី 10.5.012 ម៉ោង 16 30

បញ្ជូន

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ០១ បប**

# បទបញ្ជា

## ស្តីពី

## វិធានការពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច

អនុលោមតាមគោលនយោបាយស្តីពីការពង្រឹងប្រព័ន្ធគ្រប់គ្រង បែងចែក និងប្រើប្រាស់ដីធ្លី ដែលមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល និងយោងតាមស្មារតីប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១២ ជាពិសេសដោយពិនិត្យឃើញតម្រូវការចាំបាច់ និងបន្ទាន់ចំពោះមុខ ក្នុងការធានាសមធម៌ ពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវបទបញ្ជា ឱ្យក្រសួង ស្ថាប័ន និងអាជ្ញាធរដែលមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីអនុវត្ត ដូចខាងក្រោម÷

១. ផ្អាកជាបណ្តោះអាសន្ននូវការផ្តល់សម្បទានដីសេដ្ឋកិច្ច ។

២. ក្រសួង ស្ថាប័ន និងអាជ្ញាធរដែលមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ នូវគោលនយោបាយ និងរាល់លក្ខខណ្ឌទាំងឡាយនៃសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីការផ្តល់សម្បទានដីសេដ្ឋកិច្ច និងផ្តោតការយកចិត្តទុកដាក់លើការអនុវត្តកិច្ចសន្យាស្តីពីសម្បទានដីសេដ្ឋកិច្ច ពិសេសគឺការអនុវត្តតាមគោលនយោបាយរូបមន្តស្បែកខ្លា និងការមិនធ្វើឱ្យប៉ះពាល់ដល់ដីធ្លីសហគមន៍ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ក្នុងគោលដៅធ្វើឱ្យសម្បទានដីសេដ្ឋកិច្ចទាំងនេះ បានផ្តល់ផលប្រយោជន៍ពិតប្រាកដ ជូនដល់ប្រទេសជាតិ និងប្រជាជន ប្រកបដោយចីរភាព ។

៣. ចំពោះក្រុមហ៊ុនដែលបានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាលរួចហើយ តែមិនបានអនុវត្តតាមនីតិវិធីច្បាប់ជាធរមាន និងតាមកិច្ចសន្យា ដោយកាប់ឈើលក់ហើយមិនធ្វើការអភិវឌ្ឍដីសម្បទាន, ទន្ទ្រានដីបន្ថែម, ទុកដីចោលទំនេរសម្រាប់លក់បន្ត, ធ្វើអាជីវកម្មខុសលក្ខខណ្ឌនៃកិច្ចសន្យា, បំពានដីរបស់ប្រជាពលរដ្ឋ ឬដីសហគមន៍ រាជរដ្ឋាភិបាលនឹងដកហូតនូវដីសម្បទានសេដ្ឋកិច្ចទាំងនោះមកវិញ ។ ដីសម្បទានសេដ្ឋកិច្ចដែលត្រូវបានដកហូតមកវិញនោះ នឹងត្រូវដាក់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋ ដោយផ្ទាល់ ។

៤. ចំពោះសម្បទានដីសេដ្ឋកិច្ចដែលបានទទួលការអនុញ្ញាតជាគោលការណ៍ពីរាជរដ្ឋាភិបាលរួចហើយមុនថ្ងៃចេញបទបញ្ជានេះ ត្រូវបន្តអនុវត្តតាមគោលការណ៍ច្បាប់ និងនីតិវិធីជាធរមាន ។

គ្រប់ក្រសួង ស្ថាប័ន និងអាជ្ញាធរដែលមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវអនុវត្តបទបញ្ជានេះ ឱ្យបានម៉ឺងម៉ាត់បំផុត និងមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី៧ ខែឧសភា ឆ្នាំ ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ចម្លងជូន:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលារាជធានី ខេត្ត
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឧត្តមក្រុមប្រឹក្សា កំណែទម្រង់រដ្ឋ
ក្រុមប្រឹក្សាគោលនយោបាយដីធ្លី
លេខ០៧៤ [illegible]ជនស/កគដ

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែកក្កដាឆ្នាំ ២០១២

# សេចក្តីណែនាំ

## ស្តីពីការអនុវត្តបទបញ្ជាលេខ០១ បប ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១២ របស់រាជរដ្ឋាភិបាលស្តីពីការពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច ពាក់ព័ន្ធនឹងតំបន់សហគមន៍ជនជាតិដើមភាគតិច និងតំបន់ព្រៃស្រោង ពាក់កណ្តាលស្រោង ព្រៃឡង់ មូលដ្ឋានការពារប្រទេស តំបន់បេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ

ដើម្បីអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១បប ស្តីពីវិធានការពង្រឹងនិងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច និងលើកកម្ពស់សុវត្ថិភាពនៃការកាន់កាប់ដីធ្លីក្នុងតំបន់ដែលមានជនជាតិដើមភាគតិចរស់នៅ ហើយដែលស្ថិតនៅក្នុងតំបន់ដីព្រៃសម្បទាន ដីសម្បទានសេដ្ឋកិច្ច និងដីរដ្ឋដែលមានដីកាដកហូតដោយអាជ្ញាធរខេត្ត ព្រមទាំងរក្សាការពារធនធានធម្មជាតិឲ្យបានល្អប្រសើរ ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លីសូមធ្វើការណែនាំអំពីការអនុវត្តបន្ថែមពីលើឯកសារដែលមានជាធរមានដល់ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋគ្រប់ខេត្ត ទាក់ទងនឹងដីរបស់សហគមន៍ជនជាតិដើមភាគតិចនិងដីដែលស្ថិតក្នុងតំបន់ព្រៃស្រោង ពាក់កណ្តាលស្រោង ព្រៃឡង់ មូលដ្ឋានការពារប្រទេស តំបន់បេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ ដូចតទៅ៖

### I- ដីក្នុងតំបន់ដែលមានជនជាតិដើមភាគតិចរស់នៅ

#### ១. សហគមន៍ជនជាតិដើមភាគតិច ដែលបានចុះបញ្ជីនីតិបុគ្គលរួចហើយ នៅក្រសួងមហាផ្ទៃ:

- ត្រូវដំណើរការធ្វើអត្តសញ្ញាណកម្មដី តាមស្មារតីការងារដូចបានកំណត់ក្នុងឯកសារដែលអគ្គនាយកដ្ឋានសុរិយោដីនិងភូមិសាស្ត្របានណែនាំទាក់ទងនឹងដំណើរការនៃការអនុវត្តបទបញ្ជាលេខ០១.បប និងត្រូវចុះបញ្ជីជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ តាមការស្នើសុំរបស់អាជ្ញាធរប្រពៃណី ឬប្រធានគណៈកម្មាធិការសហគមន៍ជនជាតិដើមភាគតិច ទៅតាមប្រភេទនិងទំហំដីដូចដែលបានកំណត់ក្នុងអនុក្រឹត្យលេខ៨៣ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច និងអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី។



អាស័យដ្ឋាន : លេខ ៧៧១-៧៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់ បឹងត្របែក ខណ្ឌ ចំការមន ក្រុងភ្នំពេញ
Tel/Fax : (855-23) 215 660 , E-mail : mlmupc@camnet.com.kh

2el

ក្រោយពីការធ្វើអត្តសញ្ញាណកម្មនិងអនុវត្តតាមដំណាក់កាលខាងលើរួច ត្រូវចេញ**ប័ណ្ណកម្មសិទ្ធិបឋម**ជូនសហគមន៍ ដោយមានភ្ជាប់ជាមួយនូវផែនទីបឋមដែលសម្គាល់ពីទីតាំងនិងប្រភេទដីរបស់សហគមន៍។

- នៅលើប័ណ្ណកម្មសិទ្ធិបឋម៖

  » ត្រង់ចំណុច **II. អត្តសញ្ញាណអ្នកកាន់កាប់ដី៖** ត្រូវសរសេរឈ្មោះសហគមន៍ជនជាតិដើមភាគតិចដែលកាន់កាប់ដីនោះ *(ឧទាហរណ៍: **II. អត្តសញ្ញាណអ្នកកាន់កាប់ដី៖ សហគមន៍ជនជាតិដើមភាគតិចទំពួន** )* ភូមិ......... ឃុំ......... ស្រុក ....... ខេត្ត............។

  » ត្រង់ចំណុច **III. ប្រភេទទ្រព្យ៖**....... ត្រូវសរសេរ **កម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច....នៃភូមិ**...*(ឧទាហរណ៍: III. **ប្រភេទទ្រព្យ៖ កម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចទំពួននៃភូមិឡាអិន**)*។

- នៅពេលចេញប័ណ្ណកម្មសិទ្ធិស្ថាពរ ត្រូវចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច និងចេញប័ណ្ណកម្មសិទ្ធិសមូហភាព តាមស្មារតីនៃអនុក្រឹត្យលេខ៨៣ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច។

**២. ចំពោះសហគមន៍ដែលកំពុងដំណើរការសុំចុះបញ្ជីសហគមន៍នៅក្រសួងមហាផ្ទៃជានីតិបុគ្គល** ត្រូវអនុវត្តដូចគ្នានឹងសហគមន៍ជនជាតិដើមភាគតិច ដែលបានចុះបញ្ជីជានីតិបុគ្គលរួចហើយនៅក្រសួងមហាផ្ទៃដែរ។

**៣. ចំពោះជនជាតិដើមភាគតិចដែលមិនចូលជាសមាជិកសហគមន៍ ហើយចង់រស់នៅជាឯកជន** ត្រូវអនុវត្តដូចប្រជាពលរដ្ឋកម្ពុជាទូទៅដែរ ដោយទទួលបានដីជាកម្មសិទ្ធិឯកជន លើចំណែកដីដែលគាត់បាននិងកំពុងកាប់កាប់និងដាំដុះជាក់ស្តែងតែប៉ុណ្ណោះ។ ក្នុងករណីនេះ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្ត ត្រូវលើកសំណើសុំធ្វើអនុបយោគ ប្រសិនបើដីនោះជាដីសាធារណៈរបស់រដ្ឋ។

## II- ដីក្នុងតំបន់ព្រៃស្រោង ពាក់កណ្តាលស្រោង ព្រៃឡង់ មូលដ្ឋានការពារប្រទេស តំបន់បេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ

ក្នុងដំណើរការធ្វើអត្តសញ្ញាណកម្ម ប្រសិនបើមានប្រជាពលរដ្ឋមកអះអាង និង/ឬមានការស្នើសុំសិទ្ធិលើចំណែកដីដែលស្ថិតក្នុងតំបន់ព្រៃស្រោង ពាក់កណ្តាលស្រោង ព្រៃឡង់ មូលដ្ឋានការពារប្រទេស តំបន់បេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ ការអះអាងនិងការទាមទារទាំងនោះនឹងមិនត្រូវយកមកពិនិត្យឡើយ។



lol

ចំណែកដីដែលពាក់ព័ន្ធនឹងកិច្ចសន្យាណាមួយ ហើយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបានធ្វើអត្តសញ្ញាណកម្មឃើញថាជាដីស្ថិតក្នុងតំបន់ព្រៃស្រោង ពាក់កណ្តាលស្រោង ព្រៃឡង់ មូលដ្ឋានការពារប្រទេស តំបន់បេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្ត ត្រូវលើកសំណើសុំគោលការណ៍សម្រេចពីរាជរដ្ឋាភិបាល។

សេចក្តីណែនាំនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី**

**អ៊ឹម ឈុនលឹម**

***ចម្លងជូន៖***

- *ក្រសួង/ស្ថាប័នជាសមាជិកក្រុមប្រឹក្សាគោលនយោបាយដីធ្លី*
- *ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *គ្រប់រាជធានី ខេត្ត*
- *គ្រប់អគ្គនាយកដ្ឋាន និងអង្គភាពជុំវិញក្រសួង ដ.ន.ស.*
- *គ្រប់មន្ទីរ ដនសស រាជធានី ខេត្ត*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ឧត្តមក្រុមប្រឹក្សា កំណែទម្រង់រដ្ឋ**

**ក្រុមប្រឹក្សាគោលនយោបាយដីធ្លី**

លេខ ០១៨ សណន/កគដ

រាជធានីភ្នំពេញ ថ្ងៃទី២០ខែកក្កដា ឆ្នាំ២០១២

# សេចក្ដីណែនាំ

## ស្ដីពី

## ការធ្វើអត្តសញ្ញាណកម្មដីធ្លី អត្តសញ្ញាណកម្មប្រជាពលរដ្ឋ និងការចេញប័ណ្ណកម្មសិទ្ធិបឋម អនុវត្តតាមបទបញ្ជាលេខ០១ បប ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១២ របស់រាជរដ្ឋាភិបាល ស្ដីពីការពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច

ដើម្បីអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ បប ស្ដីពីវិធានការពង្រឹងនិងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ចឲ្យមានប្រសិទ្ធភាព ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី សូមធ្វើការណែនាំអំពីការអនុវត្តបន្ថែមពីលើឯកសារដែលមានជាធរមាន ដល់ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋគ្រប់ខេត្ត និងក្រុមបច្ចេកទេសវាស់វែងដីធ្លី ដើម្បីធ្វើប្រទានកម្មជូនប្រជាពលរដ្ឋ ដូចតទៅ៖

១. ក្នុងប្រតិបត្តិការអនុវត្តបទបញ្ជាលេខ ០១ អនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្ដីពីការគ្រប់គ្រងដីរដ្ឋ អនុក្រឹត្យលេខ៨៦ អនក្រ.បក ស្ដីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លីចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ និងសារាចរលេខ០២ ស្ដីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ អភិបាលខេត្តជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ និងជាប្រធានគណៈកម្មការរដ្ឋបាល ទន្ទឹមនឹងធ្វើការផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មាន ត្រូវណែនាំក្រុមការងារដីរដ្ឋថ្នាក់ក្រុង/ស្រុក ដោយមានជំនួយរបស់ក្រុមបច្ចេកទេសវាស់វែងដីធ្លី និងក្រុមយុវជនស្ម័គ្រចិត្ត ឲ្យធ្វើការផ្សព្វផ្សាយជាសាធារណៈអំពីយុទ្ធនាការនេះតាមឧគ្ឃោសនសព្ទ តាមក្រុង/ស្រុក ឃុំ និងភូមិគោលដៅ។ ទន្ទឹមនេះ ដើម្បីជាព័ត៌មានដល់សាធារណជន ត្រូវដាក់ផ្ទាំងប៉ាណូបង្ហាញទីតាំងស្នាក់នៅរបស់ក្រុមយុទ្ធនាការ និងទីតាំងតំបន់ត្រូវវាស់វែង។

២. <u>ការធ្វើអត្តសញ្ញាណកម្មតំបន់កាន់កាប់ដីជាក់ស្ដែងរបស់ប្រជាពលរដ្ឋ និងការធ្វើអត្តសញ្ញាណកម្មប្រជាពលរដ្ឋ</u>

- គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុមការងារដីរដ្ឋថ្នាក់ក្រុង/ស្រុក និងក្រុមការងារ វាលឃុំនីមួយៗជាអ្នកកំណត់៖ *(ទី១).* ទីតាំងតំបន់និងទំហំដីត្រូវកាត់ចេញពីដីព្រៃសម្បទាន សម្បទានដីសេដ្ឋកិច្ច និងដីរដ្ឋដែលមានដីកាដកហូតដោយអាជ្ញាធរខេត្ត។ *(ទី២).* ចំនួនគ្រួសារប្រជាពលរដ្ឋ ដែលបានអះអាងថាបានកាន់កាប់ និងដាំដុះជាក់ស្ដែង។



អាសយដ្ឋាន ៖ លេខ ៧៧១-៧៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់ បឹងត្របែក ខណ្ឌ ចំការមន ក្រុងភ្នំពេញ

Tel/Fax : (855-23) 215 660 , E-mail : mlmupc@camnet.com.kh

ក្រោយការកំណត់ទីតាំងដី ទំហំដី និងចំនួនប្រជាពលរដ្ឋកាន់កាប់ដាំដុះជាក់ស្ដែងរួចហើយ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ត្រូវលើកសំណើជូនប្រមុខរាជរដ្ឋាភិបាល ដោយរៀបចំសេចក្ដីព្រាងអនុក្រឹត្យអនុបយោគ ចំពោះដីសាធារណៈរបស់រដ្ឋ ឬសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល ចំពោះដីឯកជនរបស់រដ្ឋ និងភ្ជាប់ជាមួយនូវផែនទីបឋមនៃតំបន់កាន់កាប់នោះ។ ក្នុងអនុក្រឹត្យ ឬសេចក្ដីសម្រេច ត្រូវចែងអំពីទីតាំងដី ភូមិ ឃុំ ក្រុង/ស្រុក ខេត្ត ចំនួនគ្រួសារជាក់ស្ដែង ទំហំដី និយាមកាដី ប្រភេទនៃការប្រើប្រាស់ដី ដូចជាដីសាធារណៈ ដីលំនៅឋាន ដីកសិកម្ម ដីបំរុង...។

- តាមករណីចាំបាច់ ដើម្បីជួយសម្រួលដល់ការងាររបស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត **ក្រុមបច្ចេកទេសវាស់វែងដីធ្លី** អាចចាប់ផ្ដើមការងារវាស់វែងដីដែលប្រជាពលរដ្ឋបានកាន់កាប់ និងដាំដុះជាក់ស្ដែង ស្របពេលជាមួយនឹងការធ្វើអត្តសញ្ញាណកម្មទីតាំងតំបន់និងការកំណត់ទំហំដីរបស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្ត។ ក្នុងករណីនេះ **ក្រុមបច្ចេកទេសវាស់វែងដីធ្លី** ត្រូវវាស់វែងតែលើតំបន់ដែលប្រជាពលរដ្ឋបានកាន់កាប់ជាក់ស្ដែង និងពុំមានទំនាស់តែប៉ុណ្ណោះ។

## ៣. <u>ការធ្វើអត្តសញ្ញាណកម្មក្បាលដី អត្តសញ្ញាណកម្មប្រជាពលរដ្ឋ និងការវាស់វែងក្បាលដីដើម្បីចេញប័ណ្ណកម្មសិទ្ធិបឋម</u>

- **ក្រុមបច្ចេកទេសវាស់វែងដីធ្លី** ត្រូវជូនដំណឹងដល់ប្រជាពលរដ្ឋអំពីការចុះវាស់វែងក្បាលដីចំនួនមួយសប្ដាហ៍មុនការចុះវាស់វែង។
- បន្ទាប់មក **ក្រុមបច្ចេកទេសវាស់វែងដីធ្លី** ដែលជាមន្ត្រីជំនាញសុរិយោដី ដោយមានយុវជនស្ម័គ្រចិត្តចូលរួម ត្រូវចុះវាស់វែងក្បាលដីដែលប្រជាពលរដ្ឋបានកាន់កាប់និងដាំដុះជាក់ស្ដែង ដើម្បីប្រមូលទិន្នន័យសម្រាប់ជាមូលដ្ឋានក្នុងការចេញប័ណ្ណកម្មសិទ្ធិបឋម។ ក្នុងដំណើរការនេះ ត្រូវស្រង់ព័ត៌មានលម្អិតអំពីប្រជាពលរដ្ឋ ដូចជាឈ្មោះ រូបថត ស្នាមមេដៃ សៀវភៅគ្រួសារ អត្តសញ្ញាណប័ណ្ណ និងសមាជិកគ្រួសារ និងទិន្នន័យក្បាលដី ដែលប្រជាពលរដ្ឋបានកាន់កាប់ជាក់ស្ដែង។
- ទិន្នន័យប្រមូលបាន ត្រូវធ្វើការបិទផ្សាយជាសាធារណៈចំនួន៣០ថ្ងៃ ដោយមានការជូនដំណឹងជាមុនចំនួន០៧ថ្ងៃយ៉ាងតិចមុនការបិទផ្សាយ។ ក្នុងរយៈពេលបិទផ្សាយនេះ ត្រូវមានការប្រជុំសហគមន៍ ដើម្បីពិនិត្យផ្ទៀងផ្ទាត់រួមគ្នាលើបញ្ជីឈ្មោះ ប្រជាពលរដ្ឋនិងក្បាលដី។
- ក្រោយបានបិទផ្សាយជាសាធារណៈ និងប្រជុំពិនិត្យផ្ទៀងផ្ទាត់ឈ្មោះ និងក្បាលដីដោយមានការព្រមព្រៀងគ្នារួចហើយ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ត្រូវចេញ**ប័ណ្ណកម្មសិទ្ធិបឋម** ជូនអ្នកកាន់កាប់ដី សំរាប់ក្បាលដីនីមួយៗដែលគ្មានទំនាស់ ស្របតាមការសម្រេចរបស់រាជរដ្ឋាភិបាល ក្នុងពេលរង់ចាំការចេញប័ណ្ណកម្មសិទ្ធិស្ថាពរ ឬត្រូវចេញ**លិខិតបញ្ជាក់ការប្រើប្រាស់ដីរដ្ឋក្នុងទំរង់ជាសម្បទានដីសេដ្ឋកិច្ចខ្នាតតូច** ក្នុងពេលរង់ចាំការចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចខ្នាតតូចនៅពេលក្រោយ។

- ការសម្រេចលើឯកសារនៃការវិនិច្ឆ័យស្តីពីសិទ្ធិត្រូវផ្តល់ជូនប្រជាពលរដ្ឋៈ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ និងគណៈកម្មាការរដ្ឋបាល អាចពិនិត្យស្នើសុំការសម្រេចរបស់រាជរដ្ឋាភិបាលក្នុងការផ្តល់សិទ្ធិលើដីជូនប្រជាពលរដ្ឋតាមជំរើសដូចខាងក្រោម៖ (ក). សិទ្ធិជាកម្មសិទ្ធិលើក្បាលដីលំនៅឋាន ក្បាលដីកាន់កាប់និងដាំដុះជាក់ស្តែង ទាំងដំណាំយុទ្ធសាស្ត្រ ទាំងដំណាំរដូវ មិនឲ្យលើសពី ២០០ ហិកតា (ខ). ឬ សិទ្ធិប្រើប្រាស់ដីរដ្ឋក្នុងទំរង់ជាសម្បទានដីសេដ្ឋកិច្ចខ្នាតតូច លើដីដែលបានកាប់រានតែពុំទាន់បានដាំដុះ។ ក្នុងការសម្រេចផ្តល់សិទ្ធិត្រូវផ្តល់អាទិភាពចំពោះប្រជាពលរដ្ឋដែលមានទីលំនៅជាក់ស្តែងអចិន្ត្រៃយ៍ក្នុងភូមិគោលដៅ។ ឯចំពោះដីធំៗលើសពី១០ (ដប់)ហិកតា ត្រូវទុកធ្វើជាក្រោយតាមការចុះបញ្ជីដាច់ដោយដុំ។

៤. ករណីមានការទាមទារឬអះអាងរបស់ប្រជាពលរដ្ឋលើចំណែកដីវិនិយោគរបស់ក្រុមហ៊ុន ដែលបានដាំដុះជាក់ស្តែងនិងអភិវឌ្ឍន៍រួចហើយ ត្រូវអនុវត្តដូចខាងក្រោមៈ

- ចំពោះករណីប្រជាពលរដ្ឋដែលធ្លាប់បានទទួលការដោះស្រាយរួចហើយ ការទាមទារ ឬអះអាងខាងលើពុំអាចយកមកដោះស្រាយទៀតឡើយ។
- ចំពោះករណីប្រជាពលរដ្ឋដែលបានចាកចេញពីទីតាំងដែលធ្លាប់បានកាន់កាប់ ដោយអាជ្ញាធរ ស្ថាប័នមានសមត្ថកិច្ច ឬក្រុមហ៊ុនបានអនុវត្តត្រឹមត្រូវតាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល និងនីតិវិធីច្បាប់ នោះការទាមទារឬអះអាងខាងលើពុំអាចយកមកដោះស្រាយឡើយ។ ករណីនេះ អាជ្ញាធរខេត្ត អាចអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចជូនប្រជាពលរដ្ឋ ដោយតម្រូវឲ្យមានការបញ្ជាក់អំពីអត្រានុកូលដ្ឋានពីអាជ្ញាធរមូលដ្ឋានដើម និងមានការបញ្ជាក់អំពីភាពក្រីក្រពីគណៈកម្មាធិការបែងចែក និងប្រើប្រាស់ដីនៅខេត្តដើមកំណើត។

៥. ចំពោះករណីប្រជាពលរដ្ឋដែលចូលទន្ទ្រានកាន់កាប់ដីរដ្ឋថ្មីៗ ក្រោយថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១២ មិនអាចយកមកដោះស្រាយបានឡើយ។ ការបោះបង្គោលទន្ទ្រានដីរដ្ឋ ត្រូវហាមឃាត់ជាដាច់ខាត។ ចំពោះករណីនេះ មន្ត្រីពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ និងសមត្ថកិច្ចពាក់ព័ន្ធ រួមទាំងកងកម្លាំងប្រដាប់អាវុធ ត្រូវអនុវត្តតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តជាធរមាន ព្រមទាំងបទបញ្ជារបស់រាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាព និងមនសិការទទួលខុសត្រូវខ្ពស់។

សេចក្តីណែនាំនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី**

**អ៊ឹម ឈុនលឹម**

*ចម្លងជូន៖*

- *ក្រសួង/ស្ថាប័នជាសមាជិកក្រុមប្រឹក្សាគោលនយោបាយដីធ្លី*
- *ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
  *"ដើម្បីជូនជ្រាបជាព័ត៌មាន"*
- *គ្រប់រាជធានី ខេត្ត*
- *គ្រប់អគ្គនាយកដ្ឋាន និងអង្គភាពជុំវិញក្រសួង ដ.ន.ស.*
- *គ្រប់មន្ទីរ ដនសស រាជធានី ខេត្ត*
- *ឯកសារ កាលប្បវត្តិ*
  *"ដើម្បីជូនជ្រាបជាព័ត៌មាន"*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ**
**ក្រុមប្រឹក្សាគោលនយោបាយដីធ្លី**
លេខ.០៤០......សណន/កគដ

រាជធានីភ្នំពេញ ថ្ងៃទី២៦ខែកក្កដាឆ្នាំ ២០១២

# សេចក្ដីណែនាំ

## ស្ដីពីការអនុវត្តបទបញ្ជាលេខ០១ បប ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១២ របស់រាជរដ្ឋាភិបាលស្ដីពីការពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច ពាក់ព័ន្ធនឹងតំបន់សហគមន៍ជនជាតិដើមភាគតិច

ដើម្បីអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១បប ស្ដីពីវិធានការពង្រឹងនិងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច និងលើកកម្ពស់សុវត្ថិភាពនៃការកាន់កាប់ដីធ្លីក្នុងតំបន់ដែលមានជនជាតិដើមភាគតិចរស់នៅ និងដោយយុទ្ធនាការអនុវត្តនយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លីមានរយៈពេលកំណត់និងស្ថិតក្នុងគំរោងថវិកាឆ្នាំ២០១២ប៉ុណ្ណោះ ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី សូមធ្វើការណែនាំអំពីការអនុវត្តបន្ថែមពីលើឯកសារដែលមានជាធរមានដល់ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋគ្រប់ខេត្ត ទាក់ទងនឹងដីរបស់សហគមន៍ជនជាតិដើមភាគតិច ដូចតទៅ៖

- ដោយការកំណត់ព្រំប្រទល់ក្បាលដីទាំងឡាយជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ជាពិសេសដីចម្ការវិលជុំដែលជាចំណែកដីសាធារណៈរបស់រដ្ឋ មានច្រើនកន្លែងនៅរាយប៉ាយ ត្រូវការពេលវេលាយូរ និងចំណាយថវិកាច្រើន ការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ត្រូវទុកអនុវត្តនៅពេលក្រោយ តាមស្មារតីនៃអនុក្រឹត្យលេខ ៨៣ អនក្រ.បក ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០០៩។
- ចំពោះជនជាតិដើមភាគតិចដែលមិនចូលជាសមាជិកសហគមន៍ ហើយចង់រស់នៅជាឯកជន ត្រូវអនុវត្តដូចមានចែងក្នុងសេចក្ដីណែនាំលេខ០១៥ សណនជនស/កគដ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១២ ត្រង់ចំណុច I-៣។ បន្ថែមលើសេចក្ដីណែនាំនេះ ចាំបាច់ត្រូវមានកិច្ចសន្យាស្ម័គ្រចិត្តចង់រស់នៅជាឯកជន ដោយមានផ្តិតស្នាមមេដៃរបស់សាមីជនទុកជាភស្តុតាងទៅថ្ងៃក្រោយ។

សេចក្ដីណែនាំនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី**

**អ៊ឹម ឈុនលឹម**

*ចម្លងជូន៖*
- *ក្រសួង/ស្ថាប័នជាសមាជិកក្រុមប្រឹក្សាគោលនយោបាយដីធ្លី*
- *ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
  *"ដើម្បីជូនជ្រាប"*
- *គ្រប់រាជធានី ខេត្ត*
- *គ្រប់អគ្គនាយកដ្ឋាន និងអង្គភាពជុំវិញក្រសួង ដ.ន.ស.*
- *គ្រប់មន្ទីរ ដនសស រាជធានី ខេត្ត*
  *"ដើម្បីអនុវត្ត"*
- *ឯកសារ កាលប្បវត្តិ*

ក្រសួង ដ.ន.ស.
ចូល
លេខ 2856
ថ្ងៃខែឆ្នាំ 26/06/12 ម៉ោង 30
ហត្ថលេខា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**លេខៈ** ៧៦៦ ស.ជ.ណ

*រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១២*

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ជំរាបជូន**
**ឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**កម្មវត្ថុ ៖** ករណីសំណើសុំគោលការណ៍សម្រាប់ការងារចុះបញ្ជីដីធ្លីក្នុងតំបន់គោលដៅដែលត្រូវអនុវត្តនូវបទបញ្ជាលេខ ០១បប ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១២ ស្តីពីវិធានការពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច ។

**យោង ៖** -លិខិតលេខ ៧៣៧ ដនស/កករ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១២ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ចំណាររបស់សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១២ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រី សូមជំរាបជូនឯកឧត្តម មេត្តាជ្រាបថា ចំពោះករណីសំណើសុំគោលការណ៍សម្រាប់ការងារចុះបញ្ជីដីធ្លីក្នុងតំបន់គោលដៅដែលត្រូវអនុវត្តនូវបទបញ្ជាលេខ ០១បប ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១២ ស្តីពីវិធានការពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច នោះ រាជរដ្ឋាភិបាលបានសំរេចដូចខាងក្រោម ៖

១-នៅក្នុងតំបន់ដែលបានឆ្កៀលស្របតាមនីតិវិធី និងបទដ្ឋានគតិយុត្តជាធរមានចេញពីដីព្រៃសម្បទាន ពីដីសម្បទានសេដ្ឋកិច្ច ពីដីតំបន់គ្រប់គ្រងដោយក្រសួងបរិស្ថាន និងក្នុងដីរដ្ឋដែលមានដីកាដកហូតដោយអាជ្ញាធររាជធានីខេត្ត ត្រូវអនុវត្តតាមវិធានការដូចខាងក្រោម ៖

១.១-យល់ព្រមតាមសំណើចំពោះអ្នកកំពុងកាន់កាប់ដីជាក់ស្តែងមិនលើសពី ០៥ហិកតាត្រូវធ្វើប្រទានកម្មជូនគាត់ជាកម្មសិទ្ធិ។ក្នុងករណីនេះ ដើម្បីបង្កលក្ខណៈសម្រាប់ការអភិវឌ្ឍដីត្រូវអនុវត្តនីតិវិធីនៃការចុះបញ្ជីដីជា០២ជំហាន គឺជំហានទី១ ត្រូវផ្តល់ប័ណ្ណកម្មសិទ្ធិបឋម ដែលមានតម្លៃប្រើប្រាស់ដូចប័ណ្ណកម្មសិទ្ធិរហូតដល់ថ្ងៃទទួលបានប័ណ្ណកម្មសិទ្ធិជាស្ថាពរ ដែលនឹងត្រូវប្តូរជាមួយនឹងប័ណ្ណនេះ ដោយភ្ជាប់ជាមួយនឹងអនុក្រឹត្យ ឬសេចក្តីសំរេចទើបមានតម្លៃពេញលេញ។ ជំហានទី២ ត្រូវផ្តល់ប័ណ្ណកម្មសិទ្ធិស្ថាពរ ក្រោយបានបំពេញទិន្នន័យពេញលេញលើក្បាលដីជាកម្មវត្ថុនៃ

ប្រទានកម្ម ។ ដោយរយៈពេលអនុវត្តនីតិវិធីចុះបញ្ជីដីពុំវែងប៉ុន្មាន ត្រូវកំណត់លក្ខខណ្ឌមិនឲ្យមានការលក់ ការផ្ទេរដីនោះ រហូតដល់ការចេញប័ណ្ណជាស្ថាពរ ។

១.២- ចំពោះអ្នកកាន់កាប់ដី**លើសពី០៥**ហិកតា ទោះមានទីលំនៅ ឬមិនមានទីលំនៅនៅនឹងកន្លែង ចំណែកដីដែលបានដាំដុះជាក់ស្តែងត្រូវធ្វើប្រទានកម្មជូនគាត់ជាកម្មសិទ្ធិ។ ឯចំណែកដីដែលពុំបានដាំដុះត្រូវចុះបញ្ជីជាដីឯកជនរបស់រដ្ឋ ដោយផ្តល់ជូនគាត់ជាសម្បទានដីសេដ្ឋកិច្ចខ្នាតតូច។ ក្នុងករណីនេះ ជូនអភិបាលខេត្តជាអ្នកចុះបញ្ជីដីក្នុងនាមជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្ត និងផ្តល់សិទ្ធិប្រទានជូនអភិបាលខេត្តឲ្យធ្វើជាអាជ្ញាធរចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចខ្នាតតូចជាមួយសម្បទានិក ។

- **សុពលភាពនៃកិច្ចសន្យា** សម្បទានដីសេដ្ឋកិច្ចខ្នាតតូច**ត្រឹម ៩៩ឆ្នាំ**យ៉ាងយូរ ។
- កំណត់ឲ្យម្ចាស់ដីធ្វើការដាំដុះឲ្យអស់ផ្ទៃដីដែលមានក្នុងកិច្ចសន្យា ក្នុងរយពេល**០៥ឆ្នាំ** គិតពីថ្ងៃចុះកិច្ចសន្យា។
  ករណីអនុវត្តមិនអស់ផ្ទៃដីត្រូវប្រគល់ជូនរដ្ឋវិញនូវចំណែកដីមិនបានអភិវឌ្ឍន៍។
- កម្រៃសួយសារត្រូវអនុវត្តតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចាប់ពី**ឆ្នាំទី០៦** ទៅ។
- សម្បទានិកខ្នាតតូចមិនអាចផ្ទេរសិទ្ធិសម្បទានដីសេដ្ឋកិច្ចខ្នាតតូចនេះដល់បុគ្គល ផ្សេងបានទេ លើកលែងតែការផ្ទេរនោះធ្វើឡើងតាមរយៈការបង្កើតកិច្ចសន្យាសម្បទានសេដ្ឋកិច្ចខ្នាតតូចថ្មី ជាមួយនឹងអាជ្ញាធរមានសមត្ថកិច្ច។ សម្បទានិកខ្នាតតូចមិនត្រូវប្រើប្រាស់ដីក្នុងរូបភាពណា ដែលធ្វើឲ្យប៉ះពាល់ដល់ប្រយោជន៍សាធារណៈ ឬប៉ះពាល់ ដល់បរិស្ថាន ឬខូចខាតដល់សក្តានុពលនៃដី។

២-ចំពោះប្រជាពលរដ្ឋដែលបានទទួលដីពីកម្មវិធីសម្បទានដីសង្គមកិច្ចរបស់រាជរដ្ឋាភិបាល ដែលច្បាប់បានកំណត់លក្ខខណ្ឌកាន់កាប់ដីគ្រប់០៥ឆ្នាំ ទើបអាចមានសិទ្ធិកម្មសិទ្ធិលើដីនោះបាន ដូច្នេះ ក្នុងចន្លោះពេលអន្តរកាលនេះ អនុញ្ញាតឲ្យមានប័ណ្ណសម្គាល់សិទ្ធិសម្បទានដីសង្គមកិច្ចជូនពួកគាត់ដែរ ដើម្បីអាចយកប័ណ្ណនេះដាក់ហ៊ីប៉ូតែក ឬបញ្ចាំបាន ដោយកំណត់ឲ្យយកឯកសារបញ្ជាក់សិទ្ធិកាន់កាប់ដីសម្បទានសង្គមកិច្ច ដែលអាជ្ញាធរបានផ្តល់ជូនកន្លងមក មកប្តូរយកប័ណ្ណសម្គាល់សិទ្ធិនេះ ។ ទន្ទឹមនេះ រាជរដ្ឋាភិបាល បានសម្រេចយល់ព្រមតាមគំរូប័ណ្ណកម្មសិទ្ធិបឋម គំរូប័ណ្ណសម្គាល់សិទ្ធិសម្បទានដីសង្គមកិច្ច និងគំរូកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចខ្នាតតូច ។

សេចក្តីដូចបានជំរាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងអនុវត្តតាមការគួរ។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីស្តីទី**

**ប្រាក់ សុខុន**

**ចំលងជូន ៖**
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងបរិស្ថាន
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ខេត្ត-រាជធានី
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី២

# លិខិតផ្ញើឲ្យអង្គការ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ

សាលាខេត្តរតនគិរី

លេខ ០១៩/១២

រតនគិរី,ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ២០១២

# សេចក្តីប្រកាស

## ស្តីពី

## ការកំណត់តំបន់វិនិច្ឆ័យសម្រាប់ការងារចុះបញ្ជីដីធ្លី ដើម្បីផ្តល់ប័ណ្ណកម្មសិទ្ធិបឋម

-យោងអនុក្រឹត្យលេខ ១១៨អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការគ្រប់គ្រងដីរដ្ឋ ។

-យោងសារាចរលេខ០២ស.រ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការកាន់កាប់ដីរដ្ឋខុសច្បាប់ ។

អភិបាលខេត្តរតនគិរី និងជាប្រធានគណកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត សូមធ្វើការកំណត់ដូចខាងក្រោម :

១.កំណត់ឃុំសេដា និង ឃុំស៊ើង (ចំនុចៈ សមុទ្រលើ សមុទ្រក្រោម ថ្មី ពម ណាងហៃ យ៉ាសោម) ស្រុកលំផាត់ និង ស្រុកបរកែវ ខេត្តរតនគិរី ជាតំបន់វិនិច្ឆ័យសំរាប់ការងារចុះបញ្ជីដីធ្លីផ្តល់ប័ណ្ណកម្មសិទ្ធិបឋម ។

២.ការវិនិច្ឆ័យសម្រាប់ការងារចុះបញ្ជីដីធ្លីផ្តល់ប័ណ្ណកម្មសិទ្ធិបឋមនៅក្នុងតំបន់វិនិច្ឆ័យខាងលើ នឹងត្រូវប្រតិបត្តិការដោយកិច្ចសហការរបស់មន្ត្រីជំនាញ និងយុវជនស្ម័គ្រចិត្ត ចាប់ពីថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១២ តទៅ នៅទីតាំងដីខាងលើ ។

៣.អាជ្ញាធរមូលដ្ឋាននៃតំបន់វិនិច្ឆ័យខាងលើ អង្គភាពពាក់ព័ន្ធ និង ប្រជាពលរដ្ឋដែលជាអ្នកកាន់កាប់ ដីស្រែ ដីចំការ និង ដីលំនៅដ្ឋាន ឬ សាងសង់ទាំងអស់ដែលមានក្បាលដីនៅក្នុងតំបន់នោះត្រូវសហការជាមួយ មន្ត្រីជំនាញនិងយុវជនស្ម័គ្រចិត្ត ដែលនឹងចុះបំពេញភារកិច្ចនៃកិច្ចការវិនិច្ឆ័យសម្រាប់ការងារចុះបញ្ជីដីធ្លីផ្តល់ប័ណ្ណកម្មសិទ្ធិបឋមនេះ នៅក្នុងតំបន់ដែលបានកំណត់ក្នុងចំណុច១ ស្ថិតនៅក្នុងក្រុមហ៊ុនអេលែវ ។

៤.សេចក្តីប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តន៍ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**អភិបាលខេត្តរតនគិរី**

**និងជាប្រធានគណកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត**

**ប៉ាវ-ហមផាន់**

ចម្លងជូន

-ទីស្តីការគណរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់

(ដើម្បីជូនជ្រាប)

-សាលាស្រុកលំផាត់ និងស្រុកបរកែវ

-មន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដី

-សាលាឃុំសេដា និង ឃុំស៊ើង

(ដើម្បីសហការអនុវត្តន៍)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ

សាលាខេត្តរតនគិរី

លេខ ០២០/១២

រតនគិរី ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ២០១២

## សេចក្តីប្រកាស

### ស្តីពី

### ការកំណត់តំបន់វិនិច្ឆ័យសម្រាប់ការងារចុះបញ្ជីដីធ្លី ដើម្បីផ្តល់ប័ណ្ណកម្មសិទ្ធិបឋម

-យោងអនុក្រឹត្យលេខ ១១៨អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការគ្រប់គ្រងដីរដ្ឋ ។

-យោងសារាចរលេខ០២ស.រ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការកាន់កាប់ដីរដ្ឋខុសច្បាប់ ។

អភិបាលខេត្តរតនគិរី និងជាប្រធានគណកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត សូមធ្វើការកំណត់ដូចខាងក្រោម :

១.កំណត់ឃុំតាឡាវ ឃុំម៉ាលិក និងឃុំកិះចុង( ចំនុចៈកាណាតតូច កាណាតធំ កាក់ តាឡាវ កាណង ម៉ាលិក កាតែ លោម កាហាល់ ប៉ាឡៃ ទៀន រ៉យ) ស្រុកអណ្តូងមាស ខេត្តរតនគិរី ជាតំបន់វិនិច្ឆ័យសំរាប់ការងារចុះបញ្ជីដីធ្លីផ្តល់ប័ណ្ណកម្មសិទ្ធិបឋម ។

២.ការវិនិច្ឆ័យសម្រាប់ការងារចុះបញ្ជីដីធ្លីផ្តល់ប័ណ្ណកម្មសិទ្ធិបឋមនៅក្នុងតំបន់វិនិច្ឆ័យខាងលើ នឹងត្រូវប្រតិបត្តិការដោយកិច្ចសហការរបស់មន្ត្រីជំនាញ និងយុវជនស្ម័គ្រចិត្ត ចាប់ពីថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១២ តទៅ នៅទីតាំងដីខាងលើ ។

៣.អាជ្ញាធរមូលដ្ឋាននៃតំបន់វិនិច្ឆ័យខាងលើ អង្គភាពពាក់ព័ន្ធ និង ប្រជាពលរដ្ឋដែលជាអ្នកកាន់កាប់ ដីស្រែ ដីចំការ និង ដីលំនៅដ្ឋាន ឬ សាងសង់ទាំងអស់ដែលមានក្បាលដីនៅក្នុងតំបន់នោះត្រូវសហការជាមួយ មន្ត្រីជំនាញនិងយុវជនស្ម័គ្រចិត្ត ដែលនឹងចុះបំពេញភារកិច្ចនៃកិច្ចការវិនិច្ឆ័យសម្រាប់ការងារចុះបញ្ជីដីធ្លីផ្តល់ប័ណ្ណកម្មសិទ្ធិបឋមនេះ នៅក្នុងតំបន់ដែលបានកំណត់ក្នុងចំណុច១ ស្ថិតនៅក្នុងក្រុមហ៊ុនវាសនា ។

៤.សេចក្តីប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តន៍ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**អភិបាលខេត្តរតនគិរី**

**និងជាប្រធានគណកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត**

**ប៉ាវ ហមផាន**

ចម្លងជូន

-ទីស្តីការគណរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់

( ដើម្បីជូនជ្រាប)

-សាលាស្រុកអណ្តូងមាស និង ស្រុកបរកែវ

-មន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដី

-សាលាឃុំតាឡាវ ម៉ាលិក និងឃុំកិះចុង

( ដើម្បីសហការអនុវត្តន៍)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
សាលាខេត្តរតនគិរី
លេខ.០២១/១២

រតនគិរី,ថ្ងៃទី.០២...ខែ.កក្កដា...ឆ្នាំ២០១២

# សេចក្តីប្រកាស
## ស្តីពី
## ការកំណត់តំបន់វិនិច្ឆ័យសម្រាប់ការងារចុះបញ្ជីដីធ្លី ដើម្បីផ្តល់បណ្ណកម្មសិទ្ធិបឋម

-យោងអនុក្រឹត្យលេខ ១១៨អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការគ្រប់គ្រងដីរដ្ឋ ។

-យោងសារាចរលេខ០២ស.រ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការកាន់កាប់ដីរដ្ឋខុសច្បាប់ ។

អភិបាលខេត្តរតនគិរី និងជាប្រធានគណកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត សូមធ្វើការកំណត់ដូចខាងក្រោម :

១.កំណត់ឃុំប៉ុង ឃុំភ្នំកុក និង ឃុំហាត់ប៉ក់ (ចំនុចៈ បានប៉ុង បានហ្វាំង កាឡៃសាពូន កាឡៃតាវង ទៀមក្រោម តាកុកព្រៅ តាកុកឡាវ ឡាំប៉ាត់) ស្រុកវីនសៃ ខេត្តរតនគិរី ជាតំបន់វិនិច្ឆ័យសំរាប់ការងារចុះបញ្ជីដីធ្លីផ្តល់ប័ណ្ណកម្មសិទ្ធិបឋម ។

២.ការវិនិច្ឆ័យសម្រាប់ការងារចុះបញ្ជីដីធ្លីផ្តល់ប័ណ្ណកម្មសិទ្ធិបឋមនៅក្នុងតំបន់វិនិច្ឆ័យខាងលើ នឹងត្រូវប្រតិបត្តិការដោយកិច្ចសហការរបស់មន្ត្រីជំនាញ និងយុវជនស្ម័គ្រចិត្ត ចាប់ពីថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១២ តទៅ នៅទីតាំងដីខាងលើ ។

៣.អាជ្ញាធរមូលដ្ឋាននៃតំបន់វិនិច្ឆ័យខាងលើ អង្គភាពពាក់ព័ន្ធ និង ប្រជាពលរដ្ឋដែលជាអ្នកកាន់កាប់ ដីស្រែ ដីចំការ និង ដីលំនៅដ្ឋាន ឬ សាងសង់ទាំងអស់ដែលមានក្បាលដីនៅក្នុងតំបន់នោះត្រូវសហការជាមួយ មន្ត្រីជំនាញនិងយុវជនស្ម័គ្រចិត្ត ដែលនឹងចុះបំពេញភារកិច្ចនៃកិច្ចការវិនិច្ឆ័យសម្រាប់ការងារចុះបញ្ជីដីធ្លីផ្តល់ប័ណ្ណកម្មសិទ្ធិបឋមនេះ នៅក្នុងតំបន់ដែលបានកំណត់ក្នុងចំណុច១ ស្ថិតនៅក្នុងក្រុមហ៊ុនអេសខេ ។

៤.សេចក្តីប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តន៍ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**អភិបាលខេត្តរតនគិរី**
**និងជាប្រធានគណកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត**

**ប៉ាវ ហាមផាន់**

ចម្លងជូន
-ទីស្តីការគណរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់
(ដើម្បីជូនជ្រាប)
-សាលាស្រុកវីនសៃ
-មន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដី
-សាលាឃុំប៉ុង ភ្នំកុក ហាត់ប៉ក់
(ដើម្បីសហការអនុវត្តន៍)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ

សាលាខេត្តរតនគិរី

លេខ.០៤៧/១២

រតនគិរី.ថ្ងៃទី..០២..ខែ..កក្កដា..ឆ្នាំ២០១២

**សេចក្តីប្រកាស**

**ស្តីពី**

**ការកំណត់តំបន់វិនិច្ឆ័យសម្រាប់ការងារចុះបញ្ជីដីធ្លី**

**ដើម្បីផ្តល់បណ្ណកម្មសិទ្ធិបឋម**

-យោងអនុក្រឹត្យលេខ ១១៨អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការគ្រប់គ្រងដីរដ្ឋ ។

-យោងសារាចរលេខ០២ស.រ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការកាន់កាប់ដីរដ្ឋខុសច្បាប់ ។

អភិបាលខេត្តរតនគិរី និងជាប្រធានគណកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត សូមធ្វើការកំណត់ដូចខាងក្រោម :

១.កំណត់ឃុំលំជ័រ ឃុំសោមធំ ឃុំសេសាន្ត ឃុំកិះចុង និង ឃុំកក់ (ចំនុចៈ ឡៃ សោមគល់ ផ្តោល គ្រៀង កាចរ៉ា) ស្រុកអូរយ៉ាដាវ និង ស្រុកបរកែវ ខេត្តរតនគិរី ជាតំបន់វិនិច្ឆ័យសំរាប់ការងារចុះបញ្ជីដីធ្លីផ្តល់ប័ណ្ណកម្មសិទ្ធិបឋម ។

២.ការវិនិច្ឆ័យសម្រាប់ការងារចុះបញ្ជីដីធ្លីផ្តល់ប័ណ្ណកម្មសិទ្ធិបឋមនៅក្នុងតំបន់វិនិច្ឆ័យខាងលើ នឹងត្រូវប្រតិបត្តិការដោយកិច្ចសហការរបស់មន្ត្រីជំនាញ និងយុវជនស្ម័គ្រចិត្ត ចាប់ពីថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១២ តទៅ នៅទីតាំងដីខាងលើ ។

៣.អាជ្ញាធរមូលដ្ឋាននៃតំបន់វិនិច្ឆ័យខាងលើ អង្គភាពពាក់ព័ន្ធ និង ប្រជាពលរដ្ឋដែលជាអ្នកកាន់កាប់ ដីស្រែ ដីចំការ និង ដីលំនៅដ្ឋាន ឬ សាងសង់ទាំងអស់ដែលមានក្បាលដីនៅក្នុងតំបន់នោះត្រូវសហការជាមួយ មន្ត្រីជំនាញនិងយុវជនស្ម័គ្រចិត្ត ដែលនឹងចុះបំពេញភារកិច្ចនៃកិច្ចការវិនិច្ឆ័យសម្រាប់ការងារចុះបញ្ជីដីធ្លីផ្តល់ប័ណ្ណកម្មសិទ្ធិបឋមនេះ នៅក្នុងតំបន់ដែលបានកំណត់ក្នុងចំណុច១ ស្ថិតនៅក្នុងក្រុមហ៊ុនជាច័ន្ទរិទ្ធ ។

៤.សេចក្តីប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តន៍ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**អភិបាលខេត្តរតនគិរី**

**និងជាប្រធានគណកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត**

**ផាវ ហាមផាន**

ចម្លងជូន

-ទីស្តីការគណរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់

(ដើម្បីជូនជ្រាប)

-សាលាស្រុកអូរយ៉ាដាវ និង ស្រុកបរកែវ

-មន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដី

-សាលាឃុំលំជ័រ ឃុំសេសាន្ត ឃុំសោមធំ ឃុំកិះចុង និងឃុំកក់

(ដើម្បីសហការអនុវត្តន៍)

# ឧបសម្ព័ន្ធទី៣

# បញ្ជីក្រុមហ៊ុន

| |
|---|
| ក្រុមនិសិត្សវាស់វែងដីរួចហើយ |
| ក្រុមនិសិត្សនៅបន្តការវាស់វែងបន្ត |
| ក្រុមនិសិត្សមិនធ្វើការវាស់វែង |
| ក្រុមនិសិត្សធ្វើការវាស់វែងទោះបីជាអត់មានក្រុមហ៊ុន មានចំនួន ១ភូមិ |

| ភូមិ | ឃុំ | ស្រុក | ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច | ឈ្មោះក្រុមហ៊ុន |
|---|---|---|---|---|
| លោម | ម៉ាលិក | អណ្តូងមាស | ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច | វាសនា និង ៧៥ |
| ពែង | ញ៉ាង | អណ្តូងមាស | ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច | ហុង អាំងអូរយ៉ាដាវ |
| ញ៉ាង | ញ៉ាង | អណ្តូងមាស | ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច | ៧មករា |
| កេត | ញ៉ាង | អណ្តូងមាស | ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច | ឌី អេមគ្រុប និង ៧ មករា |
| កាណាតធំ | តា ឡាវ | អណ្តូងមាស | ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច | ហេង ប្រ៉ាដើ |
| ការណាតតូច | តា ឡាវ | អណ្តូងមាស | ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច | ហេង ប្រ៉ាដើ |
| ទៀន បខាំ | ញ៉ាង | អណ្តូងមាស | ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច | ចាន់រី |
| តាង ជិ | ញ៉ាង | អណ្តូងមាស | ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច | ឌី អេមគ្រុប និង ៧ មករា |
| អ៊ិន | តា ឡាវ | អណ្តូងមាស | ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច | ហុង អាំ អូរយ៉ាដាវ |

| | | | | |
|---|---|---|---|---|
| ម៉ាលិក | ម៉ាលិក | អណ្ដូងមាស | ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច | ហេងប្រ៉ាដើ ហេងវាសនា ហុង អាំងអូរយ៉ាដាវ |
| កាតែ | តា ឡាវ | អណ្ដូងមាស | ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច | ហុង អាំងអូរយ៉ាដាវ |
| តា ឡាវ | តា ឡាវ | អណ្ដូងមាស | ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច | ហេងប្រ៉ាដើ ហេងវាសនា |
| កា នង | តា ឡាវ | អណ្ដូងមាស | ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច | ហុង អាំងអូរយ៉ាដាវ |
| យ៉ាសោម | ស៊ើង | បរកែវ | ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច | អាវ ឡាវ យូយស្តុក |
| ស៊ើង | ស៊ើង | បរកែវ | អត់មានក្រុមហ៊ុនចូល | អត់ដឹង |
| ស៊ូ | ឡាមិន | បរកែវ | អត់មានក្រុមហ៊ុនចូល | អត់ |
| ជ្រុង | កក់ | បរកែវ | អត់មានក្រុមហ៊ុនចូល | អត់ដឹង |
| សាលា | កក់ | បរកែវ | អត់មានក្រុមហ៊ុនចូល | អត់ដឹង |
| តេន | កិចុង | បរកែវ | ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច | ហេង វាសនា |
| ប៉ាអរ | កិចុង | បរកែវ | ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចខ្នាត់តូច | Koh Gomlayng; Ansok |
| សាគ្រៀង | កិចុង | បរកែវ | ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច | ចាន់រី |
| យ៉ែម | ស៊ើង | បរកែវ | អត់មានក្រុមហ៊ុនចូល | អត់ដឹង |
| កាចក់ | កក់ | បរកែវ | ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច | ហុង អាំ អូរយ៉ាដាវ ជីចាន់ណារ៉ត់ |
| តាអង | តអង | កូនមុំ | អត់មានក្រុមហ៊ុនចូល | អត់ដឹង |
| តឺន | តឿន | កូនមុំ | អត់មានក្រុមហ៊ុនចូល | អត់ដឹង |

| | | | | |
|---|---|---|---|---|
| តា ហើយ | តឿន | កូនមុំ | អត់មានក្រុមហ៊ុនចូល | អត់ដឹង |
| ខ្លែង | តឿន | កូនមុំ | ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច | ទ្រីភាព |
| តាបាក់ | តឿន | កូនមុំ | ក្រុមហ៊ុនរ៉ែសម្បទាសេដ្ឋកិច្ច | អត់ដឹង |
| ចាងរ៉ា | ប៉ាតាង | លំផាត់ | ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច | កោះ បិក |
| សាយ៉ស់ | កាឡែង | លំផាត់ | ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច | កោះ បិក |
| កាឡែង | កាឡែង | លំផាត់ | ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច | កោះ បិក |
| កឡែង | ឡាបាំង ១ | លំផាត់ | អត់មានក្រុមហ៊ុនចូល | អត់មាន |
| កាទៀង | ឡាបាំង ១ | លំផាត់ | អត់មានក្រុមហ៊ុនចូល | អត់មាន |
| កាទៀង | ឡាបាំង ២ | លំផាត់ | អត់មានក្រុមហ៊ុនចូល | អត់មាន |
| កាចូន | ឡាបាំង២ | លំផាត់ | អត់មានក្រុមហ៊ុនចូល | អត់មាន |
| សមុទ្រលើ | សេដា | លំផាត់ | ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច | អារ ឡារ យូយ ស្តក់ និង ជិនសំរី |
| សមុទ្រក្រោម | សេដា | លំផាត់ | ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច | អារ ឡារ យូយ ស្តក់ |
| ថ្មី | សេដា | លំផាត់ | ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច | អារ ឡារ យូយ ស្តក់ |
| ប៉ាតត់ | សេដា | លំផាត់ | អត់មានក្រុមហ៊ុនចូល | អត់មាន |
| ប៉ាតាង | ប៉ាតាង | លំផាត់ | អត់មានក្រុមហ៊ុនចូល | អត់មាន |

| | | | | |
|---|---|---|---|---|
| ទេន ងល | យ៉ាទុង | អូយ៉ាដាវ | ការធ្វើកុងត្រាខ្នាតតូចជាមួយក្រុមហ៊ុន | ម៉ាញ សារ៉ុន |
| ប៉ាដល | សេសាន្ត | អូយ៉ាដាវ | ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច | ចាយ ចាន់ណារ៉ុន ៧២ |
| ភិ | សេសាន្ត | អូយ៉ាដាវ | ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច | ៧ មករា |
| ពាក់ | យ៉ាទុង | អូយ៉ាដាវ | ក្រុមហ៊ុនរ៉ែសម្បទាសេដ្ឋកិច្ច | ក្រុមហ៊ុន ភីភីអេមស៊ី ហ្គូលដិនម៉ាញ |
| ប្លង់ | ប៉ាតេ | អូយ៉ាដាវ | អត់មានក្រុមហ៊ុនចូល | អត់មាន |
| គងធំ | ប៉ាតេ | អូយ៉ាដាវ | អត់មានក្រុមហ៊ុនចូល | អត់មាន |
| គងយុ | ប៉ាតេ | អូយ៉ាដាវ | ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចខ្នាត់តូច | កៀត កុលន័យ |
| ប៉កតូច | ប៉ក់ញ៉ៃ | អូយ៉ាដាវ | ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច | ដាយ ដុង យើង |
| តាកុកប្រាយ | បរខាំ | អូយ៉ាដាវ | ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច | ដាយ ដុង យើង |
| ប្រលៃ | លំជ័រ | អូយ៉ាដាវ | ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច | ហាង្ស អាំង វ៉ីអេន |
| កានសើង | ចាន់ | អូរជុំ | អត់មានក្រុមហ៊ុនចូល | អត់មាន |
| ក្រេះ | ចាន់ | អូរជុំ | អត់មានក្រុមហ៊ុនចូល | អត់មាន |
| កង គុយ | ចាន់ | អូរជុំ | អត់មានក្រុមហ៊ុនចូល | អត់មាន |
| តា ង៉ាច | ចាន់ | អូរជុំ | អត់មានក្រុមហ៊ុនចូល | អត់មាន |
| ក្រឡា | ចាន់ | អូរជុំ | អត់មានក្រុមហ៊ុនចូល | អត់មាន |
| ល្អក់ | ល្អក់ | អូរជុំ | អត់មានក្រុមហ៊ុនចូល | អត់មាន |
| ភូមិ២ | ល្អក់ | អូរជុំ | អត់មានក្រុមហ៊ុនចូល | អត់មាន |

| | | | | |
|---|---|---|---|---|
| ក្រលង | ល្អក់ | អូរជុំ | អត់មានក្រុមហ៊ុនចូល | អត់មាន |
| កាំ | ល្អក់ | អូរជុំ | ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច | ស៊ី អរ ឌី |
| ល្អើនជង | អូរជុំ | អូរជុំ | អត់មានក្រុមហ៊ុនចូល | អត់មាន |
| តងការម៉ាល់ | អូរជុំ | អូរជុំ | អត់មានក្រុមហ៊ុនចូល | អត់មាន |
| ទុយធំ | អូរជុំ | អូរជុំ | អត់មានក្រុមហ៊ុនចូល | អត់មាន |
| ស្វាយ | អូរជុំ | អូរជុំ | អត់មានក្រុមហ៊ុនចូល | អត់មាន |
| ចាន់ | តាវែងលើ | តាវែង | ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច | ក្រុមហ៊ុនក្រុមប៉ុក |
| ជួយ | តាវែងលើ | តាវែង | ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច | ក្រុមហ៊ុនក្រុមប៉ុក |
| ទុន | តាវែងក្រោម | តាវែង | អត់មានក្រុមហ៊ុនចូល | អត់មាន |
| សៀងសាយ | តាវែងក្រោម | តាវែង | អត់មានក្រុមហ៊ុនចូល | អត់មាន |
| ផា យ៉ាង | តាវែងក្រោម | តាវែង | អត់មានក្រុមហ៊ុនចូល | អត់មាន |
| កិ កួង | តាវែងក្រោម | តាវែង | អត់មានក្រុមហ៊ុនចូល | អត់មាន |
| ទំពូនរឹងតូច | តាវែងក្រោម | តាវែង | អត់មានក្រុមហ៊ុនចូល | អត់មាន |
| កាឡៃតារ៉ង | ភ្នំកុក | វើនសៃ | ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច | ក្រុមហ៊ុនថ្មី និងឆេងឡុក |
| ទៀមក្រោម | ភ្នំកុក | វើនសៃ | ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច | ក្រុមហ៊ុន ម៉ានយាង និង អេមអេសខេ |
| កាឡៃសាពូន | ភ្នំកុក | វើនសៃ | ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច | ក្រុមហ៊ុន ម៉ានយាង និង អេមអេសខេ |
| ភ្នំកុកព្រៅ | ភ្នំកុក | វើនសៃ | អត់មានក្រុមហ៊ុនចូល | អត់មាន |
| កោះពាក់ | កោះពាក់ | វើនសៃ | អត់មានក្រុមហ៊ុនចូល | អត់មាន |

| | | | | |
|---|---|---|---|---|
| ឃុន | កោះពាក់ | វ៉ីនសៃ | អត់មានក្រុមហ៊ុនចូល | អត់មាន |
| ផាកណាម | កោះពាក់ | វ៉ីនសៃ | អត់មានក្រុមហ៊ុនចូល | អត់មាន |
| រ៉ក | កុកឡាក់ | វ៉ីនសៃ | អត់មានក្រុមហ៊ុនចូល | អត់មាន |
| ឡាឡៃ | កុកឡាក់ | វ៉ីនសៃ | អត់មានក្រុមហ៊ុនចូល | អត់មាន |

| ក្រុមហ៊ុន | ចំនួនភូមិដែលរងផលប៉ះពាល់ |
|---|---|
| ហុង អាង អូរយ៉ាដាវ | ៨ |
| ៧ មករា | ៤ |
| អាវ ឡាវ យូយ | ៤ |
| ហេងប្រ៉ាដើ | ៤ |
| ហេងវាសនា | ៣ |
| កោះបិក | ៣ |
| វាសនា | ៣ |
| ស៊ី អរ ឌី | ២ |
| ដាយ ដង | ២ |
| ឌី អេម គ្រុប | ២ |
| ក្រុមបុក | ២ |
| ចាន់លី | ២ |
| ចាយ ចាន់ណារត់ | ២ |
| ម៉ាន យ៉ាន | ២ |
| អេម អេសខេ | ២ |
| ៧២ | ១ |
| ៧៥ | ១ |
| អានសុក | ១ |
| ឆេងឡុក | ១ |
| ឌិង សំរី | ១ |
| គៀត កល្យាន៍យ | ១ |
| ក្រុមបុក | ១ |
| ក្រុមបុក | ១ |
| ម៉ាង សរុន | ១ |
| ភី ភី អេម ស៊ី ហ្គូលដិន ម៉ាញ | ១ |
| ថ្មី | ១ |
| ទ្រីភាព | ១ |

ចំណាំ: ខាងលើនេះគឺជារបាយការណ៍ដោយផ្ទាល់នៃឈ្មោះក្រុមហ៊ុន ពីអ្នកភូមិដែលទទួលរងផលប៉ះពាល់ ហើយឯកសារផ្លូវការជាមួយនឹងឈ្មោះរបស់ក្រុមហ៊ុនមិនត្រូវបានរកឃើញនៅក្នុងករណីភាគច្រើន ដូច្នេះអក្ខរាវិរុទ្ធអាចសរសេរមិនត្រឹមត្រូវ។